# ខេមរូប សូវខ្មៅ

វង់ជឿន



93

ក

895.9323
MARYKNOLL
Date... 2004 ...

# រឿង

# “ទេវរូបត្បូងខ្មៅ”

និពន្ធដោយ វង់ ជៀប

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
00012160

ឆ្នាំ ១៩៧៤

បោះពុម្ពឡើងវិញដោយបណ្ណាគារ "**អង្គរធំ**"

អាសយដ្ឋានៈ ១៤៩អឺស្ទូឡ, វិថីខេមរភូមិន្ទ, ភ្នំពេញ

ទូរស័ព្ទលេខៈ (៨៥៥) ២៣ ២១០ ២៥៨

ឆ្នាំ ២០០២

(បោះពុម្ពក្នុងខ្នាតៈ ២០ × ១៤ សង់ទីម៉ែត្រ)

រូបក្របៈ គូរឡើងវិញដោយវិចិត្រករ **ខៀវ ចាន់ថារា**

ទូរស័ព្ទលេខៈ (៨៥៥) ១២ ៩៤៥ ៦៣២

(គូរតាមរូបដើមទាំងស្រុង)

វាយអត្ថបទដោយកញ្ញា **លី សុវណ្ណារី**

ម៉ូតអក្សរ Limon S2, ទំហំ ២២

រចនាឱ្យចេញជាសៀវភៅដោយលោក **ហាក់ ចាន់ដារា**

កែអក្ខរាវិរុទ្ធដោយលោក **ឈុន សុខា**

(កែតាមសំណេរដើមទាំងស្រុង)

ឯកសារដើមបានមកពីគម្រោងស្រាវជ្រាវ

" ***វិវឌ្ឍន៍អក្សរសិល្ប៍ខ្មែរសតវត្សទី២០*** "

# អារម្ភកថា

ស្លាកស្នាមប្រវត្តិសាស្ត្រជាច្រើនបានបង្ហាញឱ្យឃើញថា ជនជាតិខ្មែរជាជនជាតិមួយ មានខឿនអរិយធម៌-វប្បធម៌ដ៏រុងរឿង ។ ទោះបីជាមានការរុកទន្ទ្រានពីសត្រូវជិតខាង ឬ មានចំបាំងរាំងជល់ផ្ទៃក្នុងក៏ដោយ ក៏វិស័យសិល្បៈ-អក្សរសិល្ប៍របស់ខ្លួន នៅតែបន្តការវិវត្តន៍ឥតឈប់ឈរ ។ ប៉ុន្តែគួរឱ្យអនិច្ចាឆ្នាំ ១៩៧០ រដ្ឋប្រហារមួយបានទម្លាក់ព្រះមហាក្សត្រ ព្រះបាទ សម្តេចព្រះ ***នរោត្តម សីហនុ*** ដែលព្រះអង្គតែងយកព្រះទ័យទុកដាក់លើវិស័យអក្សរសាស្ត្រជាតិ រហូតប្រជាពលរដ្ឋបានថ្វាយព្រះនាមព្រះអង្គ ជាព្រះបិតាអក្សរសាស្ត្រជាតិ ។ សង្គ្រាម. របបប្រល័យពូជសាសន៍ បានបំផ្លិចបំផ្លាញជាតិគ្រប់វិស័យស្ទើរដល់កម្រិតសូន្យ ក្នុងនោះ មានស្នាដៃអក្សរសិល្ប៍ផងដែរ ។ ក្រោយពីមានការបង្រួបបង្រួមជាតិក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះមហាក្សត្រ ជនជាតិខ្មែរបានរួបរួមសាមគ្គីគ្នាជាធ្លុងមួយ ស្តារ និង កសាងជាតិឡើងវិញ ។ ដោយយល់ឃើញពីសារៈសំខាន់នៃវិស័យអក្សរសិល្ប៍ក្នុងការលើកស្ទួយវប្បធម៌របស់ខ្លួន បណ្ណាគារ "**អង្គរធំ**" យើងខ្ញុំក៏បានសម្រេចលើកយកស្នាដៃប្រលោមលោកចាស់ៗ របស់អ្នកនិពន្ធដែលធ្លាប់មានឈ្មោះល្បី មកធ្វើការបោះពុម្ពឡើងវិញ ក្នុងគោលបំណងថែរក្សានូវសម្បត្តិរួមរបស់ជាតិ ដើម្បីឱ្យកូនខ្មែរជំនាន់ក្រោយៗ បានចេះដឹង គ្រាន់ជាគុណប្រយោជន៍រួមដល់សង្គមជាតិ ។

*ភ្នំពេញ, ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០០២*

# អារម្ភកថា

អ្នកនិពន្ធមានឆន្ទៈឯកី លើកតំកើងថ្វីដៃតេជះចារបុរសខ្មែរ ឲ្យស្មើនឹងអន្តរជាតិ ។

អច្ឆរិយាក០០៥ចារបុរសខ្មែរ មានរាងសង្ហារដូចរាជសីហ៍ ដៃដែកភ្នែកឥន្ទ្រី គំនិតប្រតិកម្មដែលថាបុរសមួយផែននេះ លំអោនគោពស្ងប់ស្ងែង ហើយខ្លបខ្លាចចំពោះស្នាដៃចារកិច្ចរបស់គេ ។

មែន អច្ឆរិយ មិនត្រឹមតែមានថ្វីដៃខាងចារកិច្ចប៉ុណ្ណោះទេ គឺថែមទាំងមានដើមទ្រូងស្រាល ត្រគាកធូន់ទៀតផង នារីណាបានជួបហើយ លើកដៃអធិដ្ឋាន បួងសួងប្រាថ្នាសុំឱយជួបអច្ឆរិយាគ្រប់៧ជាតិ ។

អ្នកនិពន្ធ

~១~

សៀមរាបជាខេត្តទេសចរណ៍ ព្រោះខេត្តនេះសំបូរទៅដោយប្រាងប្រាសាទរាប់រយ ដែលជាកេរ្តិ៍ដំណែលរបស់បុព្វបុរសជូនតាយើងបានកសាងបន្សល់ទុកអោយកូនចៅជាន់ក្រោយរក្សាទុក ។

នៅក្នុងព្រៃស្រោងធំល្វឹងល្វើយពោរពេញទៅដោយដើមគគី ស្រឡៅ ពពេល ឃាង គ្រាច មានបង្កប់នូវអច្ឆរិយវត្ថុដ៏ធំសំបើមដែលមហាជនក្នុងពិភពលោកនេះកោតស្ញប់ស្ញែងនិងឱនក្បាលទទួលស្គាល់ថា ពីអតីតកាលទឹកដីនេះពិតជាមានអរិយធម៌ដ៏ខ្ពស់កំពូលមែន ។

ជារៀងរាល់ថ្ងៃ ទេសចរណ៍ជាតិនិងអន្តរជាតិបានធ្វើដំណើរតាមផ្លូវជាតិដែលសន្ធឹងកាត់ពីក្រោមម្លប់ឈើដ៏ត្រឈឹងត្រឈៃ មកដល់ប្រាសាទអង្គរដែលល្អឆើតជាងគេ ដើម្បីអោយបានយល់ស្នាដៃដ៏មហាអស្ចារ្យនេះដែលលើពិភពលោកមានតែមួយគត់ ។

ក្នុងបណ្តាយានជំនិះដែលបរខ្វាត់ខ្វែងឡើងចុះនោះ យើងឃើញម៉ូតូហុងដា ១២៥ មួយបញ្ហាដោយយុវជនម្នាក់ពាក់អាវកាគី

ពណ៌លឿង ស្លៀកខោខូវបោយ បើកក្នុងល្បឿនប្រៀបដូចខ្យល់កំបុតត្បូង ។

មុខរបស់គេលំអរដោយវ៉ែនតាខ្មៅធំៗ តែគួរចំលែកគេហាក់ដូចឥតរវល់ដល់ទេសភាពដ៏ត្រកាល នៃឧទ្យានអង្គរដូចគេរាល់គ្នាឡើយ ។

ទោចក្រយានយន្តបតកាច់ពីមុខអង្គរ ហើយបត់ទៅលិចតាមផ្លូវមួយដែលតំរង់ទៅកាន់វាល់ចំណតយន្តហោះអន្តរជាតិខេត្តសៀមរាប ។

គេចផុតពីខឿនអង្គរ ឬ មុខនាគ បានកន្លះគីឡូ យានត្រូវបញ្ឆាអោយបត់ចុះតាមផ្លូវលំមួយខាងស្តាំ ហើយរត់តាមល្បឿនយឺតៗ ព្រោះផ្លូវនោះប្រកបដោយខ្សាច់ និង បត់បែន ។

មួយស្របក់ក្រោយមក គេបានមកដល់ភូមិមួយដែលមានផ្លាក់ពីដើមភូមិថា ភូមិត្រពាំងសេះ បុរសចំលែកបញ្ឈប់ម៉ូតូហើយដោះវ៉ែនតា គេបីតខ្យល់ពេញសួត រេភ្នែកមើលក្រែងលោមានអ្នកភូមិណាម្នាក់ដើម្បីទាក់ទង ។

ពេលនោះមានបុរសចំណាស់ម្នាក់ចេញពីជ្រុងម្ខាង ដោយមានរែកបំពង់ទឹកត្នោតរណែងរណោងជាមួយផង ។

ដោយចរន្តគំនិតស្វ័យប្រវត្តិ បុរសនោះសសៀកខ្លួនទៅឈប់ពីមុខជនចំណាស់ ហើយរលាស់វាចាដែលធ្វើអោយយើងស្មានមិនត្រូវ ។ តាមរាងរៅគេសមជាមនុស្សកោងហើយទើបសមដែលសំដីសំដៅផ្ទុយស្រឡះ ព្រោះសុភាពរាបសារ :

-ជំរាបសួរលោកអ៊ំ

អ៊ំចាស់ទប់ជំហាន ងើបមើលមុខម្ចាស់សំនួរហើយដកចារីស្ទឹកសង្កែចេញពីមាត់ :

-អូ ! ថ្វាយព្រះ

គាត់ចង់និយាយទៅទៀត តែឃើញម្ចាស់សំនួមានសំលៀកបំពាក់ជាអ្នកក្រុងក៏អាក់សំដី រវល់តែពិនិត្យរាងរៅមួយសន្ទុះទើបបន្តទៀត :-

-ចុះក្មួយឯងទៅណាមកណា ? យីស្លៀកពាក់ស្អាត់បាតណាស់តើ ! មានការអីឬលោកក្មួយ ?

បុរសសង្ហារងាកឆ្វេងស្តាំ លុះឃើញស្ងាត់គ្មានមនុស្សក៏សួរថា :

-សូមទោសលោកអ៊ំ ! ចុះបងប្អូនអ្នកភូមិទៅណាអស់ហើយបានជាស្ងាត់យ៉ាងនេះ ?

-អូ ! ស្មើហ្នឹងគ្មានអ្នកណានៅផ្ទះទេ គេនាំគ្នាទៅជំរះស្មៅចំការអស់ហើយ ! ក្មួយសួរមានការអីឬ ?

-បាទ ! ក្មួយជាអ្នកដំណើរ ហើយត្រូវជាក្មួយអ៊ំយន់ផងបាទ!

-អូ ! ក្មួយអ៊ំយន់ ?អ៊ំយន់ត្រូវគេលួចសំលាប់ពីថ្ងៃមុននោះឬ?

-អ្ហា ! អ៊ុំ យន់ ត្រូវគេសំលាប់ ?

អ៊ំចាស់ដាក់បំពង់ទឹកត្នោតចុះ អូសដៃបុរសសង្ហារទៅម្ខាងៈ

-ក្មួយឯងមកខាងណេះចាំអ៊ំប្រាប់ ព្រោះអ៊ំជាមិត្តភក្តិរបស់អាយន់ដែរ !

-បុរសសង្ហារអង្គុយក្បែរអ៊ំចាស់រង់ចាំស្តាប់គាត់អធិប្បាយៈ

-ក្មួយឯងនៅស្រុកឯណាដែរ ? ហើយហេតុដូចម្តេចបានជាក្រទទួលដំណឹងពីមរណភាពរបស់អាយន់ម្ល៉េះ ?

-បាទ ! លោកអ៊ំ ! ខ្ញុំរស់នៅភ្នំពេញ ខ្ញុំឥតបានទទួលដំណឹងពីញាតិមិត្តប្រាប់ទេ គឺខ្ញុំដឹងតាមការសែតដែលចុះផ្សាយពីដំណឹងនេះ ។

អត់ទោសលោកអ៊ំ តើមកដល់ថ្ងៃនេះ គេអាចសន្និដានបាន

គីរីវុធ ស្លៀកពាក់យ៉ាងរហ័ស ហើយដើរទៅលាយឡំជាមួយគេឯងដែលទៅកាន់ខ្ទមចំការ ។

ក្រោមវ៉ែនតាធំៗកំលោះទីក្រុងឃើញសពរបស់អ៊ំវងគ្រោះត្រូវឃាតកអារបំពងកពីម្ខាងទៅម្ខាង ឈាមហូរធ្លាក់តាមរនាបទៅដីឡើងកកខ្មៅ ។

ញាតិមិត្តរបស់សពខ្លះយំ ខ្លះរៀបចំយកសពទៅភូមិតែពេលនោះប្រធានភូមិបានមកដល់ហើយប្រាប់ :

-បងប្អូនកុំអាល់ប៉ះពាល់សពអី ទុកអោយគេមកកត់ហេតុ និងថតទុកស្រាវជ្រាវសិន !

-យី !អ្នកណាក៏ចិត្តអាក្រក់ម្ល៉េះ លើកដៃសំលាប់មនុស្សចាស់ដូចអ៊ំចាន់ទៅកើត ?

នេះជាពាក្យរបស់អ្នកដែលបានមកមើលសាកសព។ ក្នុងនោះគេទាំងអស់បានចាប់អារម្មណ៍លើរូប គីរីវុធ ដែលអ្នកចំណូលស្រុកគេមើលនាយតាំងពីលើដល់ក្រោម ហើយមានអ្នកខ្លះចាប់អារម្មណ៍សង្ស័យលើរូបនាយទៀតផង !

អ្នកដែលតាមដានមើល គីរីវុធ ជាងគេ គឺ ឆោម ឆោមមើលនាយមិនដាក់ភ្នែក ហើយខ្សិបខ្សៀរត្រចៀកប្រធានភូមិ

-ល្បង !អាដែងមកពីភ្នំពេញពីម្សិលស្រាប់តែយប់មិញមានគេសំលាប់អ៊ំ ចាន់ តើគួរអោយយើងចាប់អារម្មណ៍ដែរ ?

ប្រធានភូមិសំលឹងមុខ គីរីវុធ :

-យើងមិនទាន់សន្និដ្ឋានថាគេយ៉ាងម៉េចបានទេ ! ចាំមើលក្រសួងមានសមត្ថកិច្ចគេមកពិនិត្យសិន តើគេថាម៉េច ! យើងកុំអាលមុសាគេមុន !

គីរីវុធ ដូចជាឈ្លលចុងច្រមុះដែរ នាយដើរទៅជិតឆោមពោលថា :

-បើតាមឫកពារ ខ្ញុំដូចជាសង្ស័យលើរូបឯងថាជាឃាតក !

ឆោមខឹងមុខក្រហមញ័រដៃទទ្រើត :

-យើ !អាអ្នកក្រុង !បានមាត់បានកតើ !មើល៍ ! អាឯងជាស្អីទៅ !

ឆោមស្រែកចប់ស្ទុះដាល់កណ្ដាប់មាត់គីរីវុធជាច់ ... តែខុសស្រឡះ គីរីវុធចាប់ដៃជាប់រឹងដូចដង្កាប់ :

-នែ !ល្បង !កុំអាលផ្គោរក្រមាល់ផ្គេសផ្គាសប្រយ័ត្នអស់ធ្មេញស៊ីបាយ !

ឆោមខឹងណាស់ កន្ត្រាក់ដៃទាញទៅវិញតែកណ្ដាប់ដៃរបស់

គីរវុធរឹងដូចដែក នាយសើចខ្ទឹប ហើយរុញខ្លួនឆោមបន្តិច បណ្តាលអោយនាយទ្រេតទៅលើប្រធានភូមិ ។

ពេលនោះ យ៉ានី រត់មកឃាត់ :

-បង ! បង ! កុំបង្កជម្លោះអី !

-យល់លើប្អូនស្រីខ្ញុំ ! ខ្ញុំខ្ទប់កំហឹងខ្ញុំទុកប៉ុណ្ណោះសិនចុះង ! កុំអីអ្នកឯង ... ហ៊ឹស !

ឆោមស្តោះទឹកមាត់

-អញក៏យល់លើ យ៉ានីដែរ បើពុំដូច្នោះតែ ... ហ៊ឹស ! រត់ចេញពីភូមិមិនទាន់ទេអា !

ប្រធានភូមិក៏ឃាត់ជម្លោះដែរ ។

ស្នូរសំលេងជជែកព្រមជាមួយភ្នាក់ងារពីរនាក់ និងពេទ្យម្នាក់មកដល់ ដើម្បីធ្វើការកត់ហេតុ និងថតយករូបទុកជាឯកសារសំរាប់ស្រាវជ្រាវរកប្រភពតទៅទៀត ។

ឆ្លៀតពេលគេកំពុងយកចិត្តទុកដាក់នឹងការកត់ហេតុ ព្រមទាំងចំលើយផ្សេងៗ គីរវុធ បានគេចខ្លួនចេញពីទីនោះភ្លាម នាយលាអ៊ំ សែម ហើយធ្វើដំណើរមកកាន់ទីរួមខេត្តសៀមរាបជាបន្ទាន់។

នាយបានមកលបៗមុខភូមិគ្រិះមួយ ហើយរុញទ្វាររបង បណ្ដើរម៉ូតូចូលទៅ ។

សំលេងឆ្កែព្រូសពីក្នុងជាមួយនឹងសំលេងកំញើញ អាលុក អាលុក ! ឯងព្រូសអ្នកណា !

ភ្លាមនោះ នារីម្នាក់ចេញមក ពេលឃើញអ្នកបណ្ដើរម៉ូតូ នាងស្រែកដោយអំណរ :

-អូ ! បងវុធ ទេ ! បងមកដល់ពីអង្កាល់ ! ម៉េចមិនតេឡេហ្វូន អោយអូនដឹងមុន !

នាងពោលបណ្ដើររត់មកទទួលម៉ូតូ ព្រមទាំងកញ្ចប់ផ្លែឈើមួយកញ្ចប់ផងពីដៃគីរីវុធ ហើយស្រែក :

-ម៉ាក់អើយ ! បងវុធមក !

-អ៊ំចាស់ម្នាក់ដើរចេញមក គីរីវុធ លើកដៃជំរាបសួរ :

-ជំរាបសួរម៉ាក់អ៊ំ

-អើ ! គីរីវុធទេ ! ឯងមកដល់ពីអង្កាល់ ?

-បាទ ! មកពីម្សិលមិញ !

-បងឯងជិះអីមក !

-ម៉ូតូហ្នឹងណា !

-ស្លាប់ហើយ ! មកដល់ពីម្សិលមិញ ថ្ងៃនេះទើបឃើញមកដល់ផ្ទះអ៊ំ ! ចំជាចំលែកមែនក្មួយអញ រួចឯងមកធ្វើអីហ្នឹង ?

-បាទ ! មកលេងនឹងម៉ាក់អ៊ំ ! អាល័យតែនិយាយឯណេះភ្លេចសួរអោយឈឹង ! អូននារតីសុខសប្បាយទេ ? ធំអោយស្អិងតែម្តង!

-ហ៊ឹស !" នារីពេបមាត់" បែកគ្នាជិតមួយឆ្នាំបងចង់ភ្លេចនារតីហើយមែនទេ ?

-ទេ ! មិនភ្លេចទេ ! នារតី នៅតែជាប្អូនដ៏ក្រម៉ាច់ក្រមើមរបស់បងដដែលណា !

-ណ្ហើយ ! បងឯងតែអីចឹង ពេលជួបមុខសុទ្ធតែអីចេះ អីចុះយករួចពីមាត់ទេលុះក្រោយខ្នងវិញធ្លាយដូចមេឃអីចឹង មែនទេ !

-គ្មានទេ ! បងនឹកអូនដូចតែអូននឹកបងអីចឹង !

-គ្មានទេ ! អូនឥតជឿបងឯងទេ !

នារី ងងក់ គួរអោយខ្នាញ់ ។

-នារតី ! បងទើបមកពីអស់កំលាំងកុំអាលសួរនាំច្រើនពេកណា! នាំបងឯងចូលទៅក្នុងទៅ ! ហើយមើលរៀបចំណីមក !

-ចា៎ះ ម៉ាក់ !

គេក៏បណ្តើរគ្នាចូលកាន់បន្ទប់ទទួលភ្ញៀវ ។ គីរីវុធទំលាក់

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ខ្លួនលើកៅអីពួកពីមុខតុមូលតូចមួយ ។

អ៊ំស្រីម្ចាស់ផ្ទះអង្គុយទល់មុខនាយ :

-ក្មួយឯងមកលើកហ្នឹងមានការអីពិសេសឬ ?

-បាទ ! ពិតហើយម៉ាក់អ៊ំ តែជារឿងពិសេស និងស្ងាត់កំបាំងបំផុត !

-ម៉េចអីចឹង ?

-មិនអាចជំរាបម៉ាក់អ៊ំបានទេ !

ពេលនោះនារតីលើកថាសទឹកក្រូចព្រមទាំងនំ និងផ្លែឈើចេញមកផង :

-បងវុធ ! អញ្ជើញមកពិសាយកកំលាំង !

-អរគុណអូនណាស់ ! យី នារតីឥឡូវចេះបំរើភ្ញៀវចំណាប់ចំនួនណាស់តើ !

នារតី អៀនញញឹមខ្មីប :

-បងឯងកុំសួរបញ្ឆោរអូនពេក អូនធំហើយ ការអស់នេះត្រូវតែចេះជាធម្មតាទេ !

-បងនិយាយលេងទេនារតី ! អង្គុយចុះមកអូន ! បងចង់សួរអូនបន្តិចបានទេ ?

-បាន ! អោយតែបងចង់សួរហើយ អូននឹង អូនជំរាបបង ទាំងអស់ បងអធិការ !

គីរីវុធ ញញឹម :

-នារតី ! អូនរៀនថ្នាក់ទី ១ ទំនើបមែនទេ ?

-ចា៎ះ ! បងសួរមានការអីដែរ ?

-ក្នុងចំណោមអ្នករៀនជាមួយអូនឯង មានជើងល្អខ្លះទេ ?

-ចីមិនមាន ជើងល្អមានច្រើនណាស់ ត្រូវនឹងសព្វថ្ងៃគេចេះ ការ៉ាតេ តៃក្វាន់ដូ ម្ល៉ោះហើយម៉្ងៗ ឮសួរតែឈ្លោះគ្នា វាយគ្នា ជណ្តើមស្រី !

-បានហើយៗ ! បងចង់ដឹងតែប៉ុណ្ណឹងទេ ! អូនជួយបងបានទេ?

-យី ! ចុះបងឯងសព្វថ្ងៃយ៉ាងម៉េចបានជាចំឡែកម្ល៉េះ មាន ការអីមិននិយាយទៅ អោយអូនជួយរឿងអី ?

-បងចង់អោយអូនណែនាំអោយបងស្គាល់ពួកទាំងនោះផង តើបានទេ ?

-បានចេះតែបានហើយ តែគួរណែនាំដូចម្តេចទៅ ? ឬក៏នាំបង ឯងអោយទៅជួបនឹងគេ ហើយជំរាបសួរគេតែម្តងទៅ !

និយាយព្រមទាំងសើចឃឹកៗ ផង ។ គីរីវុធ គ្រវីក្បាល :

-មិនកើតតែ ! រកមធ្យោបាយផ្សេងវិញ ធ្វើដូចពាក្យអូនឯង បងទៅមិនរួចទេ !

-យី ក្រែងបងឯងជាអ្នកស៊ើបអង្កេតឬ ! អ្នកស៊ើបអង្កេតត្រូវធ្វើក៏ធ្វើដែរ មិនសូវសាញទេណា !

-បងមិនដឹងថាមិនត្រូវសាញហើយ តែកាលៈទេសៈនេះមិនមែនធ្វើដូចអូនឯងថានោះទេ !

-អីចឹងបងអោយអូនធ្វើដូចម្តេចទៅវិញ ?

អ៊ំស្រីអង្គុយស្ងាត់ស្ងៀមយូរហើយ ពោលកាត់ពាក្យសន្ទនារបស់ក្មេងៗ :

-ចាំបាច់រកមធ្យោបាយអីក្មួយ នៅប៉ុន្មានថ្ងៃទៀតនេះ ជាថ្ងៃកំណើតនារតីហើយ យើងរៀបចំពិធីជប់លៀង ហើយអញ្ជើញពួកគេះអោយចូលរួមផងទៅ នោះគីរីវុធអាចជួបនិយាយលេងជាមួយពួកទាំងនោះបានហើយ !

-ប្រសើរណាស់ ! ម៉ាក់អ៊ំពិតជាមានគំនិតល្អ !

-ធ្វើអីចឹងបានឬបងវុធ !

គីរីវុធងក់ក្បាល :

-បាទ ! និយាយអីចឹង លោកអ៊ំអញ្ជើញទៅណាហើយ ?

-ប៉ាវាឬ ? ប៉ាវាទៅកំពង់ធំបាត់ហើយ !

-ពេលណាទើបគាត់មកវិញ ម៉ាក់អ៊ំ ?

-ខានស្អែក ! នែ ! គីរីវុធ ញ៉ាំបាយនេះហើយណាក្មួយ !

-បាទ ! មិនអីទេ ! ខ្ញុំចង់បបួលម៉ាក់អ៊ំ និងនារតីទៅញ៉ាំបាយហាងវិញ !

-ដឹងឆ្ងាញ់អីបាយហាងទេបងវុធ !

-អើ ! មិនឆ្ងាញ់មែនហើយ តែយូរៗ បងមកលេងម្តង យើងបាយហាងធម្មតាទេ !

-អ៊ំមិនទៅទេ ! ឯងនាំនារតីទៅចុះ !

-អីចឹងម៉ាក់នៅចាំផ្ទះឬ ?

-ហ្នឹងហើយ !

-ខ្ញុំផ្ញើបាយឆាឡុកឡាក់ម៉ាក់អ៊ំមួយចានណា !

-អើ ! ប៉ុណ្ណឹងបានហើយ !

-ទៅ ! នារតី ស្លៀកពាក់ទៅអូន !

ក្រោយពីស្លៀកពាក់រួច គីរីវុធ បណ្តើរនារតី ទៅខាងក្រោយម៉ូតូរបស់គេ ហើយរូបគេជាអ្នកកាច់ចង្កូតបញ្ជាយានអោយរត់តិចៗ តាមមាត់ស្ទឹងសៀមរាបរហូតដល់ច្រាំងភូមិនេះ នៅភាគ

ខាងជើងក្រុងសៀមរាប ។

ទឹកស្ទឹងហូរវិញៗ លំអដោយរហាត់ទឹក វិលយឺតៗ ហើយលាក់សំលេងង៉េតង៉ិត និងសំលេងទរទឹកធាក់ទឹកឮសូរធំៗ ភូមិទ្រាំងសំបូរដោយដើមឈើស៊ីផ្លែ ដូចជាម៉ាក់ប្រាង គូលែន ខ្នុរ ត្បៀវ ដែលមានផ្លែពេញដើម ។

ក្រៅពី គីរីវុធ និងនារតី នៅមានសង្សារគេផ្សេងទៀតបណ្ដើរគ្នាលេងតាមដងស្ទឹង ដោយកង់ ឬម៉ូតូដូចនាយដែរ ។

-ភូមិទ្រាំងឥឡូវមនុស្សច្រើនណាស់មែនទេ នារតី ហើយអាកាសធាតុត្រជាក់ស្រួលផង !

នារតី ប្រកបដោយសំលៀកបំពាក់យ៉ាងឆើត នាងស្លៀកខោខូវបោយ ពាក់អាវយឺតពណ៌លឿង មើលមួយភ្លែតច្រឡំថាជាជនជាតិអឺរ៉ុប ។ នាងគងអន្ទាក់ខ្លាពីក្រោយគីរីវុធ ញញឹមបញ្ចេញធ្មេញពណ៌ដូចផ្កាម្លិះ :

-ចាស់ ! មកពីសព្វថ្ងៃនេះដើមឈើធំៗ អស់ទៅទើបចោលម្លប់ត្រជាក់ត្រឈឹងត្រឈៃដូចនេះ !

-មែន ! ដើមរុក្ខជាតិទាំងនេះចោលម្លប់ត្រឈឹងត្រឈៃ មិនខុសពីរូបនារតីដែលចោលម្លប់ដល់បេះដូងបងដែរ មែនទេ !

នារតី ក្តិចខ្នង គីរីវុធ :

-បានហើយ ! កុំសួរវោហាពេកអ្នកកវីត្បាញអាយ !

-បងមិនវោហាទេ តែបងនិយាយតាមតែចិត្តបងទេតើ នារតី អូនប្រឡងបាក់អង នៅខែណា ?

-ចាស់ខែប្រាំពីរ ! បងសួរធ្វើអី ?

-នៅសល់ប្រាំខែទៀតមែនទេ ?

-ចាស់ ! ត្រូវហើយ ! ប្រាំខែទៀត ! ឆ្មេចបើកដល់ហើយ !

-ម្ចាស់ថ្លៃអើយ ! " គីរីវុធ ឧទាន " ប្រាំខែឆ្មេចបើកដល់ ! ប្រាំខែសំរាប់បងមិនខុសពីប្រាំសតវត្សទេ !

-ម៉េចក៏បងឯងទន្ទឹងសំបើមម្ល៉េះ ?

-យី ! គោតតែអូនឯងសួរអីចឹងទៅកើត ក្រែងថ្ងៃរៀបការរបស់យើងនៅក្រោយពេលអូនប្រឡងជាប់បាក់អងឬ ?

-ចុះបើធ្លាក់ !

-នៅតែការដដែល ! ឬមួយអូនមានឯណាឯណីទៅហើយ !

នារតីក្តិចខ្នងសង្វាខ្លាំងជាងមុនទាល់តែគីរីវុធស្រែកអែយ៉ូយ ដោយក្តីឈឺចាប់ ទើបនាងព្រមាន :

-ក្រោយៗ កុំមាត់ដាចពេក ! អូនគ្មានឯណាឯណីទេណាំ !

រាល់ថ្ងៃរង់ចាំតែបងមួយប៉ុណ្ណោះ មានតែបងទេដែលឥតគិតដល់ចំប៉ីសៀមរាបបន្តិចសោះ ព្រោះបងជាហង្សក្រុងភ្នំពេញមែនទេ?

-យី ! អូននារតី ចេះពាក្យលេបខាយពីរោះណាស់តើ ! អូនរៀនពីគ្រូណា ? បង្រៀនបងផងបានទេ !

នារតី គក់ខ្នងសង្សាដោយឃ្នាន់ខ្នាញ់ :

-ស្អប់បងឯងណាស់ ! ចូលចិត្តឡកឡើយអោយអូន !

-អូនស្អប់បងណាស់ ! តែបងស្រឡាញ់អូនណាស់ !

-ពាក្យទាំងនេះផុតចេញពីបបូរមាត់របស់បង ដោយមានអណ្ដាតជាអ្នកក្រលាស់ ឯចិត្តរបស់បងវិញអូនឥតទាន់បានឃើញទេ !

-អូនចង់ចោទថា អណ្ដាតអត់ឆ្អឹងចេះតែក្រលាស់ឬ !

-អូនមិនហ៊ានថាទេ ! ស្រេចតែបងយល់ឃើញទៅចុះ !

សូរស័ព្ទសារសងចេះតែបន្តគ្នារដឹកឥតដាច់ មិនខុសពីទឹកស្ទឹងដែលចេះតែហូរ ... ហូរ ... ជានិច្ចកាលនោះទេ ។

ម៉ូតូបោលទៅមុខតិចៗ ហើយចេញផុតពីផ្លូវចាក់ថ្មកៅស៊ូចូលដល់ផ្លូវដីដែលមានព្រៃល្បាតលោតសន្ធឹងតាមបណ្ដោយមាត់ស្ទឹង ។ នារតី កេះខ្នងសង្សា :

-បងកុំទៅឆ្ងាយពេក ! ខ្លាចណាស់ ...!

-ខ្លាចអីអូន ! យើងមានពួកម៉ាកម្នាក់តាមជួយការពារយើងដែរតើ !

-ពួកម៉ាកណា ! " នារតី សួរដោយឆ្ងល់ "

-អូនឯងស្ទាបនៅនឹងចង្កេះបងឃើញហើយ !

នារតី យល់ន័យ នាងស្ទាបចង្កេះសង្សាឃើញវត្ថុយមួយរឹង១ :

-បងយកកាំភ្លើងខ្លីតាមជាប់ខ្លួនឬ ?

-ត្រូវហើយ ! ត្រូវតែអោយមានវាជាប់នឹងខ្លួន ព្រោះមិនមែនគេចូលចិត្តយើងទាំងអស់នោះទេ !

-បងឯងកុំអាងពេក ! ប្រយ័ត្នគេលបពីក្រោយខ្នង បងឯងពូកែដល់ថ្នាក់ណាក៏ហក់មិនផុតដែរណា !

-អូនកុំភ័យ ! មនុស្សយើងមិនមែនស្លឹកដូចដុំដីទេ !

-អូនទុកចិត្តលើសមត្ថភាពបងហើយ តែអូនបារម្ភពីសេចក្តីសុខរបស់បងណាស់ ព្រោះសេចក្តីសុខរបស់បងក៏ជាសេចក្តីសុខរបស់អូនដែរ ...

នារតី ឱបចង្កេះសង្សាដោយភ្ញាក់ផ្អើល ព្រោះមានសំលេង

មួយលាន់ឡើងពីក្នុងព្រៃក្បែរនេះ នាងឱទានដោយតក់ស្លុត

-បង ! ដូចជាមានសំលេងមនុស្ស !

-មែនហើយពិតជាសំលេង យើងទៅមើលអោយជិតបន្តិចណា!

-កុំអីបង ! អូនខ្លាចណាស់ !

-កុំខ្លាច ! មានបងនៅជិតហើយ អូនឯងខ្លាចអី !

គីរីវុធ បញ្ជាយានចុះពីថ្នល់កៅស៊ូ ហើយបរកាត់វាលស្មៅតំរង់ទៅកាន់ប្រភពសំលេងដែលនាយឮសូរចំឡែកអំបាញ់មិញ ។

ពេលនោះសំលេងដដែលឮតិចៗ :

-ជួយ ... អី ...លែង ...

សូរសំលេងពិតជាហៅរកជំនួយ តែត្រូវគេបង្ខំបង្ខំ ទើបសំលេងឮមិនច្បាស់ ។ គីរីវុធ ត្រូវបញ្ឈប់ម៉ូតូ ព្រោះផ្លូវទៅមុខទៀតលែងរួច ។

-នារតី ! ចាំបងនៅទីនេះហើយណា ! កុំដើររហេតរហូតប្រយ័ត្នគ្រោះថ្នាក់ !

-ចាស់ ! បងឯងក៏ត្រូវប្រយ័ត្នដែរ !

គីរីវុធ រត់ដូចហោះទៅរកកន្លែងដែលសំលេងហើរមក

អម្បាញ់មិញ រីឯនារតី ក៏តាមមើលស្រមោលសង្សារជាប់ទាល់តែបាំងបាត់នឹងគម្លោតព្រៃ ។

នុះ ! នៅពីមុខនាយ លើវាលស្មៅតូចមួយ ហ៊ុំព័ទ្ធដោយព្រៃស្បាត បុរសបីនាក់កំពុងចាប់ផ្ដួលនារីម្នាក់ ។ អាពីរនាក់ចាប់ដៃរបស់នាងជាប់ឥតអោយនាងរើរួចឡើយ រីឯអាម្នាក់ទៀតទ្រោបពីលើនាងហាក់ដូចជាកាយវិការប្រុងរំលោភលើសេចក្ដីបរិសុទ្ធរបស់នារីរងគ្រោះ ។

គីរីវុធ ចោលភ្នែកពីចំងាយ នាយឃើញប្រាណរបស់នារីរងគ្រោះត្រូវអាក្រាត ប្រាកដជាពួកពាលទាំងបីបកសំលៀកបំពាក់នាងហើយ ។ រីឯកាយវិការរបស់អាពាលពីរនាក់ដែលចាប់ដៃនាងនោះក៏ពុំគួរមើលទៀត ដៃម្ខាងវាចាប់ដៃនាងផ្ទាច់ទៅដី មិនអោយនាងរើរួច រីឯដៃម្ខាងរបស់វា វាច្របាច់សុដន់របស់នាងលេងជាល្បែង បណ្ដាលអោយនារីអភ័ព្វស្រៀវស្រើបរមួលខ្លួន ។

ឯអាមួយពីលើវិញ វាចាប់កន្ទែកជើងនាងប្រុងនឹងរំលោភទៅហើយ ... ។

នារីរងគ្រោះប្រហែលជាភ័យពេក បានជានាងគ្មានកំលាំងរើបំរះ ឬក៏រើមិនរួចតែម្ដង ព្រោះដៃជើងរបស់នាងត្រូវគេចាប់

ផាប់ទៅហើយ ម្ល៉ោះហើយនាងធ្មេចភ្នែកហាក់រងចាំទទួលផល កម្មដែលនឹងធ្លាក់មកដល់ខ្លួននាងនៅពេលនោះ ។

រីឯពួកអាល្មោភកាមទាំងបី វាយល់ថាបំណងរបស់វាបាន សំរេចហើយនោះ វាកំពុងតែត្រជរឈាមស្រម៉យឃើញថាឋានសួគ៌ លោកកិយដែលពួកវានឹងទៅដល់នៅពេលបន្តិចទៀតនេះ ។

តែនៅពេលដែលវាហៀបនឹងរុញទូកអូសកាត់ត្រើយ មហា ស្រណុកទៅហើយនោះស្រាប់តែ :

_ផាំង !

អាទ្រោបពីលើនារីរងគ្រោះ ងើក្បាលដូចជ្រូកត្រូវព្រនង់ ព្រោះទម្ងន់ជើងរបស់គីរីវុធបានស្វាគមន៍កណ្ដាលក្បាលរបស់វា ធ្វើអោយវាជ្រមុជក្បាលខ្វូចស្ថានភាពចូលលុក ហើយដួលទៅលើ ដី ។

អាពីរនាក់ទៀតហាក់ដូចជាស្លន់ មួយសន្ទុះធំទើបងើប មុខមកវិញរកស្មៀតតដៃ ។

តែហួសពេលទៅហើយ គីរីវុធ ដែលបានប្រុងប្រៀបជា មុននោះមិនចាំអោយវាសងទាន់ឡើយ ។ នាយហក់មកពីចំងាយ ហើយកណ្ដាប់ដៃរបស់នាយបានទៅស្វាគមន៍កញ្ចប់មាត់វាលាន់ ភឹង

... អានោះវិលមួយជុំទើបឈប់នឹង ។

នារីវង់គ្រោះស្ទើរមិនជឿភ្នែកខ្លួនឯង ថាមានទេវតាមកជួយទាន់ឡើយ នាងស្រវេស្រវ៉ារកសំពត់អាវដែលពួកអាពាលប្រស្រាតពីនាង ហើយចោលក្បែរនោះមកស្លៀកពាក់យ៉ាងប្រញាប់ ។

គីរីវុធ ឈរបង់ជំទែង ពោលទៅកាន់នារីវង់គ្រោះ :

-នាងឆាប់រត់ចេញពីទីនេះភ្លាម !

មិនចាំបាច់តឿនជាលើកទីពីរឡើយ នាងច្រកអាវសំពត់រួចក៏រត់ត្រុយលែងងាកក្រោយ ។

អាមួយដែលមិនទាន់ត្រូវអីនឹងគេ បានរត់ទៅតាមប្រាថ្នាចាប់នារីនោះមកវិញ តែ ...

គីរីវុធ រត់ទៅឈរពាំងពីមុខវាជាប់ :

-បើអាឯងចង់ចាប់នាង ! ចាំកន្ទួងខ្មោចអញសិន !

អានោះខាំមាត់ :

-អាភ្លើនេះមិនចេះភ្លក់ភ្លាមែន ! បើវាចង់ស៊ីផងមានអីសុំតាមសំរួលមិនបានឬ ? ម៉េចចាំធ្វើភ្លូត១ យ៉ាងនេះពិតជាឥតស្គាល់ស្លាប់មែនអាឯង !

-ប្រសើរណាស់ ! អញចង់ស្លាប់ចាំមើលតើអាឯងធ្វើអោយ

អញងាប់តាមរបៀបណា !

-ហាស់ៗ "វាសើចយ៉ាងរលាត់" មានអី ! អាឯងស្មានថា អញញញើតឬ ?

ពេលចប់វាហូតយកកូនកាំបិតកែមួយពីចង្កេះរបស់វា ហើយរលាស់បញ្ចេញផ្លែស្រួចរលែបជ្រលមកមុខគីរវុធ ។

គីរវុធ ឥតព្រឺទៀយ នាយស្ទាបកាំភ្លើងនៅចង្កេះ តែមិនទាន់ដល់ពេលប្រើវានៅឡើយទេ គេមិនដែលយកកាំបិតតាំងតោទៅធ្វើត្រឹចង្ការឡើយ ។ នាយនឹកក្នុងចិត្តហើយ ប្រុងខ្លួនតាមមើលសកម្មភាពរបស់ពួកវា ។

អាពីរនាក់ទៀត ក្រោយពីបាត់ស្រងល់បន្តិច ក៏ខាំមាត់ប្តូងដៃចូលដោយក្តៅក្រហាយណាស់ដែរ :

-ហ៊ឹស ! អាចោរព្រៃ ! ធ្វើអោយបាត់ចំណីឆ្ងាញ់អញអស់ ! គួរតែសំលាប់ចោល ហើយទំលាក់ទឹកស្ទឹងទើបត្រូវ !

អាពីរនាក់ដែនទេ ចូលពីក្រោយដោយប្រុងប្រយ័ត្នព្រោះវាយល់ថា គីរវុធ មិនមែនជាជនធម្មតាដែរ

ពេញជាអង្គប្រុស គីរវុធ ឥតព្រឺប៉ុនក្រចកដៃឡើយ នាយឈរយ៉ាងសង្ហារ រំភើយ ហើយញាក់ជើងហួចតិចៗ ដូចគ្មានរឿង

អ្វីសោះ តែភ្នែកសំលឹងចំអាកាន់កាំបិតពីមុខនាយ ។

ពន្លឺថ្ងៃបណ្តើរកូនចាំងព្រិចៗ បង្ហាញស្រមោលអ្នកទាំងបួនលើស្មៅយ៉ាងច្បាស់ ។ ខ្យល់បក់អ្វិៗ ហាក់ដូចជាទំនួញខ្មោចទារព្រលឹង ។

គីរីវុធញោចស្មានៅពេលដែលកាំបិតរបស់ជនពាលហើរមកពីចំងាយ ។ នាយបន្ទន់ខ្លួនងាកគេចយ៉ាងងាយ ហើយក្រឡាស់ខ្លួនទៅម្ខាង ព្រោះអាម្នាក់ទៀតហក់ធាក់ពីចំងាយដែរ ។ នេះជាស្នៀតទាត់មួយក្នុងក្បួនការ៉ាតេ គីរីវុធ ស្គាល់យ៉ាងច្បាស់ ។ បានន័យថាពួកបីនាក់នេះមិនមែនជាអ្នកចេះស្នៀតដូនតាដូចពួកអាបីនាក់ពីថ្ងៃមុននោះទ្បើយ នាយគេចទៅម្ខាង ហើយចាំអោយវាទំលាក់ជើងមកវិញទើបនាយបញ្ជូនកណ្តាប់ដៃសងវាវិញរឹបៗ និងឆ្វៀតងាកមកទល់ជាមួយអាទីបី ដែលហក់មកជាបន្តដែរ ។

ក្បាច់ប្រដាល់របស់ គីរីវុធ មានភាពស្វាហាប់ និងរហ័សក្រៃលែង បង្កើតជារង្វង់ហ៊ុំព័ទ្ធខ្លួននាយជុំទិស តែនាយមិនទាន់ច្បាស់ថាអាចទប់នឹងកាំបិតនៅទ្បើយទេ ។

អាកាន់កាំបិតស្រែក " តាម " ហើយហក់ធ្លោ មកដោយគំរង់ផ្លែកាំបិត រកដើមទ្រូងនាយនោះបង្ខំឱ្យគីរីវុធគេចយ៉ាងរហ័ស

ស្ទើរមិនទាន់ តែរំពេចនោះទំងន់ជើងរបស់ជនទីពីរក៏ហើយមកដល់ល្មម ។ គីរីវុធ មិនតក់ស្លុត នាយមិនគេចទេ ដោយកំលាំងជើងដ៏ខ្លាំងក្លារបស់នាយ នាយហក់ឡើងលើហើយទាត់តំរង់ស្នងជើងរបស់វា ។

ស្នូរភឹង លាន់ឡើង អានោះស្រែក " អួយ " ជាមួយនឹងផងខ្លួនរបស់វាដួលគ្រឹបលើដី វាចុកចាប់យ៉ាងខ្លាំង ។

គីរីវុធ ប្រុងហក់ទៅបង្ហើយវាដែរ តែអាទីបីហក់ឆាល់មកទៀត អានេះមិនស្លូវទាត់ទេ វាចេះតែដាល់ ពិតជាចេះស្នៀតតែក្វាន់ម្ហូរសម ។

គីរីវុធ ឥតញញើត ទទួលយកកញ្ចប់ដៃរបស់វា

" ភឹង"

នាយចុកអួលត្រង់ស្មា តែកំលាំងដៃរបស់អានេះមិនសូវជាពូកែដែរ ។ ភ្លាមនោះនាយស្រែក " ចាច " សំលុតស្មារតីសត្រូវហើយបញ្ចេញស្នៀតពិសេសយ៉ាងខ្លាំងក្លាវាយសំរុកចូលធ្វើអោយវាថយក្រោយៗ យ៉ាងលឿនបំផុត ។

នៅពេលជនកាន់កាំបិតលបលួចចាក់ឆ្មក់ពីក្រោយ គីរីវុធវៀចខ្លួនបន្តិចគេចផុតយ៉ាងប៉ិនប្រសប់ ហើយរហ័សស្ទើស្នូររន្ទះ

នាយចាប់កដៃវាជាប់ មួលទៅក្រោយ ។

អានេះភ្ញាក់ខ្លួនយល់ថាលង់ទ្រនេស តែជ្រុលពេលទៅហើយ ក្បាលជង្គង់របស់គិរីវុធ លើកឡើងហើយអុកកណ្ដាលទ្រូងវាភឹង អានោះលាន់មាត់ " អិក " ... ឈាមមួយដុំធ្លាក់ចេញពីមាត់វា គិរីវុធ ឆក់មួយដៃទៀត ភឹង អានោះដួលស្រុញលើដី របូតកាំបិតពីដៃ ហើយសន្លប់ស្ដូកស្ដឹង ។

នៅសល់ម្នាក់ទៀត ស្មានស្មានការណ៍ដឹងស្រេចថាមិនអាចយកជ័យលើគិរីវុធបានឡើយ វាដកឃ្លាប្រុងរកច្រក តែ :

-អាភ្លើ ! មិនអាចចេញពីទីនេះបានទេ ! បើមិនជឿសាកមើល!

មាត់ពោលតែនាយបានរើសកាំបិតកៃរបស់ពួកវា ហើយបោះត្រេះលេង :

-បើអាឯងហ៊ានរត់ចេញពីទីនេះ កូនកាំបិតនេះនឹងចូលទៅស៊ុឆ្អឹងភ្លៅអាឯង ... អាឯងសាកលមើល !

ឆ្កែដែលត្រូវគេវាយហើយវាមិនព្រមទៅអោយគេវាយថែមទៀតឡើយ យ៉ាងណាមិញជនពាលទាល់ច្រកនេះក៏ដូច្នេះដែរ ទោះនាយគំរាមយ៉ាងណាក៏ដោយ វាមិនព្រមស្ដាប់ដែរ វានៅតែរត់ត្រឹងឥតងាកក្រោយ ... តែ ... វីវ ...។

-អូយ !

វាដួលប្រួសលើដី ដោយកាំបិតកែបានហើរចេញពីដៃរបស់គីរីវុធ ហើយទំលើភ្លៅរបស់វាមែន ។ ឈាមហូរហាមប្រទ្បាក់ពេញវាលស្មៅ គីរីវុធ ដើរទៅជិតវា :

-យ៉ាងម៉េច អាឯងជឿអញទេ អញថាកុំអោយរត់អាឯងមិនជឿ! អាឯងនៅចាំទីនេះហើយ !

បន្ទាប់មក គីរីវុធ បែរទៅម្ខាង នាយដកពីហោប៉ៅនូវរបស់មួយមានរាងដូចដែកកេះ ហើយចុចគន្លឹះរបស់វា

ភ្លើងក្រហមបង្ហាញសញ្ញាភ្លែត១ ជាមួយនឹងសំលេងទីត១១ ... ពិតជារបស់វិទ្យាសាស្ត្រដ៏ទំនើប គីរីវុធនិយាយ :

-ទីនេះ ក០០៥ សូមឡានមួយមកដឹកជនទុច្ចរិត ។ បីគីឡូម៉ែត្រខាងជើងក្រុង និងមួយរយម៉ែត្រខាងកើតមាត់ស្ទឹង ។

និយាយចប់នាយបិទគន្លឹះ ... ភ្លើងរលត់ គីរីវុធ ច្រកវត្ថុនោះក្នុងហោប៉ៅវិញ ហើយស្រែកហៅសង្សា :

-នារតី ! អូននារតី !

សំលេងខ្ទរព្រៃត្រឡប់មកវិញ បន្តិចក្រោយមកនារតី និងពៅរងគ្រោះអម្បាញ់មិញរត់មកដល់ :

-បងវុធ ! អូនបារម្ភចំពោះបងណាស់ !

គីរីវុធ ញញឹម :

-អត់អីទេ ! អូនកុំភ័យ ... ចុះអ្នកនាងខាងណោះឥតអីទេ ?

នារីរងគ្រោះអៀនមុខក្រហម ព្រោះអម្បាញ់មិញ គីរីវុធពិតជាបានឃើញអាថ៌កំបាំងនៃរាងកាយនាង នាងស្រក់ទឹកភ្នែកដោយអាណិតខ្លួន និយាយស្ទើរមិនចេញសំលេង :

-ចាស់ ! ឥតអីទេលោក !

-បងអ្នា ! នាងក៏ជាសិស្សនារីនៅក្នុងវិទ្យាល័យសៀមរាបដែរណា ! ខ្ញុំធ្លាប់ឃើញជាញឹកញាប់ តែនាងឥតដែលស្គាល់ខ្ញុំទេ ព្រោះនាងរៀនទាបជាងខ្ញុំមួយថ្នាក់ :

-អីចឹងឬ ? រួចរឿងហេតុយ៉ាងណាបានជានាងត្រូវរងគ្រោះមកដល់ទីនេះ ?

នារីរងគ្រោះគិតតែយំ នាងឥតឆ្លើយថាម៉េចទេ ។

សំលេងរថយន្តកាត់ផ្តាច់ការសន្ទនា :

-យី ! ឡានអីទៅបង ?

គីរីវុធ សំលឹងទៅពួកយុវកូងទាំងបីដែលនៅស្តូកស្តឹងលើដី

-ឡានមកដឹកពួកអាកូនឆ្កែទាំងបីនេះទៅដាក់ទ្រុង !

រំពេចនោះរថយន្តហ្ស៊ីបមួយគ្រឿងបើកយ៉ាងលឿនតំរង់មកហើយឈប់ ។ ភ្នាក់ងារពីរនាក់ចុះពីឡានដើរតំរង់មក ។

គីរីវុធ ដកកាបូបពីហោប៉ៅខោ ហើយហុចអោយភ្នាក់ងារម្នាក់ ។

ក្រោយពីមើលរួច ភ្នាក់ងារនោះគំនាប់ផ្លូវ ដោយគោរព

-សូមគោរព !

គីរីវុធ គោរពតបវិញ :

-បានហើយ ! នាំខ្លួនវាបីនាក់នេះទៅបញ្ចូលគ្រុំងសិនទៅ !

-លោកអត់អញ្ជើញទៅ ស្នងការដ្ឋានទេឬ ?

-មិនទាន់ទៅទេ ! ព្រោះនៅមានការច្រើនតទៅទៀត ! ផ្តាំទៅសួរសុខទុក្ខលោកមេបញ្ជាការផង !

-បាទ ! គោរពលា !

ភ្នាក់ងារ គោរពលា ហើយបែរខ្នងលើកពួកពាលទាំងបីបញ្ចូលក្នុងរថយន្ត ទើបបើកចេញពីទីនោះជាបន្ទាន់ ។

ភ្នាក់ងារចេញផុតអស់ទៅ គីរីវុធងាកមកមើលនារតី និងតារ៉ាងគ្រោះដែលធ្វើភ្នែកស្លឺ ព្រោះឆ្ងល់នឹងគីរីវុធ ដែលមានពួកពិញសិងាត់គោរពហ្មត់ចត់យ៉ាងនេះ ។

-នាងឆ្ងល់ណាស់មែនទេ ។ កុំឆ្ងល់អី ហើយខ្ញុំសង្ឃឹមថា នាងនឹងមិននិយាយរឿងនេះអោយគេដឹងតទៀតឡើយ !

-ចាស់ សូមលោកទុកចិត្តចុះ ! ខ្ញុំមិននិយាយទៅទៀតទេ ! ហើយខ្ញុំសូមថ្លែងអំណរគុណចំពោះការជួយសង្គ្រោះរបស់លោកដោយមិនដឹងថាបានអីសងគុណលោកវិញទេ !

-ទេ ! ៗ ! ខ្ញុំជួយអ្នកនាងដោយស្មោះ មិនមែនប្រាថ្នាគុណស្រ័យអីទេ ! អត់ទោសអ្នកនាងឈ្មោះអីដែរ !

-ចាស់ ! ខ្ញុំឈ្មោះ រតនា !

នារតី ឃើញគីរវុធ នៅជជែកជាមួយនាងយូរពេក កួនចិត្តមួយផុសឡើង កួនចិត្តចំលែក :

-បង ! យើងទៅវិញ !

-ឈប់សិន ! " គីរវុធ ឃាត់ " ទៅម៉េចកើត ! ចោលអ្នកនាងរតនាឬ ? ត្រូវយកនាងទៅផង !

តើយកទៅម៉េចរួច បើម៉ូតូមួយ គ្នាដល់ទៅបីនាក់ ។

នារតី ទាញដៃគីរវុធ ធ្វើអោយ រតនាហាក់ដូចជាដឹងខ្លួននាងពោលតិចៗ :

-សូមលោកអញ្ជើញទៅចុះ ! ទុកអោយខ្ញុំដើរម្នាក់ឯងហើយ

-មិនកើតទេ ! ៗ ! " គីរីវុធស្រែក " ទុកអ្នកនាងដើរតែឯម្ដេចកើត ! ឥឡូវយើងដើរទាំងអស់គ្នា !

ពោលចប់ គីរីវុធដើរចេញទៅកាន់កន្លែងចតម៉ូតូ ហើយបណ្ដើរចេញទៅដោយ នារតី និងចរនាដើរតាមពីក្រោយផង ។

ចេញពីព្រៃស្បាត អ្នកទាំងបីបានមកដល់ថ្នល់មាត់ស្ទឹង គីរីវុធ សួររចនា :

-អ្នកនាងរចនា ! អ្នកនាងមិនទាន់ប្រាប់ពីរឿងរ៉ាវដែលបណ្ដាលអោយអ្នកនាងរងគ្រោះដោយពួកពាលផង !

រចនា ដើរឈ្ងោកមុខ នាងកេះជាយអាវ និយាយតិចៗស្ទើរស្ដាប់មិនឮ :

-ចាស់ ! ខ្ញុំមកកាន់ភូមិទ្រាំងដើម្បីទន្ទេញមេរៀនក្រោមម្លប់ឈើ ស្រាប់តែអាមួយនោះឈ្មោះ អារ៉ូសា វាធ្លាប់រៀនជាមួយខ្ញុំដើរមកប្រាប់ថា មិត្តនារីខ្ញុំម្នាក់ផ្ដាំអោយទៅជួបដោយមានការចាំបាច់។ខ្ញុំក៏មកតាមវា វាបោកប្រាសដើម្បីធ្វើបាបខ្ញុំសោះ ខ្ញុំក៏មកតាមដោយពុំស្គាល់ផ្លូវ វានាំខ្ញុំទៅកាន់ទីនេះ ។ ពេលចុះពីផ្លូវភ្លាមខ្ញុំភ្ញាក់ព្រើតគិតថា មិនស្រួល តែគ្នាវាម្នាក់បានរត់ចេញពីព្រៃ មកចាប់ខ្ញុំជាប់ហើយបីរត់ចូលព្រៃដោយមានគ្នាវាម្នាក់ទៀត មកប្រវាយចាប់ខ្ញុំយក

ទៅផង ។ រហូតដល់បានលោកមកជួយសង្គ្រោះទាន់កុំអី ខ្ញុំប្រហែលជាត្រូវស្លាប់ក្នុងទឹកស្ទឹងបាត់ទៅ ហើយ !

ពេលអ្នកទាំងបីជជែកគ្នាបណ្តើរ ដើរតាមមាត់ស្ទឹង បណ្តើរ ម៉ូតូមួយបោះពួយយ៉ាងលឿនកាត់តាមនោះ ។

ម្ចាស់បញ្ជាយានជាបុរសម្នាក់អាយុប្រហែលសាមសិបឆ្នាំ ពាក់វ៉ែនតាខ្មៅធំៗ ។

រចនា ប្រាប់គិរីវុធ :

-គាត់នេះជាម្ចាស់បាររមនោរម្យ ! វាមានសំបើមណាស់ នៅក្នុងបាររបស់វាស្រីផុនណាក៏មានដែរ !

គិរីវុធ ងាកមើលមុខ រចនាដោយឆ្ងល់ក្រៃលែង ។ វន្ទះគំនិតមួយនាំអោយនាយពិចារណា :

-ចរនា ជាស្រីក្រមុំ កូនគេអ្នកមានពូជអំបូរត្រឹមត្រូវ ចុះហេតុដូចម្តេចក៏នាងស្គាល់បារនោះម្ល៉េះ ?

រចនា ហាក់ដូចជាយល់ចិត្តរបស់ គិរីវុធ នាងប្រាប់ថា :

-លោកប្រហែលជាឆ្ងល់ថា ម៉េចបានជាខ្ញុំដឹងរឿងរបស់បាមនោរម្យច្រើនម្ល៉េះមែនទេ ? សូមលោកកុំឆ្ងល់ គឺបងប្រុសរបស់ខ្ញុំជាអ្នកនិយាយ ព្រោះគាត់ចេញចូលបារនេះរាល់ថ្ងៃ ព្រោះបងខ្ញុំ

ជាអ្នកខិលខូចលេខមួយ !

-បងអ្នកនាងឈ្មោះអីដែរ ?

-ចាំះ គាត់ឈ្មោះ អសនី !

-អសនី ! ឈ្មោះនេះសាហាវណាស់តើ !

នារតី ស្ងៀមស្ងាត់យូរហើយ ក៏លាន់មាត់ :

-អសនី ! រៀនជាមួយខ្ញុំដែរ តើ !

-ចាំះ ! បងអសនីតែនិយាយពីអ្នកនាងនារតីប្រាប់ខ្ញុំញឹកញាប់ណាស់ ! គាត់សរសើរថាអ្នកបងរៀនពូកែទៀតផង !

នារតីញញឹម នេះជារឿងធម្មតារបស់មនុស្សស្រី បើមានគេនិយាយបញ្ជោរ ។

ដល់ផ្លូវធំទើប រចនាប្រាប់គីរីវុធ :

-ខ្ញុំសូមលាលោក និងអ្នកបងសិនហើយ ! នុះរ៉ឺម៉ក ! ខ្ញុំជិះរ៉ឺម៉កទៅក៏បានដែរ !

-អូ ! ប្រសើរណាស់ ! អ្នកនាងអាចជិះរ៉ឺម៉កបាន អេរ៉ឺម៉ក !មកណេះ !

ពូ រ៉ឺម៉ក ឮសួរសំលេងហៅក៏បត់ក្បាលមករក

-អញ្ជើញទៅណាទាន !

-ខាងកើតបេនទ្បាន ពួយកប៉ុន្មាន ?

-បានមួយរយរៀន !

រចនា ឡើងលើរ៉ុម៉ក នាងងាកមកញញឹមដាក់គីរីវុធ :

-សូមលាលោក និងអ្នកបងហើយ ! បើមានពេលទំនេរ សូមលោកទៅលេងនឹងខ្ញុំកុំខានណា !

-សូមអ្នកនាងអញ្ជើញ ! មិនអីទេ ថ្ងៃណាមានពេលទំនេរខ្ញុំនាំអូននារតីទៅលេងជាមួយនាងមិនខាន !

រចនាញញឹមជាចុងក្រោយហើយ រ៉ុម៉កក៏នាំខ្លួននាងចេញបាត់ទៅ :

-ទៅយើងទៅរកញ៉ាំអីសិន ថ្ងៃបែរទៅហើយ !

គីរីវុធបញ្ឆាម៉ូតូ ។ នារតី ពោលរង៉ូវ :

-ហ៊ឺះ ! ឃើញគេញញឹមដាក់ មើលគេស្ទើរបាក់ក

គីរីវុធ ញញឹមងាកមកសើចដាក់សង្សា :

-ម្ចាស់ថ្លៃអើយ ! អូនមិនអោយបងញញឹម តើអោយយំឬ ?

នារតីក្ដិចពោះសង្សារដោយឃ្នាន់ឃ្នាញ :

-គ្មានអ្នកណាអោយបងឯងយំទេ តែកុំស្ទូវស្ទីដាក់គេពេក ! បងឯងនេះ ចិត្តដូចចុងស្រល់អីចឹង !

គីរីវុធ អស់ពីគិតទៅជាសើច :

-ម្ចាស់ថ្លៃអើយ ! អូនឯងប្រច័ណ្ឌមែនទែនហើយហ្នឹង ! ចុង ស្រល់តែកាលណាអស់ខ្យល់វាលឈរត្រង់ភ្លឹង ឥតរៀចទេ !

-បានហើយៗ ! អូនមិនខ្ចីប្រច័ណ្ឌទេ ! ស្រេចតែបងឯងចុះ ព្រោះយើងមិនទាន់រៀបការឯណា !

គីរីវុធ សើចហើយគ្រវីក្បាលដោយហួសចិត្ត បន្ទាប់មកក៏ បញ្ឆេះម៉ូតូចាកចេញពីទីនោះភ្លាម ។

ជិតចេញផ្សាយទៀតហើយ !!

រឿង "**តាមរកមាឌម្ចាស**" របស់អ្នកនិពន្ធដដែល ជា ប្រលោមលោកបែបមនោសញ្ចេតនា និងស៊ើបអង្កេត ពាក់ឡាងទស្សវត្ស៧០ ពីបណ្ណាគារ "**អង្គរធំ**" ធានាថាពិតជាល្អ ពិតជាពីរោះរណ្តំក្នុងដួងចិត្តលោក-អ្នកអានគ្រប់ៗរូបពុំខាន !!!

~៣~

សំលេងយានរលត់ តូម៉ូតូឈប់ងក់ពីមុខស្នងការសំងាត់ ផ្នែកស៊ើបការអង្កេត ។ បុរសម្នាក់ចុះពីម៉ូតូដើរតំរង់ទៅរកទ្វារ ការិយាល័យ គេមានមាឌមាំធំដំបង មុខគេលំអដោយវ៉ែនតាធំៗ គ្មាននរណាក្រៅពីគីរីវុធឡើយ ។

អ្នកយាមឈរត្រង់ខ្លួនសួរ :

-អត់ទោស ! សូមមើលកាតទាន !

គីរីវុធ មិនដោះវ៉ែនតាចេញទេ នាយលូកហោប៉ៅដកកាត ហុចអោយ ។

មើលរួចអ្នកយាមគោះកែងហើយគំនាប់ :

-សូមគោរព ! លោកអញ្ជើញរកអ្នកណា ?

-លោក មេបញ្ជាការនៅទេ ?

-បាទ ! នៅខាងក្នុង ! សូមលោកអញ្ជើញចូល !

គីរីវុធ ដោះជំហានយ៉ាងសង្ហារ ឆ្លងផុតអាគារមួយទើបមក ដល់ការិយាល័យស៊ើបអង្កេត នាយគោះទ្វារ :

-តុក ! តុក ! ៗ !

-ចូលមក ! " សំលេងពីក្នុង "

នាយច្រានទ្វារចូល បុរសចំណាស់ម្នាក់មានក្បាលត្រងោល ពាក់វ៉ែនតា ស មនុស្សចាស់សំលឹងមករក នាយកគោះជើង គោរព។

ជននោះចង្អុលកៅអី :

-សូមលោកអញ្ជើញអង្គុយ !

គីរីវុធ អង្គុយចុះ នាយដកកាតហុចទៅជនចំណាស់តែ ជននោះគ្រវីក្បាល :

-មិនបាច់ទេ ! ខ្ញុំស្គាល់ហើយ ! លោក ក០០៥ តើលោកមក ដល់សៀមរាបពីថ្ងៃណា ?

-ម្សិលម៉្ងៃ !

-ខ្ញុំបានទទួលទូរលេខសំងាត់ពីភ្នំពេញប្រាប់ថា លោកនឹង អញ្ជើញមកជួយស៊ើបពីអាថ៌កំបាំងនៃឃាតកម្មមួយនៅក្បែរអង្គរ តែតាំងពីនោះមកឥតឃើញលោកមកសោះ !

-ខ្ញុំមកដល់ដោយឥតចង់អោយគេភ្ញាក់ផ្អើលឡើយ ខ្ញុំបានទៅ កាន់ភូមិប្រណាំងសេះ ហើយជួបពួកអ្នកលេងបីនាក់លើខ្នងទំនប់ ពារាយណ៍ ខ្ញុំបានជួបនឹងឃាតកម្មមួយនៅភូមិត្រពាំងសេះ និង

មិវៀលមិញនេះ បានបញ្ជូនអាយុក្នុងបីនាក់អោយលោក ។ ការ ដែលខ្ញុំធ្វើយ៉ាងនេះ ដោយមានបំណងតាមដានមើលសកម្មភាព របស់ឃាតក ដោយមិនចង់អោយគេដឹងថា ខ្ញុំមកដល់សៀមរាប

-ឥឡូវនេះ លោកត្រូវការអ្វីទៀត ?

-គ្មានទេ ! តែខ្ញុំចង់មើលឯកសារ និងរូបថតដែលគេធ្វើឃាត រូបអ៊ំយន់ !

-បាន ! ៗ ! សូមលោកចាំបន្តិច !

ជនចំណាស់ជាមេបញ្ជាការ បានក្រោកពីតុរបស់ខ្លួនហើយ ចាក់សោរទូរបើកវើសំណុំរឿងមួយចំពួសចេញមកដាក់លើតុ ។

-សូមលោកមើលចុះត្រូវការណាមួយ !

គីរីវុធ ឬភ្នាក់ងារ ក០០៥ រើរូបថតជាច្រើនមកមើល ក្នុង នោះរូបសាកសពបុរសចំណាស់ដេកស្លាប់ក្នុងថ្លុកឈាមដោយ មានកាំបិតស្នៀតដោតលើខ្នងមួយ ។

បន្ទាប់មកគឺរូបអ៊ុំ ចាន់ ដែលបានឃើញខ្មោចអ៊ុំ យន់ មុន គេ ។ រូបនាង យ៉ានី អ៊ំ សែម ដែលជាគ្រួសាររបស់ជនរងគ្រោះ។

បន្ទាប់មកនាយបានអានឯកសារដែលកត់ត្រាពីចំលើយ របស់អ៊ំ ចាន់ នាងយ៉ានី និងម្តាយ តែទាំងអស់នេះមិនអាចជាពន្លឺ

ក្នុងការស្រាវជ្រាវរកឃាតករសោហ ។

គីរីវុធ ដកដង្ហើមធំ ទំលាក់រូបថតទាំងនោះលើតុវិញ :

-ដូចជាយកជាការមិនបានសោះ ! លោកមេបញ្ជាការមែន ទេ?

-ហ្នឹងហើយ ! ឯកសារទាំងអស់នេះមិនអាចគ្រប់គ្រាន់អោយយើងស្រាវជ្រាវរកឃាតករឃើញទេ ! ដោយហេតុហ្នឹងម៉្យាងនិងម៉្យាងទៀត នៅទីនេះរកអ្នកជំនាញខាងស៊ើបអង្កេតគ្មានទេ ទើបខ្ញុំបញ្ជូនរបាយការណ៍ទៅសុំជំនួយពីភ្នំពេញ ។

គីរីវុធ ផ្អែកលើកៅអីទំរ៉េត ដកបារី ប្រាំរយហាសិបប្រាំមួយដើមមកអុជជក់បង្ហុយផ្សែងទៅលើដោយជញ្ជីងគិតមួយសន្ទុះ ទើបសួរថា :

-ក្រោយពីឃាតកម្មលើរូបអ៊ំ ចាន់ តើមានប្រតិកម្មអីចំលែក ទេ!

-តាមភ្នាក់ងារដែលបានស៊ើបនៅទីនោះបានអោយដឹងថា អ៊ំ ចាន់ ប្រហែលជាមានចូលរួមក្នុងរឿងឃាតកម្មនេះ ក្រោយមកដោយហេតុខ្លាចគាត់ធ្វើអោយបែកការ បក្សពួករបស់ពួកគាត់ក៏បបលួចសំលាប់គាត់បន្ថែមទៀត !

-លោកមានសង្ស័យថា ហេតុដូចម្តេចបានជាគេចលួចសំលាប់អ៊ំយន់ទេ ?

-ភ្នាក់ងាររបស់ខ្ញុំយល់ថា នេះជារឿងគំនុំផ្ទាល់ខ្លួន ឬក៏ជម្លោះរវាង អ៊ំ យន់ និងអ្នកភូមិ !

-មិនមែនទេ !

-ម៉េចក៏លោកហ៊ានអាកាត់មុតមាំយ៉ាងហ្នឹង !

គីរីវុធ យកដៃទល់វ៉ែនតាបន្តិច ទើបពោលមួយៗ :

-តាមសំដីរបស់នាងយ៉ានី កូនស្រីអ៊ំយន់ប្រាប់ខ្ញុំថា ឪពុកនាងទៅចំការ គឺដើម្បីគាស់គល់ដង្គត់ឈើដែលរំខានដល់ការធ្វើចំការ ក្រោយពីឃាតកម្មលើរូបឪពុកនាងហើយ នាងបានរកឃើញកំទេចត្បូងមួយដុំ នៅក្នុងរណ្ដៅដែលឪពុកនាងកាយត្បូងនោះ នាងយកទៅលក់បានបីពាន់រៀលទៀតផង ! ...

-បើអ៊ីចឹងលោកយល់ថា អ៊ំយន់ច្បាស់ជាគាស់បានកំណប់ហើយត្រូវជនមិនស្គាល់ឃើញរួចលួចសំលាប់គាត់ដណ្ដើមយក ដោយមានសល់ត្បូងជាភស្តុតាងមែនទេ !

-ពិតជាអ៊ីចឹងហើយ !

-រឿងនេះ ! កាលភ្នាក់ងាររបស់យើងទៅកត់ហេតុ យើងឥតបានទទួលដំណឹងនេះទេ !

-រឿងហ្នឹងហើយដែលខ្ញុំមកពីភ្នំពេញ មិនមកជួបលោកភ្លាម

ព្រោះខ្ញុំត្រូវការពត៌មានបន្ថែមពីលើការការកត់ត្រារបស់លោក !

-ខ្ញុំសូមសរសើរចំពោះការឈ្លាសវៃរបស់លោក ! ឥឡូវលោកត្រូវការភ្នាក់ងារជំនួយទេ ?

-ត្រូវការដែរ តែដោយសំងាត់ !

-ប៉ុន្មាននាក់ ?

-ម្នាក់ពីរបានហើយ ! អស់ការខ្ញុំលាសិនហើយ !

-សូមអញ្ជើញអោយបានជោគជ័យ !

គីរីវុធ ញញឹមចាប់ដៃលោកមេបញ្ជាការលាក់ ហើយបង្វិលខ្លួនចាកចេញពីទីនោះជាបន្ទាន់ ។

នៅលើម៉ូតូ នាយនឹកឃើញដល់ភារកិច្ចរបស់ខ្លួន :

-ភារកិច្ចមិនមែនជារឿងងាយស្រួលទេវើយ តែប្រហែលខ្លួនបង្អិចព្យាតនឹងផ្ដុំខ្លួយកំជរព្រលឹងរបស់នាយភ្លាម ហើយគ្មានអ្នកណាយំស្ដាយនាយដែរ ! មានតែនារីមួយប៉ុណ្ណោះ ។

បារមនោរម្យជាកូនរង្គសាលមួយទើបនឹងចាប់កំណើតថ្មីៗនេះ នៅទីរួមខេត្តសៀមរាប ។

ទីនេះគឺជាកន្លែងប្រមូលផ្ដុំនៃអ្នកមានលុយសន្ធឹកសន្ធាប់ដែលចាយមិនអស់ ហើយដែលជីវិតនៅលើលោកិយរបស់គេជួប

ការអផ្សុក ដូច្នេះបារនេះជាកន្លែងរកអោយគេនូវស្ថានសួគ៌ក្លែងក្លាយកាយមួយ លើស្ថាននរករបស់អ្នកក្រ ។

ម៉ោងប្រាំមួយល្ងាច ពេលស្មើនេះចាត់ទុកជាពេលសំរាករបស់អស់ពួកសេដ្ឋី ដែលរស់ដោយឧត្តុង្គឧត្តម្ភលើគំនរញើសឈាមរបស់អ្នកក្រីក្រ ដែលស្មើនេះនៅកំពុងបង្ហូរញើសឈាមក្នុងពលកម្មនៅឡើយ ។

រថយន្ត និងទោចក្រយានយន្តបានមកចំពីមុខ បារមនោរម្យហើយ ថៅកែដុះពោះស្មុយៗ បោះជំហានចូលបារយ៉ាងរីក រាយ ។

ស្នូរតូរ្យតន្ត្រីប្រគំរងំ សណ្តំព្រលឹងភ្ញៀវទាំងឡាយអោយលង់លក់ទៅកាន់ឋានពិសេសមួយដែលអ្នកក្រមិនដែលស្គាល់ ។

នៅក្បែរគេ នារីរូបស្អាតស្រស់ឆើតឆាយកំពុងបំរើភ្ញៀវ ។

នៅជ្រុងខាងកើតនៃបារ តុមួយមានបុរសពីរនាក់កំពុងប្រកៀកប្រអោបនារីក្នុងរង្វង់ដៃរបស់ខ្លួន ៈ

-អាស្រី ! ចាក់ស្រាអោយបងអូន !

ជននោះស្រវឹងជោកទៅហើយ តែដៃរបស់វាឥតបេះពីនារីឡើយ ហើយម្រាមដៃរបស់វាបានជ្រលួសទៅលូករាវផ្ទៃទំលាប់របស់នាងផ្កាមាសជារឿយៗ តែនាងគៀសចេញ ៈ

-ដឹងស្អីទេ ! កណ្ដាលវាលអីចឹង មិនខ្មាស់គេទេ !

-យី ! ខ្មាស ... អាណា ... អូនឯងជារបស់ ... បងណាមើល៍

ទជិតបងបន្តិចមក ... បងសូម ... ថើបអូនឯងបន្តិច !

មាត់ពាល តែមុខរបស់គេងើបឡើងប៉ងនឹងថើបនារីនោះ

តែនាងគៀសចេញ :

-កុំអាល ... ចាំរកកន្លែងស្ងាត់សិន !

ឃើញដូចច្នោះគូកនវា ស្ដីអោយ :

-នែ ! អារស់ ! កុំសូវដាច់ដាបពេកអា ! អាណិតអញ !

អារស់ សំលក់ដាក់គូកន :

-ចុះអាឯងមិនដាច់ដាបទេអ្ហី ! បានជាឱបស្អិតដូចតុកកែអីចឹង

វាងោកខ្លួនស្ទើរទប់ខ្លួនមិននឹង " នែ ! អាស្រី ! បើឯងខ្មាស់គេ

មកទៅក្នុងជាមួយបង ! បងទ្រាំមិនបានទេ !

ពោលចប់គេក្រោកទាំងត្រេតទ្រោត ហើយអូសនាងនោះ

ទៅជាមួយផង ។

នារីផ្កាមាសលក់សំរស់ លក់ឈាមចបំរើតណ្ហាពពួកជន

សង្គម បង្កបញ្ហាគ្រប់យ៉ាងដល់មនុស្សជាតិ បានបណ្ដោយប្រាណ

អោយជនពាលសង្គមអូសយកទៅបាត់ ។ តើគេទៅណា ?

អារស់ចេញផុតទៅ អាក្លើវាងាកទៅញញឹមដាក់កំណាន់របស់គេ :

-ឯបងផ្សេងទៅវិញ ! មិនត្រូវការរបៀបអារស់ទេ !

នាងផ្កាមាសញញឹមយ៉ាងផ្អែមដកខ្សឹដាក់វិញ :

-អូនក៏ពេញចិត្តនឹងបងដែរ ! អូនជារបស់បងហើយ ចាំបាច់អីធ្វើដូចបងរស់ ! មិនថាអីចឹង !

-ត្រូវហើយៗ ពិសីស្រីពៅដួងកែវជីវិតបង ! យើងចាំបន្តិចទៀតមែនទេ ! ហាក៏ ! ឥឡូវផឹកសិនទៅ !

ពោលបណ្ដើរគេលើកកែវស្រារុញអោយនាងផ្កាមាស នាងជោកជាំដោយជាតិសុរាទៅហើយ ដូច្នេះគ្រាន់តែលើកក្រេបប៉ុណ្ណឹងគ្មានបញ្ហាអ្វីសំរាប់នាងដែរ ។

នាងក្រេបស្រារួចសើច អាប្រុសវានិយាយ :

-អាវីអ្ហា ! អូននៅភ្នំពេញធ្លាប់តែអ៊ូអរ ដល់មកនៅសៀមរាបអីចឹង មិនអផ្សុកទេឬ ?

ឮសំនួរនេះនាងបញ្ចេញឫកមាយាភ្លាម :

-ដំបូងអូនអផ្សុកណាស់ តែក្រោយមក ... បាន ... ជួបបងអូនលែងអផ្សុកហើយ ...។

-អីចឹងឬ ! ប្រសើរណាស់ ! មិនបាទន័យថា រូបបងនេះជាទីពេញចិត្តឬ ?

អារី នារីផ្កាមាសឱបក ប្រុសរបស់នាង :

-បងសួន ឯងល្អជាងពួកអាប្រុសៗ ភ្នំពេញឆ្ងាយណាស់ តាំងពីអូនបានជួបបង អូនបានសុខច្រើនណាស់ ពិសេសបងឯង ...។

-បងយ៉ាងម៉េច ?

នារីដកខ្សឹឱនដាក់ត្រចៀកអាសួន ខ្សឹបតិចៗ :

-បងឯងប្រសប់នាំអោយអូនឡើងឋានសួគ៌ ... ។

អាសួនសើចហាស់ៗ ដោយពេញចិត្ត វាទះស្នានាងមេអំបៅស្រាលៗ :

-អូនឯងប៉ុនយល់សាច់ការណាស់ !

អាសួន សើចហើយអើតមើលមុខបុរសម្នាក់ដែលទើបនឹងបោះជំហានចូលមក ធ្វើអោយនាងរ៉ុមេអំបៅចាប់អារម្មណ៍ :

-បង ! បង ! ឯងយ៉ាងម៉េច ?

វាភ្ញាក់ដឹងខ្លួនវិញ និយាយបន្ទប់ :

-គ្មានយ៉ាងម៉េចទេ ! តែបងដូចជាធ្លាប់ស្គាល់អាគាត់នោះ ។

វានិយាយតិចៗ ដោយចង្អុលទៅជនទើបចូលមកដល់

ដែលគ្មានអ្នកណាក្រៅពី ក០០៥ ឡើយ ។

គីរីវុធបង្ហាញខ្លួនក្នុងរង្គសាលមនោរម្យ ប្រកបដោយសំនើចយ៉ាងសង្ហារ ។

វ៉ែនតាខ្មៅរបស់នាយឥតដោះឡើយ នាយក្រឡេកមើលឆ្វេងស្តាំ ហើយឈប់ងក់ត្រង់អាសូន និងនារីមេអំបៅរបស់វា ។

នាយដូចជាធ្លាប់ស្គាល់ទាំងពីរនាក់ហ្នឹង តែដើម្បីកុំអោយវាចាប់អារម្មណ៍ នាយប្រញាប់ងាកមុខចេញ ហើយរកតុមួយអង្គុយៈ

- បោយ !

អ្នកបំរើរត់ញាប់ជើង គោរពភ្ញៀវដ៏ឧត្តមនេះ :

-លោកពិសាអីទាន ?

-ស្រាហ៊ិនីស៊ី និង សូដា !

-បាទ ! បាទ !

ខ្លួនអង្គុយយ៉ាងស្ងៀមស្ងាត់លើកៅអី តែភ្នែកក្រោមវ៉ែនតាបានរេទៅគ្រប់ច្រកល្ហកនៃរង្គសាល ។

បេឡាទទួលលុយ ឈរពីក្រោយតុវែងមួយក្បែរថៅកែបារ ដែលរចនាបានបង្ហាញនាយកាលពីថ្ងៃមុន គឺជាបុរសម្នាក់មានទឹកមុខកាចសាហាវ កំពុងបីតបារីកន្ទុយស្ពោបង្ហុយទៅលើ ។

វង់ភ្លេងសម័យ និងនារីអ្នកចំរៀងម្នាក់កំពុងដំអូញចំរៀងអន្លង់អន្លោចតាមចង្វាក់ស្លូ ! នាងមានសម្រស់គួរគ្រេកគ្រអាល !

បន្ទាប់មកគឺនាយសួនដែលអង្គុយមិនសុខ ។ គឺនាយនេះហើយដែលបានប៉ះដៃនាយកាលនៅលើខ្នងទំនប់បារាយណ៍ តែពាត់ពីរនាក់មិនឃើញ ។

ចំណែកនាងស្រីដែលអង្គុយជិតវានោះ គឺនាយដូចជាធ្លាប់ស្គាល់ដែរ ។

គីរីវុធ យកដៃគោះថ្ងាសប៉ឹកៗ :

-អូ ! គឺស្រីបារនៅភ្នំពេញទេតើ នាយធ្លាប់បានជួបនាងនេះជាច្រើនលើកនៅបារមេកុង ។ ចុះវាមកសៀមរាបពីកាលណា ហើយអ្នកណានាំវាមកទីនេះ ដើម្បីអ្វីដែរ ?

អ្នកបំរើលើកស្រាមកដាក់លើតុនាយ ដោយពោលថា :

-លោកប្រហែលជាអ្នកដំណើរទេ បានជាមិនដែលឃើញមកទីនេះ ! លោកត្រូវមានម្ហូបស្រស់កំដរទេបាទ !

-ម្ហូបក្លែម និងម្ហូបស្រស់យើងត្រូវការដូចគ្នា !

ពោលរួច ពេលដែលអ្នកបំរើចេញទៅ នាយក្រោកឈរសំដៅតុអាសួនដែលកំពុងសំលឹងមករកនាយដោយឆ្ងល់ :

-សួស្តីសំឡាញ់ ! សំឡាញ់ឯងប្រហែលជាមិនស្គាល់គ្នាជាអ្នកណាមែនទេ ?

គីរវុធ អង្គុយទល់មុខវាហើយឆ្លៀតបិចចង្កានាងមេអំបៅបន្តិច តែនាងគៀសដៃចេញ :

-នែ ! កុំសូវខិតលើពេក !

គីរវុធ សើច :

-ចុះអីក៏កំណាញ់ម្ល៉េះ អូនស្រី !

អាសួន លេបទឹកមាត់ :

-ទេ ! គ្នាដូចជាមិនដែលស្គាល់ឯងទេ !

-អីយ៉ា ! ម៉េចក៏ឆាប់ភ្លេចម្ល៉េះ ! កាលនៅពីលើខ្នងទំនប់បារាយណ៍ ...។

អាសួន ចង់បដិសេធមិនទទួលស្គាល់នាយទេ តែពេលនាយចុចចំពេកវារកប្រកែកមិនបាន ហើយនិយាយថា :

-ទេ !ៗ ! "គីរវុធ" ពេញចិត្តណា តែពួកឯងជាមាន់ត្រចៀកស មិនទាន់បានអីផងនាំគ្នាចូលព្រៃអស់ រកតែអញនិយាយជាមួយមិនទាន់ !

-យ៉ាងម៉េចអីឡូវនេះ ឯងចង់និយាយអីឬ ?

-ដោយសារតែមានហ្នឹងហើយ បានជាអញមករក" នាយ
ទោកទៅអារ៊ី" នែ! អូនស្រីយើងសុទ្ធតែអ្នកភ្នំពេញដាច់ឃ៉ែរសាត់
មកដល់ទីនេះដូចគ្នាទេ មិនអញ្ចឹង!

នារីមេអំបៅ ភ្ញាក់ព្រើត :

-អ្ហា! បងឯងជាអ្នកភ្នំពេញដែរ?

-ត្រូវហើយ! គេរកចាប់បងឯភ្នំពេញ បងក៏រត់មកនៅសៀម
រាប...។

-ម៉េចបានជាគេរកចាប់អាឯង?" អាសួនសួរ"

-ព្រោះតែអារឿងទាត់ធាក់ហ្នឹងណា!

-អូ អីចឹងអាឯងជាអ្នកទាត់ធាក់ដែរ?" សួនសួរ" គីរីវុធងក់
ក្បាល :

-មិនត្រឹមតែទាត់ធាត់ទេ ថែមទាំងហាក់តប់ផង!

-គីរីវុធ សើច ។ ពេលដែលអ្នកបំរើលើកសាច់ក្លែមមក នាយបក់
ដៃសញ្ញាអោយទៅដាក់ខាងនាយ :

-យកមកណេះ យើងផឹករួមគ្នាឯណេះវិញ!

បន្ទាប់មក គីរីវុធ ចាក់ស្រាបំពេញកែវខ្លួនឯង កែវអាសួន
និងកែវ អារ៊ី :

-ដើម្បីជាអនុស្សាវរីយ៍នៃថ្ងៃជួបគ្នាជាលើកដំបូងនេះ យើងជល់កែវគ្នាម្តង ហើយគ្នាសង្ឃឹមថា បើឯងមានច្រករកស៊ីប្រាកដជាហៅគ្នាដែរ !

អាសួនស្រវឹងស្រៀង១ ទៅហើយ តែវានៅដឹងខ្លួននៅឡើយ វាហុចកែវស្រាទៅអារ៉ី ហើយលើកកែវឡើងជល់នឹងកែវរបស់គីរីរុធ :

-ប្រសើរណាស់ ! បានមនុស្សដូចឯងមកចូលរួមជាមួយយើងពេញចិត្តណាស់ !

អ្នកទាំងបីក្រេបស្រាទាល់តែអស់ ។ គីរីរុធ ជូរមាត់ហើយចាក់ស្រាបន្ថែមទៀត :

-អារឿងផឹក ! អញដូចជាមិនសូវប៉ុនសោះ តែថ្ងៃនេះបានជួបសំឡាញ់ឯង អញផឹកអោយលេចថ្លើមម្តង !

នាយជល់កែវជាមួយអាសួន មួយកែវហើយមួយកែវទៀតហើយក្រាបលើតុ :

-អាភឿនអញស្រវឹងហើយ ...។

អាសួនញាក់ចិញ្ចើមដាក់នាងសេះកុបយ៉ាងសំងាត់ ហើយវាក្រោយដើរចេញទៅ ។

គីរីវុធ ស្រវឹងឬ ? ពោះរបស់នាយធ្លាប់ទទួលម្តងរាប់សិប

ដប រឿងអីនាយស្រវឹងប៉ុណ្ណឹង ។

ពេលដែលអាសួនដើរចេញទៅ នាយធ្វើជាផ្ងាខ្លួនផ្អែកលើ

កៅអី ហើយសន្ទឹងដៃទៅក្បែរមុខនាងមេអំពៅ ហើយឆ្លៀតបន្ទ

រផ្ទៃលថ្ពាល់នាងផង ...។

-អាស្រី ! កុំភរបង ... មួយយប់ ... ណា !

កែវភ្នែករបស់នាយបានទម្លុះកញ្ចក់វ៉ែនតាតាមមើល

ដំណើររបស់អាសួន ។

អានោះដើរទៅជិតថៅកែបារ ហើយខ្សិនខ្សៀបតិចៗ មិនអាច

អោយនាយឮបានឡើយ ហើយស្រាប់តែអានោះដើរចេញបាត់ទៅ។

បានឱកាស ក០០៥ ត្រូវការនាងមេអំពៅ មិនមែនដោយ

នាយមានតណ្ហានោះទេ តែដើម្បីការងាររបស់នាយ ។

នាយក្រោកដើរ ដោយធេងធោង ដូចមនុស្សស្រវឹងជោក

ហើយតំរង់ទៅរកថៅកែបា :

-គិតលុយ ! គិតថែមទាំងម៉ូយមួយនោះដែល យើងត្រូវការ

យកទៅឥឡូវ ។

-ពីរពាន់រៀល ! ស្មើណាយកមកវិញ ?

-ស្អែកព្រឹក !

នាយបោះជំហានត្រឡប់មកកាន់តុដដែលវិញ :

-យី ! ដូចជាបាត់អាភ្លី ! វាទៅណាអូនស្រី ?

-ខ្ញុំមិនដឹងទេ !

-អីចឹង អូនស្រីឯងទៅជាមួយបង !

-ទៅណា !

-យី ! ដូចជាគ្មានដឹងអីសោះតែម្តង កុំភ័យចាំបងថែមកុំម៉ឺស្យូង អោយ ។

នាងមេអំបៅធ្វើមុខក្រញូវ ព្រោះវាត្រូវការសាហាយវា តែចំពោះមុខថៅកែដែលទិញក្បាលវាបានហើយនោះ វាមិនអាចប្រកែកបានឡើយ

វាក្រោកទាំងទើសទាល់តាមគីរីវុធ ចេញពីបារមួយរំពេច

នាយបានជួលបន្ទប់សណ្ឋាគារមួយ ដើម្បីនាយប្រតិបត្តិការសឹកជាមួយនាង ។

គ្រាន់តែចូលដល់ក្នុងបន្ទប់ភ្លាម នាយច្រានទាងផ្ទាប់លើពូក ហាក់ដូចជាស្លូឈាមខ្លាំងណាស់ ហើយក៏បកសំលៀកនាងចេញអស់ ទុករាងកាយរបស់នាងរលីងអាក្រាតដូចជន្លេន ។

នាងអណ្តើកមាសរើបំរះតិចៗ តែតាមពិតនេះជាឫក មាយារបស់វាតែប៉ុណ្ណោះ ។

តែគីរវុធ ដែលធ្លាប់ប្រព្រឹត្តល្បែងនេះយូរហើយ នាយឥត ចូលចិត្តទេ បន្ទាប់ពីពញ្ញាក់កាមអារម្មណ៍ចំពោះនាងបន្តិច នាយក៏ដឹក ដៃនាងឡើងទៅកៀងទាអាឡេវងឋានត្រៃត្រឹង្ស ធ្វើព្រងើយ ។

នាងកំភេមពេលរាត្រី រោទ៍ដោយក្តីរំភើបស្រៀវស្រើបក្រៃ លែង ។ ដងកាយរបស់នាងរេពត់រមួលដូចអន្ទង់ត្រូវស្ទ ។ នាង ស្រវាឱបចង្កេះបុរសដ៏ប៉ិនប្រសប់ ។

-អូយ ! បងសំឡាញ់ ! អូនពេញចិត្តចំពោះបងណាស់ ! បង ពិតជាមានទេពកោសល្យប្រពៃក្រៃលែង ។

គីរវុធ ញញឹម នាយថើបថ្ពាសនាងថ្នមៗ :

-ព្រលឹង ! ពេញចិត្តទេ ! បងនឹងនាំអូនទៅកសាងសុភមង្គល មួយឆ្ងាយពីគេ អូនព្រមទេ !

នាងមេអំបៅ ដេកផ្កាប់មុខ នាងនៅនឹកស្តាយភាពសុខ ស្រួលដែលទទួលអម្បាញ់មិញនៅឡើយ ។ នាងថ្ងូរតិចៗ :

-ចំពោះបងមួយ បងនាំចូលរូងក្តាមក៏អូនចូលដែរ !

-មែនឬ ?

-ពិតណាស់ !

ក្រោយពីរលកបោកបែកផ្កាត្រែងផ្ទប់នឹងមាត់ច្រាំង គិរីវុធក្រោកអង្គុយលើពូក ហើយហូតចារីមកអុជជក់ ។

នាងពីងពាងជ្រកក្រោមផ្លាកឈ្មោះ អារ៉ាក៏ក្រោកចូលបន្ទប់ទឹកដែរ ។

គិរីវុធ ចាំអោយនាងចេញមកវិញ នាយឱបនាងជាប់ :

-អូនស្រឡាញ់បង !

-ចុះអាសង្សាររបស់អូន !

អារ៉ា ពេបមាត់ :

-ហ៊ឹស ! មនុស្សចោលម្សៀតដូចវា អូនទាត់ក្បាលចោលពេលណាក៏បានដែរ !

គិរីវុធ ទាញប្រាណនាងឱបផ្ទឹបដើមទ្រូងរបស់នាយ ធ្វើអោយកន្សែងពោះគោដែលនាងចោមពុង របូតធ្លាក់ទៅចុងជើងរបស់នាយដែលសណ្ដូកចុះក្រោម ។ នាយថើបជ្រលងសុដន់ដ៏រលើបរលោងរបស់នាង :

-ពៅឈ្ងុកស ! អូនស្អាតណាស់ ! ស្មានមិនដល់ថាបានជួបអូននៅទីនេះសោះ ! អូនអាចប្រាប់បងបានទេ តើអូនមកដល់សៀម

...ពេលនេះដោយចៃដន្យឬ ?

នារីមេអំបៅឱបក គីវវុធ ត្រដុសថ្ពាល់នាងនឹងថ្ពាល់អធិការ ...ពាក់មុខ ហើយមើលមុខយ៉ាងយូរ :

-មិនមែនដោយចៃដន្យទេ ! គឺមានគេតំរូវអោយមក !

-នោះជាអ្នកណា !

នាងអារ៉ាំ នៅទ្រឹងស្ងៀម នាងរារែកចិត្ត ធ្វើអោយលោក អធិការអន្ទះអន្ទែងចង់ដឹងក្រៃលែង តែគេធ្វើហី ហើយអង្អែល ...ក្បាលនាងយ៉ាងយូរ រួចទំលាក់ដៃអង្អែលថ្ពាល់របស់នាង លើកំពូលភ្នំ ...ទាំងគូរពណ៌កូឡាបព្រឿងៗ ។

នាងព្រឹមៗ ធ្មេចភ្នែកទទួលភាពសុខស្រួលយ៉ាងរំភើប ហើយឱបវិញយ៉ាងតឹងដៃ ។ ជាមួយនោះសំលេងនាងថ្ងូរហ៊ឺស :

-អូយ ! បងអើយ ! បងប្រសប់ម៉្លេះទេ !

ក្នុងជីវិតជាផ្កាមាសរបស់នាង នាងឥតដែលទទួលការ ...បពោសអង្អែលពីបុរសណាទេ ព្រោះបុរសទាំងនោះគិតតែខ្លួនគេ ...ពទទួលភាពស្រណុកសុខស្រួលជាការស្រេច ឥតគិតដល់រូបនាង ...ឡើយ ទើបតែពេលនេះដែលនាងបានទទួលការបពោសអង្អែលពី ...អធិការកំលោះមិនអោយនាងថ្ងូរហ៊ឺសម្ដេចកើត ។

ឃើញនាងធ្លាក់ក្នុងកាមអារម្មណ៍ហើយ គីរវុធ សួរតិចៗ

-អ្នកណាប្រើអូនមកទីនេះ ?

នាងធ្វើភ្នែកភីដូចពុលកញ្ឆា :

-កុំអាលសួរបង... អូនស្រួលណាស់ ! បង... អូយ ! អង្អែល... ទៀតទៅ ...។

មិនបង្អង់យូរ គីរវុធឃើញនាងកំពុងត្រដរខ្យល់សារជាថ្មី ដោយរលកតណ្ហា នាយក៏ស្ទុះភ្លែតបំពេញបំណងអោយនាងតាមចំណង់ ។

នាងពីងពាងមាសអារ៉ុ គ្មានអ្វីក្រៅពីរោទ៍ដោយស្រណុកក្រោមលង្វែកទ្រូងរបស់ប្រុសដែលនាងស្រឡាញ់ជាលើកដំបូងនោះឡើយ ។

ឆ្លៀតដែលនាងកំពុងប្រកាច់ ក្នុងមហាកាមសាគរលោកិយ គីរវុធ យកសំនួរដដែលចំពោះនាងទៀត :

-អូនសំលាញ់ ! អូនឃើញឋានសួគ៌ទេ ?

នាងញីក្បាលប្រុសស្នេហ៍ :

-ឃើញច្បាស់ណាស់បង ! ... អូយ ... ហ៊ឺ ...

-អ្នកណាអោយអូនមកសៀមរាប ...

-គឺគេម្នាក់ ... តែចាំពេលក្រោយ ... សុំមបងដឹង ! ...
តាមពិតអូនក៏មិនស្គាល់ ... គេដែរ ...។

-អស្ចារ្យ ! មីនេះលេងបួនសន្លឹកដាក់អញ !

គីរីវុធ នឹកក្នុងចិត្ត នាយស្ទុះចេញពីរូបកាយនាងមយូរ៉ា
ធ្វើអោយនាងសែនស្តាយក្រៃលែង ព្រោះបំណងរបស់នាងឥត
បានសំរេចឡើយ ។ នាងនៅរមួលខ្លួនថ្ងូរហ៊ឹស ។

-អូយ ! ... បង ... ឯងម៉េច ... ចុះចោលអូនពាក់កណ្តាល
ទីពីចឹង ! ... មក ... បង ... បង្ហើយទៅ ...។

គីរីវុធ នឹកអស់សំណើចនឹងភាពស្លូឈាមរបស់នាង នាយ
សួរភ្លាម :

-បើអូនឯងមិននិយាយរឿងអ្នកបញ្ជាអូនមកកាន់ទីនេះបង
លែងរវល់ហើយ ! ... ។

-អូយ ! បងឯងចិត្តអាក្រក់ណាស់ ! មិនដែលនរណានាំគេជិត
ដល់ត្រើយហើយ ចុះចោលដូចបងឯងទេ !

-នាំដល់ត្រើយយ៉ាងម៉េច ! បើអូនឯងមិនត្រង់នឹងបងផង !

អារ៉ិ ស្រវាឱបគីរីវុធសារជាថ្មី តែគីរីវុធ ធ្វើព្រងើយ ។
នាងអង្អែលស្មាគេ ហើយលួងលោម :

-នេះជាការពិតណាបង ! អ្នកដែលអោយអូនមកឥតបង្ហាញ ខ្លួន និងឈ្មោះអោយអូនឃើញទេ ! គេអោយអូនមកតាមសំបុត្រ ដែលប្រាប់ថា អូននឹងស្គាល់គេនៅពេលណាដែលដាក់សំបុត្រ អោយទៅទទួលរបស់មួយបន្តពីប្រាសាទ ... គឺ ! អូនមិនដឹង ប្រាសាទអីទេ ! ចាំតែគេប្រាប់ទើបដឹង ! គេសន្យាថា កាលណា អូននាំយករបស់នោះទៅដល់ភ្នំពេញនោះ អូននឹងក្លាយជាអ្នកមាន មិនខាន ... អូនដឹង តែប៉ុណ្ណេះទេ ... មកបង ! អូនប្រាប់ បងអស់ហើយ បងមិនអាសូរអូនទេឬ ?

ពោលរួច នាងផ្ដួលខ្លួនលើពូកហើយទាញគីរីរុធទៅជាមួយ ផង ។

នៅលើជញ្ជាំង ជីងចក់ឃំជិចៗហើយដេញខាំគ្នាប្រញាយ។

~៤~

ម៉ូតូហុងដា ១២៥ឈប់ នាងពីងពាងមាសចុះពីម៉ូតូអាល័យ ភ្នែករបស់នាងឡើងសល្អក់ដូចត្រីស្ងោ ព្រោះនាងភ្លក់រសជាតិស្នេហារបស់គីរីវុធ មួយយប់កន្លងមក ។

-បងលាហើយណា " គីរីវុធពោលតិចៗ" ចាំស្អែកល្ងាចបងមកទទួលអូនទៀតឮទេ !

នាងងក់ក្បាល :

-អូនចាំបងជានិច្ច !

គីរីវុធ សើចនិយាយលេង :

-គ្រាន់តែយំ ភ្នែកចង់ប្រែពណ៌ទៅហើយ អូនឯងខ្សោយណាស់!

នាយសំឡក់ដោយឥតចេញវាចាមួយម៉ាត់ឡើយ ។ គីរីវុធបញ្ឆេះម៉ូតូចាកចេញពីទីនោះជាបន្ទាន់ ។ តើនាយត្រូវទៅកាន់ទីណា ?

គ្មានគោលដៅពិតប្រាកដ ! គំនិតរបស់នាយរេរកច្រកដោះស្រាយបញ្ហាដែលប្រទាក់ដូចអំបោះជំពាក់មុខ ។

ពន្លឺតូចមួយដែលចេញពីសំដីរបស់អារ៉ុយកជាការមិនទាន់

បានជាដុំកំភួនឡើយ ។ តែនាងនេះច្បាស់ជាគេបញ្ជូនមកដោយរឿងនេះមិនខាន ! ទទួលយករបស់ម៉្យាង ...។

តើជារបស់អ្វីទៅ ? កំណាប់ដែលអិយយន់ជីកឃើញនោះឬ ?

នាយគិតស្ទើរឡប់ក្រឡកធាតុ តែរកសន្និដ្ឋានអោយច្បាស់មិនទាន់កើត !

ទីបំផុតម៉ូតូរបស់នាយរត់តាមផ្លូវជាតិឆ្ពោះទៅជើង ទៅកាន់ប្រាសាទអង្គរ ... ភ្លាមនោះនាយនឹកឃើញសំដីអារ៉ី ប្រាប់ថានាងត្រូវទៅទទួលយករបស់នោះនៅប្រាសាទ ... តើប្រាសាទណាបើក្នុងបរិវេណប្រាសាទអង្គរមានប្រាសាទរាប់រយឯណោះ !

ភ្លាមនោះនាយកាច់ចង្កូចបំបែរម៉ូតូចេញពីថ្នល់កៅស៊ូចូលព្រៃប្រោក ។

នាយងាកជុំវិញ ឃើញស្ងាត់គ្មានមនុស្ស ទើបនាយបញ្ចេញវត្ថុពិសេសពីហោប៉ៅហើយចុចគន្លឹះបញ្ជាម៉ាស៊ីន ។

ពណ៌ក្រហម និងសំលេងទីទៗ នាយនិយាយ :

-ក០០៥ ! សូមចាត់ភ្នាក់ងារឃាមគ្រប់ប្រាសាទ ! អស់ !

នាយបញ្ជូនវត្ថុនោះក្នុងហោប៉ៅយ៉ាងរហ័ស ព្រោះសំលេង

ួយលាន់ឡើងក្បែរត្រចៀក ហើយភ្នែករបស់នាយងាកផាច់ទៅរក

ក្រគពសំលេង ... មនុស្សម្នាក់ ... ធ្វើជាភ្ញាក់ហើយប្រុងរត់គេច

ាបន្ទាន់ តែ ...

ឈប់សិន !

នាយគំហកព្រមទាំងច្រានម៉ូតូ ហើយរត់តំរង់ទៅកាន់ទី

ោះដូចហោះ ។

ជនចំលែកឃើញសភាពការណ៍មិនស្រួល វាបញ្ចេញកាំបិត

ស្សៀតភ្លែត កំញើញ :

កុំចូលប្រយ័ត្នស្លាប់ !

គ្មានព្រីប៉ុនសរសៃសក់ទេ ! គីរីវុធលោតវៀហើយស្រែក

ាច " ទាត់ទៅពីចំងាយ ។

ជននោះគេចចេញទៅម្ខាងដោយមុខកាំបិតតំរង់មករក

ាយ ប្រាថ្នាសំលាប់នាយនឹងកន្លែងតែម្តង ។

តែខកសោះ គីរីវុធ ភ្នាក់ងារ ក០០៥ ធ្លាប់ទទួលងារខ្សែ

ក្រវ៉ាត់ខ្មៅបីជាន់នៅក្រុងតូក្យូ ខាងស្នៀតការ៉ាតេ ។ ទទួលងារ

ខ្សែក្រវ៉ាត់ខ្មៅបួនជាន់នៅក្រុងសេអ៊ូលប្រទេសកូរ៉េ ខាងកីឡា

ប្រយាល់តៃក្វាន់ដូ ថែមនេះទៀតនាយបានហាត់ចេះស្ទាត់នូវក្បាច់

បូរាណខ្មែរទៀតផង ។

ហេតុនេះ គ្រាន់តែបុកកាំបិតមកភ្លាម មិនគ្រាន់តែមិនកាត់រងប៉ុណ្ណោះទេ នាយបែរជាទាត់ផាច់ៗ បីជើងផ្ទួនគ្នាធ្វើអោយវាច្រឡោតគោកតួងទៅម្ខាងដោយកាំបិតរបស់វា ឥតមានលទ្ធភាពប្រើការកើតនៅឡើយ ។

តែតាមមើលទៅជនចំលែក ហាក់ដូចជាចេះស្ទៀតខ្ពស់គួរសម វាយហក់ធាក់ដោយសន្ទុះគួរអោយស្ងើចសរសើរ តែមិនអាចប៉ះពាល់ដល់រោមជើងរបស់នាយបានឡើយ ។

គីរវុធ បង្វិលខ្លួនមួយជុំ ឆ្លៀតប្រើកែងដៃអុកទ្រូងវាផាំងហើយជើងស្តាំប្រកបដោយថាមពលរាប់នាលក៏ហើរជាបន្តទៅទៀត ហើយរហ័សជាងផ្លេកបន្ទោរ និងខ្លាំងជាងរន្ទះទាំងប្រាំ ទិសសន្ទុះជើងរបស់នាយក្រលែងថ្គាមរបស់វាផាំង !

-អូយ ! "សំរែកគ្រលួច"

បន្ទាប់មករាងកាយដ៏សំបើមរបស់វាដួលលើដី

-ស្លាប់ចុះអា ! ឥតអាណិតទេ ! ព្រោះអាឯងគ្មានគំនិតល្អមួយអញសោះ ! សង្គមជាតិឥតត្រូវការមនុស្សធុនអាឯងទេ !

ទម្ងន់ជើងរបស់គីរវុធ សង្កត់លើខ្នងវាហើយនាយរលាស់

វាចាវ៉ាវដូចទឹកហូរ ៖

-និយាយអោយច្បាស់ បើចង់សុខខ្លួន ! អ្នកណាប្រើអាឯង មកកាន់ទីនេះ ?

អានោះមិនឆ្លើយ ហើយស្រែកថ្ងូរខ្លាំងៗ ចំលែក !

គីរីវុធ សង្កត់វាថែមទៀត វាស្រែករឹតតែខ្លាំង !

ក ០០៥ ចាប់អារម្មណ៍ភ្លាម ធម្មតាមនុស្សឆ្លាតស្លាប់ ច្បាស់ជាស្រែកសុំជីវិតមិនខាន ហេតុដូចម្តេចក៏វាស្រែកស្លឈាម ខ្លាំងម្ល៉េះ មួយជើងអម្បាញ់មិញមិនធ្វើអោយវាជកចង្ការមាន់ទេ !

ដូច្នេះនាយត្រូវប្រុងប្រយ័ត្ន តែជើងនៅសង្កត់វាធ្ងន់ពាប់ ដដែល ហើយរឹតតែខ្លាំង ៖

-និយាយទៅ ! លឿនឡើង ! យមភូបាលរង់ចាំនាំព្រលឹងអា ឯងទៅកាន់បាតាលហើយ !

ដូចនាយស្មានឥតខុស ស្នូរសំលេងម៉ូតូឮយ៉ាងស្រាល ហើយភ្លាមនោះ ៖

-ប៉ុង !

ដោយគំនិតប្រតិកម្ម គីរីវុធ ផ្តួលខ្លួនលើដី ហើយប្រមៀល ពីរបីត្រឡប់ ៖

គ្រាប់កាំភ្លើងទីមួយហើរទៅបៀមជាប់នឹងដើមយាងមួយដើម ។ អម្បាញ់មិញ បើនាយក្រាបមិនទាន់ទេ ម៉្លេះរូបកាយនាយត្រូវគេទំលុះបាត់ហើយ នាយក៏ត្រូវឆ្កែចចកហែកវេលាយប់នេះ ។

មួយប៉ប្រិចភ្នែកប៉ុណ្ណោះ គ្រាប់ទីពីរលាន់ឡើង :

-ប៉ុង !

ជាមួយនឹងសំលេង " អូយ " ជនដែលនាយវាយអោយរបួសអម្បាញ់មិញប្រកាច់រវើរវក់ក្នុងថ្លុកឈាម ។

-ចុម ! ពួកវាសំលាប់មនុស្សបំបាត់ដានទេតើ !

ដោយកាយវិការដូចជំរឆក់ គីរីរុធ ប្រមៀលខ្លួនថែមពីរបីត្រឡប់ទៀត ហើយស្រវ៉ាចាប់កាំបិតស្នៀតគប់តំរង់ប្រភពកាំភ្លើងតែហួសពេលទៅហើយ ម៉ូតូហុងដាធុន ហ៊ុរអ៊ិច ១២៥ បោះពួយចេញយ៉ាងលឿន ។

គីរីរុធ ស្ទុះងើបឡើងហើយរត់ទៅចាប់ដៃម៉ូតូ បញ្ឆេះហើយហក់ចេញទៅភ្លាម ។ នាយមួលវ៉ាភិបឥតបន្ធូរដៃ យានយន្តបោលដូចហោះ ។ កង់វាឥតជាប់លើថ្នល់ឡើយ ។

តែម៉ូតូមុនត្រូវបាត់ដានដោយផ្លូវក្រវិចក្រវៀនពេក ហើយព្រៃក៏ធំផង ។

នាយក្តៅក្រហាយក្រៃលែង សឹងបោកក្បាលបំបែកពិសេស ស្តាយជនទុច្ចរិតដែលហៀបចាប់បានទៅហើយ បែរជាត្រូវខកខាន ទៅវិញ ។

នាយបរវ្ហៃលឆ្វាត់មួយសន្ទុះរកមើលតទៅទៀត តែ ! មានតែខ្យល់បក់ចុងឈើប្រាវៗ ប៉ុណ្ណោះដែលកំពុងស្វាគមន៍នាយ ក្នុងដំណើររុកនេះ ។

បន្តិចក្រោយមកនាយបានបត់ក្បាលត្រឡប់មកកាន់ក្រុង សៀមរាបវិញ ។

ថ្ងៃបុណ្យកំណើតរបស់នារតីបានមកដល់ នៅគេហដ្ឋាន របស់នាងមានរៀបចំយ៉ាងល្អប្រណិតប្រកបដោយផ្កាភ្ញីរំយោល និងអំពូលអគ្គិសនីព្រោងព្រាត ។ នារតី និងម្តាយនាងរវល់ជាង គេក្នុងពិធីនេះ ។

តាំងពីព្រលឹមអ៊ុំស្រីត្រូវទៅផ្សារដើម្បីទិញម្ហូបរៀបចំពិធី ជប់លៀង ចំណែកនារតី និងអ្នកបំរើរៀបចំតុបតែងផ្ទះ ។ លើ ជញ្ជាំងសុមទ្វារក្រោយពីស្លឹកដូង និងស្លឹកជ្រៃក្រឹម នៅមានផ្ទាំង អក្សរចារជាភាសាបារាំង និងអង់គ្លេស មានន័យថាអបអរីករាយ ថ្ងៃខួបកំណើត ។

តុមួយកណ្ដាលបន្ទប់ទទួលភ្ញៀវ រៀបចំផ្កាភ្ញី និងវត្ថុសិល្បៈផ្សេងៗ គឺកន្លែងតំកល់នំសុភមង្គល ។

គីវរុធ ក៏បានជួយរៀបចំដែរ នាយសួរនារតី :

-អូនឯងមានអញ្ជើញនាងរចនា និងបងប្រុសគេទេ ?

នារី ងាកមើលមុខអធិការសំងាត់ សួរវិញ :

-បងឯងសួរធ្វើអី ? បើមិនអញ្ជើញយ៉ាងម៉េច

-យី ! ម៉េច អូនឯងមិនហៅគេផង ?

-ហ៊ឹះ ! បងឯងយកចិត្តទុកដាក់នឹងរចនាណាស់មែនទេ ?

គីវរុធ សើចស្រស់ ត្បិកក្បាលនាងបន្តិច :

-បងមើលទៅអូនឯងដូចជាប្រច័ណ្ឌណាស់មែនទេ ?

-ខ្ពើមណាស់ " នារតីពេបមាត់ " បើបងឯងស្រលាញ់គេក៏ស្រលាញ់ចុះ ! នារតីឥតថាអីទេ !

-អញ្ជើញហើយ ! កុំសួរកើតទុក្ខពេក !

គីវរុធ សើចដោយហួសចិត្ត ។

-ចាំម៉ោងពីរបងមកវិញណា ! បងមានការចេញទៅក្រៅបន្តិច!

-អញ្ជើញចុះ ! មិនមកវិញក៏បានដែរ !

នារតីនិយាយដោយគ្នាន់ខ្នាញ់ ។

គីរីវុធ អួសម៉ូតូចេញដោយងាកក្រោយញញឹមដាក់សង្សារ

អស់ពេលប៉ុន្មានថ្ងៃហើយដែលគីរីវុធទទួលបញ្ជាអោយមកស្រាវជ្រាវឃាតកដែលកើតឡើងក្នុងបរិវេណប្រាសាទអង្គរ តែមកទល់ថ្ងៃនេះនាយមិនទាន់ចាប់ប្រភពវាឃើញនៅឡើយទេ ។ គ្រាន់តែប្រផិតប្រផើយប៉ុណ្ណោះ ព្រោះជនទុច្ចរិតរៀបដើងព្រួលល្អណាស់ !

ពត៌មានដែលនាយបានទទួលពីយ៉ានី បានដឹងត្រឹមតែថាមានកំណប់ពិសេសដែលជនទុច្ចរិតប្រាថ្នាហើយសំលាប់អ៊ំយន់និងអ៊ំចាន់បំបាត់ដាន ។ ឯពត៌មានទទួលពីនាងអារ៉ីដឹងត្រឹមតែស្រពិចស្រពិលប៉ុណ្ណោះ ។ គឺនាងនេះមានពាក់ព័ន្ធជាមួយនឹងអំពើឃាតកម្ម និងការជំរិតកំណប់ពិសេស ! តើកំណប់ពិសេសនោះជាអ្វី ហេតុអ្វីក៏មានកំទេចត្បូងក្នុងរណ្ដៅដែលអ៊ុំយន់គាស់គល់ឈើនោះ ។

តើត្បូងនោះជាប្រភេទណា ?

ហេតុអ្វីបានជាមានកំណប់ក្បែរប្រាសាទបូរាណដូច្នេះ ?

ឬក៏ត្បូងនេះជាបូរាណវត្ថុដែរ ? ...

ដូច្នេះត្រូវមើលកំទេចត្បូងអោយច្បាស់សិន !

សំរេចចិត្តហើយ នាយតំរង់ទិសទៅកាន់ភូមិត្រពាំងសេះ

អ៊ំសែនកំពុងដណ្តាំស្លដើម្បីចេញទៅធ្វើការ ទទួលក្រឡេក ឃើញគីរីវុធ :

-យី ! ឯទៅណាបាត់ពីរបីថ្ងៃ ?

-បាទ ! លោកអ៊ំ ! ក្មួយដើរលេងឯក្រុង ! ចុះនាងអូនទៅណាដែរ ?

-បាទ ! ខ្ញុំចង់ឃើញកំទេចត្បូងដែលលោកអ៊ំយកទៅលក់អោយគេបន្តិច !

-យើងលក់អោយគេហើយ ! ក្មួយចង់មើលធ្វើអី ក្រែងគេកែច្នៃ ឬក៏លក់បាត់ហើយទេដឹង ?

-ទោះយ៉ាងណាក៏ត្រូវទៅអោយឃើញបន្តិចដែរ ព្រោះខ្ញុំចង់ឃើញណាស់ !

ទទួលពេលនោះនាងយ៉ានីឡើងមកដល់ :

-យី ! បងទេ ! ខ្ញុំស្មានថាបងអញ្ជើញទៅភ្នំពេញវិញហើយ !

គីរីវុធ សើច :

-នៅទេនាងអូន ! បើបងទៅវិញត្រូវតែមលាលោកអ៊ុំ និង

នាងអូនមិនខាន !

-មីនាងអ្ហា ! ក្មួយចង់ឃើញកំទេចត្បូងដែលយើងលក់ពីថ្ងៃមុន! កូនឯងជូនក្មួយទៅផ្ទះអ្នកលក់នោះបន្តិចទៅ !

-ចាស់ !

-ក្មួយអ្ហា ! ហូបបាយសិនទៅ

-មិនអីទេលោកអ៊ំ ! ខ្ញុំនាំនាងអូនទៅញ៉ាំឯផ្សារចុះ ! នាងអូនផ្លាស់សំពត់អាវទៅ !

យ៉ានី នារីជនបទនាងឥតដែលស្គាល់ជាតិជិះម៉ូតូទេ ម្ល៉េះហើយពេលទំពីក្រោយខ្នងគីរីវុធ នាងភ័យញ័រដោយខ្លាចភ្លាត់ហើយឱបចង្កេះគេមិនកើត នាងប្រឹងទប់ខ្លួនឡើងបែកញើស :

-បង ! កុំសូវបើកលឿនពេក ប្រយ័ត្នធ្លាក់ណា !

គីរីវុធ សើច :

-ប៉ុណ្ណឹងឃើតទេ ! បើខ្លាចធ្លាក់ឱបចង្កេះបងមក !

យ៉ានី អៀនក្រហមមុខប្រកែកញ៉ាញ :

-មិនកើតទេ ! ឱបចង្កេះដូចប្ដីប្រពន្ធម៉េចកើត !

-ចុះយើងជាបងប្អូននឹងគ្នាដែរតើ !

-គ្រាន់តែជាបងប្អូន ធ្វើដូច្នេះមិនកើតទេ !

-ស្រេចលើអូនឯងចុះ !

គីរីវុធ ធ្វើជាកាច់ចង្កូចទំលាក់ស្នាមជង្គុកធ្វើអោយរលាក់បន្តិច យ៉ានីស្រែកយ៉ៃ ហើយគិតមិនទាន់ក៏ឱបចង្កេះគីរីវុធមែន ព្រោះខ្លាចធ្លាក់ ។ នាយចំអន់លេង :

-ន៎ ! កូននេះម៉េចឱបចង្កេះគេអីចឹង !

យ៉ានីអៀនក្រៃណាអៀន ស្ទើរលោតចុះពីម៉ូតូ នាងក្តិចខ្នងបងជីដូនមួយ ពិតឬពុំពិត បន្តិចស្តីអោយ :

-បងឯងលេងអាក្រក់ណាស់ !

គីរីវុធ សើចហែសៗ នាយមានចរិតខិលណាស់ចំពោះស្រីៗ ។ អម្បាញ់មិញ ខ្នងរបស់នាយមានវាសនាដោយបានសុជន់នារីជនបទជល់បន្តិចធ្វើអោយរសើបតិចៗ ដែរ ។

-បងលេងអាក្រក់តែនឹងបងប្អូនឯងទេ បើមិនស្គាល់គ្នា ក៏បងមិនលេងដែរ ! អូនកុំប្រកាន់ !

-អូនមិនប្រកាន់បងទេ ! តែ ...

-តែយ៉ាងម៉េច ?

-បងឯងធ្វើអីចឹង ! ធ្វើអោយអូននឹកបងឯងមួយជីវិត !

គីរីវុធ ភ្ញាក់ព្រើត អុញដល់ហើយតើ ! ស្មានមិនដល់ថា

ពន្លកស្អីមួយផុះចេញពីបេះដូងនាងសោះ ។

គីរីវុធ សើចស្មើរលែងសម ស្មានមិនដល់ថានារីជនបទ ហាមាត់ហែកស្រទាប់បេះដូងប្រាប់នាយសោះ នាយលែងមាត់តទៅទៀតហើយបង្កើនល្បឿនយានរហូតមកឈប់ពីមុខហាងលក់មាសមួយទល់មុខផ្សារតាមការបង្ហាញរបស់យ៉ានី ។

-ហ្នឹងហើយបង ! ផ្ទះហ្នឹងហើយ !

គីរីវុធ រលាស់ជន្ទល់ម៉ូតូ នាយទាញវ៉ែនតាមកពាក់ រួចបោះជំហានទៅ ។

អ្នកខ្លះសំលឹងព្រាត ព្រោះសាច់ឈាមរបស់សង្សារមួយគូនេះមិនសមគ្នាសោះ ។

-លោក ! លោកស្រី ! អញ្ជើញអីចា៎ះ ខ្សែក ខ្សែដៃ ឬ ចិញ្ចៀនដាំត្បូង ?

ម្ចាស់ហាងស្រីនិយាយរាក់ទាក់រកភ្ញៀវដោយញញឹមខ្ជិប។

គីរីវុធ ឈរច្រត់ចង្កេះពីមុខទូរកញ្ចក់ដែលខាងក្នុងមានតាំងខ្សែមាសប្រកបដោយពន្លឺផ្លេក១ ចាំងចេញពីត្បូង និងពេជ្រ

-នែ ! អ្នកអ្ហា ! ...” នាយនិយាយទៅកាន់ម្ចាស់ហាង” កាលពីថ្ងៃមុនអ្នកមានទិញត្បូងពីនាងខាងណោះមែនទេ ?

ម្ចាស់ហាងធ្វើមុខឆ្ងល់សំលឹងមុខគីរវុធ រួចសំលឹងមុខ យ៉ានី ដោយទឹកមុខចំលែក បន្តិចក្រោយមកទើបសំរួលទេវិញ ពោលថាៈ

-ទេ ! ដូចជាគ្មានទេ ! នាងច្រឡំទេដឹង !

-ទេ ! យ៉ានី " ប្រកែកញ៉ាញ " ខ្ញុំឥតច្រឡំទេច្បាស់ជាមីងឯងហ្នឹង !

-នាងនឹកអោយស្រួលបួលបន្តិចទៅ !

-ទេ ! ខ្ញុំមិនទាន់ភ្លេចទេ ! គឺហាងមីងឯងហ្នឹង !

ការដែលម្ចាស់ហាងប្រកែកមិនចង់ទទួលសារភាពមកពីគាត់ខ្លាចនាងយ៉ានីលួចរបស់គេ ម៉្យាងឬក៏នាងយ៉ានីត្រូវអ្នកដទៃអោយថ្លៃលើសមករករឿងគាត់វិញ ហេតុនេះជាការល្អចាំបាច់ត្រូវតែបដិសេធ ។

គីរវុធ រង់ចាំមើលប្រតិកម្មរបស់ម្ចាស់ហាងមួយសន្ទុះ ទើបនិយាយតាមសំរួល :

-អ្នកអ្នា ! មើលនាយអាយស្រួលបួលមើល ! គ្មានអ្នកណាគេច្រឡំហាងបុណ្ណឹងទេ !

-ទេ ! ខ្ញុំថាមិនមែនគឺមិនមែនហើយ !

-បើគេនៅតែប្រកែក ខ្ញុំទៅរកភ្នាក់ងារប្រចាំផ្សារនេះ !

ឮសូរភ្នាក់ងារប្រចាំផ្សារថៅកែឥតព្រីក្បាលទេ ព្រោះទឹកលុយរបស់គេអាចទិញក្បាលភ្នាក់ងារទាំងនោះបានដោយងាយ ។

ខ្ជិលជជែកច្រើន គីរីវុធបោះជំហានទៅកាន់ប៉ុស្តិ៍ផ្សារ ក្រោយពីបានបង្ហាញកាតហើយ ភ្នាក់ងារនោះដើររលះរលាំងមកដល់ភ្លាម ។

-មីង ! ត្រូវតែបង្ហាញត្បូងដែលនាងនេះលក់អោយកាលពីថ្ងៃមុនទៅលោកនេះ !

ថៅកែហាងធ្វើភ្នែកព្រិចៗ ហើយលួចញាក់ចិញ្ចើមដាក់ភ្នាក់ងារនោះ តែជាការឥតប្រយោជន៍ ព្រោះនៅមុខគីរីវុធ គ្នាធ្វើម៉េចហ៊ាន :

-មីងឯងត្រូវប្រគល់អោយលោកខាងណោះមើលឿនឡើង

-មិនមែនទេលោក ! ខ្ញុំឥតបានទិញរបស់នោះពីនាងនេះទេ !

-នៅតែប្រកែកទៀត " ភ្នាក់ងារ " មើលនាង នាងពិតជាលក់អោយគាត់មែនទេ ?

-ចាស់ ! ពិតហើយ !

-បើដូច្នោះ " ភ្នាក់ងារ " ខ្ញុំត្រូវដាក់ខ្នោះមីងឯងនាំយកទៅកាន់ស្នងការ !

ឮសួរថាខ្មោះដៃ ថៅកែហាងភ័យស្វាយបបូរមាត់ ស្រែកហៅថៅកែប្រុសជាបន្ទាន់ :

-ប៉ាវា ! អើប៉ាវា !

ថៅកែប្រុសមានវ៉ែនតាមនុស្សចាស់ នឹងភ្នែកស្ទុះចេញមក:

-មានការអីឬ ?

-នែ ! នាងនេះប្រាប់ថា ពីថ្ងៃមុនបានលក់ត្បូងអោយឯង តើឯងមានទិញទេ ?

ថៅកែប្រុសសំលឹងមើលយ៉ានីពីលើដល់ក្រោម រួចទើបបែរទៅនិយាយជាមួយគីរវុធ :

-លោកចង់មើលត្បូងនោះធ្វើអី ?

គីរវុធមិនឆ្លើយ ភ្នាក់ងារឆ្លើយកាត់ :

-មានការបានជាចង់មើល ! ម៉េចចាំសួរអីចឹង

ថៅកែហាងទាំងប្តីប្រពន្ធមិនដែលឃើញភ្នាក់ងារសំបិអាក្រក់ដូចលើកនេះទេ គាត់យល់ថាប្រហែលជាមានការពិសេសហើយ ហេតុនេះក៏នៅស្ងៀមលែងមាត់តទៅទៀត ។

គីរវុធ សួរ :

-ត្បូងនោះថៅកែឯងឥតទាន់កែច្នៃទេឬ ?

-បាទ ! បាទ ! នៅទេ !

-អីចឹងល្អហើយ ! "គីរីវុធ" យកចេញមក !

-បាទ ! ឮ !

ថៅកែនោះញ៉រមាត់ប្រញាប់ចាក់សោរបើកទូយកប្រអប់មួយចេញមក ហុចអោយគីរីវុធ ។ គីរីវុធ យកមកលើកផ្ទៀងផ្ទងមើល ។ ត្បូងនេះថ្វីត្បិតតែនៅខ្ចៅ តែស្អាតអស្ចារ្យ វាដេញពន្លឺផ្លេក១ ដូចពេជ្រអីចឹង ។ គីរីវុធ ឥតដឹងថាត្បូងមួយគ្រាប់នេះមានតំលៃពិតប្រាកដប៉ុណ្ណាទេ ព្រោះនាយមិនមែនជាអ្នកជំនាញខាងត្បូងឯណា ! ភ្លាមនោះនាយនឹកឃើញដល់ក្រុមអភិរក្សប្រាសាទបូរាណដែលជំនាញខាងវត្ថុបូរាណ ។

-ខ្ញុំសុំយកត្បូងនេះទៅអោយអ្នកជំនាញមើលបន្តិចបានទេ ?

-យី ! ម៉េចអីចឹង ! ដំបូងថាសុំមើលទេ ! ឥឡូវបែរជាសុំយកទៅណាទៀត ! មិនកើតទេទុកចិត្តម្ដេចបាន !

ភ្នាក់ងារដែលឈរក្បែរនោះលូកមាត់ :

-បើលោកខាងណោះត្រូវការយកទៅសួរគេបន្តិចអោយគាត់យកទៅចុះ !

-មិនកើតទេ ! " ចៅកែហាង " ខ្ញុំទុកចិត្តម្ដេចបាន !

-មិនអីទេ ! ខ្ញុំធានា ! " ភ្នាក់ងារ " ។

ម្ចាស់ហាងនៅស្ងៀម ធ្វើភ្នែកភ្លឹះៗដូចកូនឈ្លូសឃើញភ្លើងព្រាន ។

គីរវុធ ច្រកប្រអប់នោះក្នុងហោប៉ៅ នាយនិយាយទៅកាន់ភ្នាក់ងារ :

-ខ្ញុំជាអ្នកណា ? នេះជាអាថ៌កំបាំងរក្សាទុកអោយបាន

-បាទ ! ៗ ! សូមលោកកុំព្រួយ ។

នាយងាកមកខាងយ៉ានី :

អ្នកទាំងពីរបានមកដល់ក្រសួងអភិរក្សអង្គរ គីរវុធបញ្ឈប់ម៉ូតូ :

-លោកនាយនៅទេនាយ !

អ្នកយាមអើតក្បាលចេញពីប៉ុស្តិ៍ :

-បាទ ! នៅ !

-ខ្ញុំអាចចូលទៅបានទេ ?

-មិនទាន់បានទេ ចាំខ្ញុំសួរលោកនាយសិន ពិសេសសុំលោកហុចកាត !

គីរីវុធហុចកាត អ្នកយាមទ្វារគោរពបន្តិចហើយលើក ទូរស័ព្ទសួរទៅក្នុង ។ ទើបប្រាប់ថា :

-លោកនាយកអនុញ្ញាត្តិហើយ សូមលោកអញ្ជើញចូល !

ម៉ូតូរុលទៅមុខ ។

បុរសម្នាក់រាងទាបចេញមក :

-សួស្តីលោកអធិការ !

-បាទ ! សួស្តីលោកនាយក !

អ្នកទាំងពីរចាប់ដៃគ្នាតាមរបៀបសកល ។

-ខ្ញុំសែនរីករាយណាស់ដែលលោកអធិការអញ្ជើញមកកា កន្លែងខ្ញុំ ! លោកត្រូវការទស្សនាវត្ថុបូរាណនៅទីនេះឬ ?

-នេះជាគោលបំណងបន្ទាប់បន្សំទេ !

-ចុះគោលបំណងសំខាន់ ?

-សុំ យោបល់ខ្លះពីលោក !

-អីចឹងទេ ! សូមអញ្ជើញចូល !

អ្នកទាំងពីរបណ្តើរគ្នាចូលទៅកាន់ការិយាល័យរបស់ លោកនាយក ។

នារីម្នាក់កាន់ថាសទ្រកែវទឹក និងបារីចេញមកដាក់លើតុ

មុខភ្ញៀវ ។

គីរីវុធសំលឹងមុខលោកនាយក រួចមុខយ៉ានីនាយពោល :

-លោកនាយក ! នេះជាការសំងាត់ !

-អីចឹងឬ ? គាត់ងាកទៅនារីបំរើ " នាងនាំនាងខាងណោះចេញទៅអង្គុយលេងនៅបណ្ណាល័យមើលរូបភាព និងទស្សនាវដ្ដីលេងណា !

-ចាស់ !

នាងនាំយ៉ានីចេញទៅ ។

គីរីវុធដកប្រអប់ត្បូងចេញមក បើកគំរបហើយហុចជូនលោកនាយក :

-លោកនាយក ! លោកអាចស្គាល់ត្បូងនេះទេ ?

លោកនាយកលើកត្បូងមើលបន្តិច ក៏ក្រោកទៅលើកមីក្រូទស្សន៍ចេញមក គាត់ឆ្លុះមើលយ៉ាងពិនិត្យពិច័យ ទើបពោលថា :

-ត្បូងនេះត្រូវកប់ដីយូរហើយ !

គីរីវុធ នៅស្ងៀមចាំស្ដាប់ពត៌មានរបស់លោកនាយកដែលពោលបន្ត :

-ត្បូងធម្មតាដែលនៅក្នុងដីជារ៉ែឥតទាន់ទទួលការកែច្នៃ មានសភាពគ្រោតគ្រាត និងស្រអាប់ ។ តែត្បូងនេះមានសភាពរលីង ដូច្នេះហើយកប់ក្នុងដីបញ្ជាក់ថាជាត្បូងដែលគេកែច្នៃរួចហើយ ទើបយកទៅកប់ដី ដូច្នេះយើងអាចសន្និដ្ឋានថាជាកំណប់ ។ តើលោកបានពីណាមក ?

គីរីវុធ រៀបរាប់រឿងឃាតកម្មកើតឡើងនៅភូមិត្រពាំងសេះប្រាប់លោកនាយកសព្វគ្រប់ហើយបន្ថែមថា :

-តើលោកនាយកមានចាប់សង្ស័យថាវាជាវត្ថុបូរាណឬ ?

-វត្ថុបូរាណ ! " លោកនាយកផ្ទួនពាក្យ " ហេតុម្តេចក៏លោកចាប់អារម្មណ៍ថាជាវត្ថុបូរាណ ?

-តាមកិរិយា និងកូនរបស់ជនរងគ្រោះដែលប្រាប់ថាវត្ថុទាំងនេះរកឃើញនៅក្នុងរណ្តៅជាមួយនិងថង់មៀវនៃត្បូងនេះ ខ្ញុំសង្ស័យថាត្បូងនេះត្រូវបែកចេញដោយការប៉ះទង្គិចជាមួយនឹងចបនៅពេលកាប់គាស់ ដូច្នេះត្បូងនេះអាចជាកំទេចនៃរូបអីមួយ !

-មែន ! បើលោកអធិការពោលបែបនេះគួរឱ្យចាប់អារម្មណ៍ដែរ ! នៅក្នុងសារៈមន្ទីររបស់ខ្ញុំមានរូបបដិមាមួយធ្វើអំពីត្បូងដែលគេធាយឃើញនៅក្បែរប្រាសាទព្រហ្មកិល ។ ត្បូងនេះ

មានលក្ខណៈដូចជាត្បូងនោះអីចឹង ! ហើយតាមសិលាចារឹកបានប្រាប់ថានៅសតវត្សទី ១០ ក្នុងរាជ្យស្ដេចយសោវរ្ម័ន ប្រជាជនខ្មែរបានសាងរូបបដិមាអំពីត្បូងកែវដ៏មានតំលៃចំនួនពីរតំកល់នៅប្រាសាទបក្សីចាំក្រុង ហេតុក្រោយមកដោយមានសង្គ្រាមជាមួយជនជាតិចាម គេក៏បានយកបដិមា ឬទេវរូបត្បូងខ្មៅនេះទៅកប់ចោល ។

សូមលោកអធិការតាមខ្ញុំ ! ខ្ញុំបង្ហាញទេវរូបត្បូងខ្មៅនោះអោយលោកបានឃើញ ។

លោកនាយកក្រោកនាំមុខអធិការគីរីវុធទៅកាន់បន្ទប់សំងាត់ ។ លោកបើកទ្វារ ហើយច្រានចូលទៅ ។

ក្នុងបន្ទប់ពោរពេញដោយបដិមាដ៏មានតំលៃ ជាស្នាដៃរបស់ដូនតាយើងបានច្នៃចេញពីមហាសម្បត្តិធម្មជាតិនៃប្រទេសយើង ។

បដិមាទាំងនោះមានរូបឈរ អង្គុយ ដេក ដែលជារូបព្រះពុទ្ធលោកេស្វរៈ ព្រះនារាយណ៍ដៃប្រាំមួយ ព្រះវិស្ណុ ព្រះព្រហ្ម ក្បាលមុខបួនជាដើម ។

អធិការគីរីវុធចាប់ចិត្តចំពោះរូបបូរាណវត្ថុជាកេតនភ័ណ្ឌជាតិក្រៃលែង ហើយក៏នឹកសរសើរចំពោះស្មារតីរបស់លោកនាយក

អភិរក្សអង្គរដែលមានស្នារតីក្នុងការថែរក្សាវត្ថុទាំងនេះ ។

លោកនាយកងាកមកនិយាយជាមួយគីរីវុធ :

-រូបទាំងនេះសាងឡើងពីថ្មភក់ទាំងអស់ ថ្វីត្បិតតែថ្មមាន សិរស់មិនល្អ តែតំលៃប្រវត្តិរបស់វាមិនអាចកាត់ថ្លៃបានឡើយ ។ ចំណែកទេវរូបត្បូងខ្មៅខ្ញុំបានរក្សាក្នុងទូដែកនេះ

លោកនាយកចង្អុលទូតូចមួយក្បែរនោះ ហើយចាក់សោរបើកខ្វាក !

គីរីវុធស្ទើរមិនជឿភ្នែកខ្លួនឯង ដោយនឹកស្មានមិនដល់ថាបុព្វបុរសកម្ពុជាកាលពីដើមអាចកសាងបាននូវអច្ឆរិយវត្ថុដ៏មានតំលៃសំបើមយ៉ាងនេះសោះ ។

ទេវរូបនេះពិតជាធ្វើអំពីត្បូងពណ៌ខ្មៅយង់ និងនៅខាងលើចិញ្ចើមមានដាំពេជ្រមួយគ្រាប់ប៉ុនមេជើង រះរស្មីភ្លឺច្រាលចេញមក។

គីរីវុធ ជញ្ជក់មាត់ :

-ទេវរូបនេះស្អាតណាស់ ! មានទំហំប៉ុនណាដែរលោក នាយក!

h=35cm P=80Kg

-កំពស់សាមសិបប្រាំសង្ទីម៉ែត្រ ទម្ងន់ប៉ែតសិបគីឡូក្រាម ។នេះជាប្រភេទត្បូងមរតកដែលពិភពលោកទាំងមូលរកត្បូងប៉ុននេះមិនទាន់បានទេ ! បើនិយាយពីតំលៃវិញថ្លៃស្មើប្រាសាទអង្គរ

ទាំងមូល !

-អស្ចារ្យណាស់ ! ទេវរូបនេះសាងឡើងដោយទេពកោសល្យផុតកំពូល មើលចុះរាងអង្គុយភ្នែនសមឥតខ្ចោះ ។

គីរីវុធយកកំទេចត្បូងមកផ្ទៀបមើល នាយលាន់មាត់ :

-យី ! ដូចគ្នាបេះបិតតែម្តង ! ពិតជាទេវរូបត្បូងខ្មៅទីពីរ ហើយ! ត្បូងនេះខ្ញុំទុកជាមួយទេវរូបនេះណាលោកនាយក ចាំកាលណារកទេវរូបទីពីរឃើញសឹមយកមកតំកល់នៅទីនេះទៀត

-បាទ ! អរគុណ ! កាលណាមានរឿងទាក់ទងនឹងវត្ថុបូរាណក្រសួងខ្ញុំក៏មានភារកិច្ចក្នុងការស្រាវជ្រាវដែរ ។

-ប្រសើរណាស់ ! សូមលោកនាយកជួយស្រាវជ្រាវបណ្តេញចោរលួចក្បាលអ្នកតានេះផងចុះ !

លោកនាយកចាក់សោរទូទៅវិញ ហើយបណ្តើរគីរីវុធមកកាន់ការិយាល័យវិញ ។

-អស់ការហើយ ! ខ្ញុំសូមលាលោកនាយកសិនហើយ ថ្ងៃក្រោយជួបគ្នា ។

អ្នកទាំងពីរចាប់ដៃគ្នាយ៉ាងរាក់ទាក់ ។ យ៉ានីក៏លើកដៃសំពះលាដែរ :

-នាងខ្ញុំជំរាបលាលោកសិនហើយ !

-បាទ ! សូមអញ្ជើញចុះ !

គីរីវុធ ជូនយ៉ានីទៅកាន់លំនៅដ្ឋានវិញ ទើបនាយអោយដំណឹងទៅភ្នាក់ងារមានសមត្ថកិច្ចស្តីពីការដកហូតយកកំទេចត្បូងពីថៅកែហាងមាស ។

ម៉ោងពីររសៀល ជាពេលដែលពិធីជប់លៀងអបអរថ្ងៃបុណ្យកំណើតរបស់នារតី ។

ភ្ញៀវបានមកដល់ជាបន្តបន្ទាប់ ហើយពិធីក៏ស្ថិតនៅក្នុងសភាពអ៊ូអរជាលំដាប់ ។

នារតីចេញមុខទទួលភ្ញៀវដែលជាមិត្តភ័ក្រ្តយ៉ាងរីករាយ នាងមិនខុសពីបុប្ផានាពេលព្រឹកព្រលឹមដែលសំបូរដោយទឹកសន្សើមនោះឡើយ ។

តែទន្ទឹមនឹងការសប្បាយនោះ នាងក៏មានភាពអន្ទះអន្ទែងណាស់ដែរ ព្រោះចាត់មិនឃើញគីរីវុធមកដល់សោះ ។

នាងទទួលភ្ញៀវបណ្តើរលើកនាឡិកាដៃមើលបណ្តើរ ។ ម៉ោងបីទៅហើយ ! ពិធីផ្លុំពន្លត់ភ្លើងទៀនកាត់នំជិតមកដល់ដែរ តែគីរីវុធនៅតែមិនទាន់មកដល់ ។

ពេលនេះតើ ក០០៥ កំពុងធ្វើអ្វី ?

ក្រោយពេលជូនយ៉ានីទៅដល់ផ្ទះហើយ នាយបំរុងស្រូត អោយទាន់ពិធីបុណ្យរបស់នារតីដែរ តែនៅពេលដែលនាយបើក ម៉ូតូកាត់មុខព្រះអង្គរធំ បដិមាធំស្ថិតនៅជ្រុងខាងត្បូងប្រាសាទ អង្គរ នាយបានប្រទះភ្នែកមនុស្សម្នាក់ ពួនលីបលពីក្រោយព្រះអង្គរធំ ។

ដោយការសង្ស័យ គីរីវុធបង្ហូសម៉ូតូទៅមុខបន្តិច ហើយ បញ្ឈប់ នាយចតម៉ូតូស្រួលបួលទើបរត់តំរង់ទៅកាន់ព្រះអង្គធំដោយ ពួនតាមគល់យ៉ាងធំៗ ។

នាយឈប់ងក់ព្រោះឃើញក្បែរគល់ចំបក់ដ៏ធំមួយ មនុស្ស ពីរនាក់កំពុងនិយាយជាមួយមនុស្សម្នាក់ផ្សេងទៀតទំនងជាអ្នក បញ្ជា ។ ជននោះស្លៀកពាក់យ៉ាងសង្ហា ហើយពាក់មួកបាំងមុខជិត ព្រមទាំងវ៉ែនតាមួយធំផង ម្ល៉ោះហើយនាយមិនអាចមើលមុខគេ ឃើញច្បាស់ឡើយ ។

គីរីវុធផ្ទាច់ខ្លួននឹងគល់យាង នាយប្រឹងក្រឡេកមើលអោយ ច្បាស់ នាយឃើញបុរសពាក់មួកនិយាយតិចៗ ដោយលើកដៃចង្អុល ផង ហើយពីរនាក់ទៀតងក់ក្បាលតាមញាប់ស្អេក ។ ពេលដែលជន ម្នាក់ក្នុងពីរនាក់ងាកមុខមកចំនាយ ទើបនាយស្គាល់យ៉ាងច្បាស់

គ្មានពីណាក្រៅពីឆោមសង្សារយ៉ានីឡើយ ។

-អ្ហា ! អាឆោមអាចជាឃាតកឬ ?

នាយគិតក្នុងចិត្ត ! អានេះហ៊ានសំលាប់ឪពុករបស់សង្សារផង ចំជាបីសាចក្នុងស្រោមមនុស្សមែន !

នាយស្ទាបកាំភ្លើងខ្លីនៅនឹងចង្កេះ ! តើគួរប្រលេះវាចោលឬ ?

មិនទាន់ដល់ពេលទេ បើសំលាប់វាចោលនៅពេលនេះ មិនអាចក្រសោបបណ្តាញរបស់វាបានទេ ហើយភស្តុតាងក៏មិនទាន់ប្រមូលគ្រប់គ្រាន់ដែរ ។ ប៉ុន្តែសំខាន់បំផុតគឺអាឆោមសង្សាររបស់យ៉ានី ចាំបាច់ត្រូវតាមវាអោយបានយ៉ាងប្រកិតបំផុត ។

ក្រោយពីជជែកគ្នាមួយសន្ទុះក្រោយមក ពួកវាក៏បែកគ្នាភ្លាមទៅតាមទិសរៀងខ្លួន !

ជនដែលទំនងជាមេគេដើរដោយរលះរលាំង ហាក់ខ្លាចគេមើលឃើញ ។ ឡើងដល់ថ្នល់កៅស៊ូភ្លាមម៉ូតូមួយ បានមកដល់ហើយបញ្ជិះវាចេញពីទីនោះភ្លាម ។

ចំណែកអាឆោម និងគ្នាវា ឥតបានចេញពីព្រៃទេ ពួកវាបាននាំគ្នាចូលទៅក្នុងព្រៃ ។

គីរីវុធចង់តាមដែរ តែនាយទុចជំហ៊ាន !

ពួកវាអាចរៀបអន្ទាក់ចាំប្រហារនាយចោលក្នុងព្រៃ ដោយគ្មានស្តាយស្រណោះ នាយមិនត្រូវរហន់ពេកទេ ។

គិតឃើញដូច្នេះនាយរត់តំរង់ម៉ូតូ ព្រោះនារតីកំពុងរង់ចាំនាយ ។

ម៉ោងបួនគត់ នាយបានមកដល់ផ្ទះនារតី សំលេងតូរ្យតន្ត្រីលាន់ខ្ទរខ្ទារទៅគ្រប់ទិស ។ ម៉ូតូឈប់ នារតីរត់ចេញមកពី ក្រោយនាងកញ្ញារចនារត់មកដែរ :

-បងវុធ ! បងឯងអញ្ជើញទៅណាបានជាបាត់យូរម្លេះ ?

-លោកអញ្ជើញទៅបាត់ដូច្នេះ អ្នកបងនារតីអន្ទះអន្ទែងមើលផ្លូវលោកផ្សាភ្នែកទៅហើយ !

គីរីវុធ ញញឹម :

-សួស្តី អ្នកនាងរចនា ! នារតី ! សូមអភ័យទោស ! បានជាមានការយឺតយ៉ាវព្រោះបងរវល់ពេក !

-ហ៊ឺស" នារតីឯងក់" ទោះជារវល់យ៉ាងណា ក៏បងគួរតែខានមួយពេលដែរ !

នៅពេលអ្នកទាំងពីរសាសងរកគ្នា កែវភ្នែករាប់សិបបាញ់

ឆ្គោះមករកគេ ពិសេសចំពោះគីរីវុធតែម្តង ។

-នារតី ! ឯណាមិត្តភ័ក្រ្តអ្នកដែលបងចង់ស្គាល់នោះ ?

នារតីយល់ពាក្យសង្សារ នាងចង្អុល :

-នុះ ! នៅតុនោះ !

គីរីវុធ ងាកញញឹមដាក់រចនាបន្តិច :

-សូមទោសអ្នកនាងរចនា ! សូមចាំមួយភ្លែកណា !

-ចាស់ ! មិនអីទេ !

គីរីវុធ ដើរទៅកាន់តុដែលពួកជើងល្អរៀនជាមួយនារតី គេ ត្រវាស់ខ្សែភ្នែកមួយត្រូស ... គ្មានឃើញអ្នកដែលធ្លាប់ជួបជាមួយ នាយសោះ ! បាននន័យថាពួកដែលតាមដាននាយមិនមែនចេញពី មជ្ឈដ្ឋានសិស្សវិទ្យាល័យសៀមរាបទេ ។

នាយបកមកវិញ :

-សូមទោស ! អ្នកនាងរចនា ! ឯណាបងនាង ?

-ចាស់ ! គាត់ឥតអញ្ជើញមកទេ !

-អូ ! ឥតមកទេ ! ម៉េចក៏ដាច់ចិត្តបដិសេធសេចក្តីអញ្ជើញ របស់នារតីអីចឹង !

-ចាស់ ! ខ្ញុំមិនដឹងដែរ ! ចាត់គាត់តាំងពីម្សិលមិញ ឥតឃើញ

មកផ្ទះទេ !

-បងអ្នកនាងប្រហែលជារវល់ក្នុងការរៀនសូត្រហើយមែនទេ

-ហ៊ី ! បងខ្ញុំនេះដើរលេងច្រើនណាស់ ! គាត់ឥតសូវរវីរវល់នឹងការរៀនសូត្រប៉ុន្មានទេ !

ក្នុងពេលអ្នកទាំងពីរកំពុងជជែកគ្នា នារតីស្រែកហៅ :

-បងវុធ ! អូនផ្លុំទៀនកាត់នំហើយណា !

-ផ្លុំទៅ អូនចាំអីទៀត ល្ងាចណាស់ហើយ !

ស្នូរទះដៃប្រាវលាន់ដូចលាជផ្ទុះ នារតីប្រាកដខ្លួនដោយសំលៀកបំពាក់ដូចទេពធីតាពីមុខតុចូលនាងញញឹមហើយ ប្រកាសៈ

-ប្រិយមិត្តជាទីរាប់អាន ! ខ្ញុំសូមថ្លែងអំណរគុណចំពោះបណ្ដាមិត្តទាំងអស់ដែលបានចូលរួមក្នុងពិធីចំរើនអាយុរបស់ខ្ញុំ ក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមផ្លុំទៀន និងកាត់នំដើម្បីចាប់ផ្ដើមកម្មវិធី !

ស្នូរទះដៃបន្តទៅទៀត នារតីផ្លុំទៀនអស់ នាងកាត់នំដាក់ចាស ហើយហុចជូនមិត្តទាំងអស់ដែលស្រែកជូនពរនាងទ្រហឹងអ៊ឹងអាប់ :

-សូមនាងមានសំរស់ដ៏ត្រកាល !

-សូមនាងស្ថិតក្នុងសុភមង្គល !

-សូមឆ្នាំថ្មីនាំដល់នាងនូវសុខមាលភាព !

-សូមនាងរីករាយជានិច្ចក្នុងយុវវ័យ !

សំលេងអោយពរទាំងនេះធ្វើអោយនាងនារតីញញឹមបិតមាត់មិនជិត ។ ចុងក្រោយបំផុតនាងហុចនំអោយគីរីវុធ ។ នាយទទួលនំហើយឱនថើបសក់របស់នារតី ស្គរទះដៃលាន់រំពងខ្លាំងបន្ទាប់មកគីរីវុធ ដឹកដៃនារតីហើយចូលរាំបើកឆាកជាការអញ្ជើញមិត្តទាំងអស់ឡើងរាំកំសាន្តនៃយុវវ័យរបស់គេ ។

ស្គរតន្ត្រីបានលាន់រងំជាមួយភ្លើងអគ្គិសនីផ្លាស់ពណ៌ជាញឹកញាប់ យុវវ័យ រីករាយឥតខ្វាយខ្វល់ពីអីឡើយ គេរាំកំសាន្តដើម្បីអនាគតរបស់គេ ។

ចង្វាក់ហៃ្សកម៉ានីសុន បានចប់ទៅជាមួយការស្តាយស្រណោះរបស់គូរាំ គេថយមកកាន់កន្លែងរៀងខ្លួន ។

នារតី អង្គុយតុជាមួយគីរីវុធ បបូរមាត់នាងញញឹមជាប់ មិនខុសពីស្រទាប់ផ្កាឈូកទើបចាប់ផ្តើមលាតរីកនៅពេលព្រះអាទិត្យរះឡើយ ។

ក្នុងពេលដ៏សែនសប្បាយ មានម៉ូតូមួយបានឈប់ពីមុខរោងពិធី នារីម្នាក់នាំខ្លួនល្វតល្វន់ចូលមក ។

គ្មានអ្នកណាយល់នាងទេ តែបូកខិលខូច ប្រុសពុប៉ុន្មាននាក់ប៉ុណ្ណោះដែលឱ្យបខៀវគ្នា ព្រោះគេស្គាល់នាងយ៉ាងច្បាស់

គីរីវុធ ភ្ញាក់ជាងគេ មិនស្មានថាអ្នកដែលដើរចូលមកជាអារីុសោះ នាយស្ទុះទៅជិតនាង ធ្វើអោយនារតីឆ្ងល់ក្រៃលែង ឆ្ងល់ផងខឹងផង ។

គីរីវុធ ទៅជិតនាងពោលតិចៗ :

-អារី ! មករកអ្នកណាអូន ?

នាងតបយ៉ាងរហ័ស :

-មករកបងឯងហ្នឹង !

-រកបង ! មានការសំខាន់ឬ ?

-ចាស់ សំខាន់ណាស់ !

ឮសួរថាសំខាន់ណាស់ គីរីវុធ ដឹកដៃនាងដើរចេញក្រៅឥតរវល់ពីភ្នែករាប់សិបដែលដោតមកលើនាយឡើយ ។

មកដល់ខាងក្រៅ អារី ពោលប្រាប់ថា :

-បង ! ដល់ពេលយើងចេញពីនោះហើយ !

-ទៅណា ?

-យប់នេះ វេលាទៀបភ្លឺម៉ោងបួន អូនត្រូវទៅទទួលរបស់មួយ

បន្តយកទៅភ្នំពេញ នៅប្រាសាទភិមានអាកាសពីមនុស្សម្នាក់ ។ គេបានអោយដឹងថារបស់នោះមានតំលៃណាស់ លក់បានរាប់កោដដុល្លា ! អូនគិតថាល្មមដល់ពេលយើងចេញពីរូងខ្លាហើយ បងកាលណាយើងទទួលរបស់នោះបាន អូននិងបងរត់ទៅស្រុកសៀមហើយរស់នៅជាមួយគ្នាដោយសារទ្រព្យដែលបានដោយលក់របស់នោះ បងពេញចិត្តទេ ?

គីរីវុធ ភ្ញាក់ដូចជាន់លើក្បាលពស់វែក ! ពួកជនទុច្ចរិតមានបំណងនាំយករបស់នោះទៅកាន់ក្រុងភ្នំពេញហើយតើ ! តើជាទេវរូបត្បូងខៀវឬក៏របស់អ្វីផ្សេងទៀត ! សំណាងល្អណាស់ ដែលនាយទាក់បាននាងមេអំបៅអារ៉ី កុំអីមិនងាយទេ ។

នាយសួរភ្លាម :

-អ្នកណាប្រាប់អូន ?

-ចាំះ សំបុត្រមួយដែលអូនទទួលនៅក្នុងបន្ទប់ដេករបស់អូន !

-អស្ចារ្យ ! នៅតែឥតស្គាល់អ្នកណាដដែល ! តែមិនជាបញ្ហាទេ ! ព្រោះយើងត្រូវការតែរបស់មានតម្លៃ ។

កំពុងតែជជែកគ្នា មានបុរសម្នាក់បានកំសៀកខ្លួនចេញពីចំណោមអ្នកចូលរួមក្នុងពិធីបុណ្យ ។

គីរីវុធ ឃើញយ៉ាងច្បាស់ នាយស្ទុះទៅយ៉ាងរហ័សហើយ

ទាញអាវជាប់ :

-នែ ! ប្អូន ! ពិធីមិនទាន់ចប់ផង ប្អូនឯងគិតទៅណាហ្នឹង ?

-ជននោះទ្រង់ញ័រមាត់បន្តិច និយាយតតាក់តតុប :

-ខ្ញុំមាន ... ធុរៈ ... បន្តិចត្រូវទៅផ្ទះអូន ...

អាការៈរបស់វាធ្វើអោយគីរីវុធសង្ស័យយ៉ាងខ្លាំង :

-ប្អូនឯងមិនទាន់ចេញទៅណាបានទេ !

-ម៉េចអីចឹង ?

-ត្រូវតែអីចឹង !

-ខ្ញុំនៅតែទៅ !

-បងនឹងឃាត់ !

បើវាជាជនដែលមានធុរៈ ធម្មតាមែននោះច្បាស់ជាវា និយាយរឿងរ៉ាវប្រាប់នាយមិនខាន ។ ក្នុងការសង្ស័យនាយយល់ថា វាពិតជាខ្សែបណ្ដាញពួកជនទុច្ចរិត ដូច្នេះចាំបាច់ត្រូវឃាត់ដំណើរ វា។

ជននោះមិនស្ដាប់ វានៅតែបោះជំហានចេញ តែគីរីវុធ អូសកអាវវាជាប់ ។

ភ្ញៀវក្នុងពិធីជប់លៀងផ្អើលឆោឡោរត់មកមើល តែគីរីវុធ លើកដៃប្រាប់ :

-សូមមិត្តទាំងអស់បន្តការសប្បាយចុះ ! គ្មានបញ្ហាអ្វីជាធំដុំ កំភួនទេ ! ខ្ញុំគ្រាន់តែឃាត់ខ្លួនជននេះអោយនៅកំសាន្តតទៅទៀត តែមិនព្រម ។

-អូ ! គ្រាន់តែប៉ុណ្ណឹងទេ ? ម៉េចមិនទៅលេងនឹងគេសិនទៅ ឯងបន្ទាន់ទៅណា !

ឃើញសភាពមិនអនុគ្រោះ ជននោះក៏ដើរបែបមាន់ជល់ ចាញ់ទៅកាន់ពិធីវិញ ។

បរិយាកាសបានប្រព្រឹត្តទៅជាធម្មតា តែអារ៉ុ គ្រាន់តែ ប្រាប់គីរីវុធ ហើយនាងគេចចេញទៅភ្លាមដោយបញ្ជាក់ថា :

-បងឯងកុំភ្លេចអោយសោះណា ! បើបងមិនធ្វើអន្តរាគមន៍ ទាន់ពេលវេលាទេនោះ យើងគ្មានវាសនានឹងបានរួមរស់ជាមួយ គ្នាទេ ហើយអូនក៏មិនអាចរស់នៅតទៅទៀតបានទេ !

-ហេតុអ្វីទៅ ?

-ចា៎ះ ! បងដូចជាល្ងង់ណាស់ ! វត្ថុដែលអូនទទួលអោយគេ មានតំលៃសំបើមណាស់ ហើយវាអាចីកំបាំងទៀតផង ដូច្នេះកាល

បើអូនយកទៅប្រគល់អោយគេហើយ ងាយអីគេនឹងបណ្តោយអោយអូនរស់នៅដឹងរឿងអាថ៌កំបាំងរបស់គេ ។

ពេលនោះផ្ទៃមេឃងងឹតទៅហើយ ហេតុនេះគ្មានអ្នកណាម្នាក់យកចិត្តទុកដាក់នឹងអ្នកទាំងពីរឡើយ ។

គីរីវុធ ច្របាច់ដៃនាងយ៉ាងណែន :

-បងយល់ហើយ ! បងនឹងទៅអោយទាន់ពេលវេលាមិនអោយអូនរងគ្រោះទេ ! ទុកចិត្តលើបងចុះ ! ទៅចុះអូន ទុកចិត្តហើយសង្ឃឹមថា បងនៅពីក្រោយអូនជានិច្ចណា ។

-ចាំះ ! អូនអរណាស់ ! យើងនឹងបានរស់នៅជាមួយគ្នាក្នុងពេលឆាប់ៗ នេះហើយ ! អូនលាហើយណាបងសំលាញ់ ។

នាងសុវណ្ណមយូរ៉ាជំទើតជើងថើបថ្ពាល់គីរីវុធ ព្រមទាំងទះមាត់នាយស្រាលៗ :

-ព្រលឹងអូនអើយ ! ក្លិននេះធ្វើអោយអូនស្រម័យឃើញបងរាល់រាត្រី !

-ព្រលឹងបង ! រូបកាយរបស់អូន បងគេងយល់សប្តិឥតដែលខានមួយពេលណាឡើយ ! អូនឯងប្រៀបដូចផ្កាយព្រឹកលំអផ្ទៃមេឃដូច្នោះដែរ !

អាវ៉ិ ងាកមុខចេញហើយរត់តំរង់ម៉ូតូរបស់នាងក្រោម ក្រសែភ្នែករបស់គីរីវុធ ។

ជាបន្ទាន់ភ្លាមនោះ គីរីវុធ រកកន្លែងស្ងាត់ហើយ ហៅតំរួត ជាបន្ទាន់ ។ គឺសហការីដែលតាមជាមួយនាយគ្រប់ជំហាន ។

គេឈរទីងងឹត ចង្អុលទៅបុរសដែលមានទំនាក់ទំនង អំបាញ់មិញប្រាប់ថា :

-ពេលចប់ពិធីជប់លៀង ត្រូវចាប់ខ្លួនអានេះយកទៅឃុំជាចាំ បាច់ ! អានេះពិតជាខ្សែបណ្ដាញពួកវាមិនខាន ?

-បាទ ! ៗ !

ពេលនោះផ្ទៃមេឃងងឹតមែនទែនហើយ នាយពោលមិន ទាន់ផុតពីមាត់ផង ជននោះក្រលេកនាយអាយ ហើយគេចភ្លែត ទៅដល់ទីងងឹតប្រុងនឹងរត់កាត់ថ្នល់ទៅម្ខាង ។

តែនៅពេលដែលវារត់ទៅដល់ទីងងឹត សំលេងមួយលាន់ ពីក្រោយវា ... គឺមនុស្សរត់តាម ... អានោះងាកក្រោយ ...។

-ផាំង ...

អានោះបែកអំពិលអំពែក ទំងន់មួយបានប៉ះលើកញ្ចាំងក របស់វា វាទទួលអារម្មណ៍ដូចយល់សប្ដិឃើញផ្កាយរះព្រោងព្រាត

ហើយដួលផ្កាប់មុខលើដី ។

-យិះ ! អានេះលឿនណាស់តើ ! ឯងផ្តាំមិនទាន់ចប់ផង វា ប្រុងរត់ចេញភ្លាម ! នែ ! នាយឯងយកវាទៅឃុំសិនទៅណា ! ហើយសួរចំលើយវាអោយមែនទែន រួចបញ្ជូនអោយខ្ញុំផងណា !

-បាទ ! ទទួលបញ្ជា !

ផ្លេកបន្ទោរវាត់ឆ្វាច់ យើងឃើញស្រមោលមនុស្សម្នាក់ រត់ចេញពីនោះទៅយ៉ាងលឿន ។

គីរីវុធ ដើរមួយៗ ត្រឡប់មកកាន់ពិធីជប់លៀងវិញ ។

ពេលវេលាហោះលឿនទៅមុខឥតអាក់ ម៉ោងជប់យប់ ពិធីជប់លៀងត្រូវបញ្ចប់ ភ្ញៀវទាំងឡាយបានបែកខ្ញែកគ្នារៀងខ្លួន ចុងក្រោយបំផុត គីរចនា ដែលលាគីរីវុធយ៉ាងយកចិត្តទុកដាក់ ។

គីរីវុធ ជូនដំណើរនាងដល់មាត់ទ្វាររបង ហើយផ្តាំថា :

-មានពេលទំនេរឱស្សាហ៍មកលេងនឹងខ្ញុំផងណា !

-ចាំះ ! លោកក៏អីចឹងដែរ ថ្ងៃណាមួយខ្ញុំមកអញ្ជើញលោក ទៅពិសាបាយផ្ទះខ្ញុំម្តង !

-អរគុណ ! អ្នកនាងណាស់ ! ខ្ញុំប្រាកដជាទៅតាមសេចក្តី អញ្ជើញមិនខាន !

រថនាចេញផុតទៅ ! គីរីវុធ ស្លៀកពាក់យ៉ាងប្រញាប់ ដោយមានអាវុធសំខាន់ៗយកទៅជាមួយផង ព្រោះនាយយល់ថាបន្តិចទៀតនេះឆាកប្រយុទ្ធមួយមានលក្ខណៈស៊ីសាច់ហុតឈាមច្បាស់ជាកើតឡើង ។

នារតី អស់កំលាំងព្រោះរវល់ពេញមួយថ្ងៃ លុះឃើញ គីរីវុធ ស្លៀកពាក់ទាំងកណ្តាលយប់យ៉ាងចំលែកដូច្នេះនាងឆ្ងល់ក្រៃលែងៈ

-បងឯងទៅណាហ្នឹង ?

គីរីវុធ រឹតខ្សែក្រវ៉ាត់ប្រាប់ថា :

-ការងាររបស់មនុស្សប្រុស ប្រាប់អូនមិនបានទេ !

-ការងាររបស់មនុស្សប្រុស តែមានពេលខ្លះមនុស្សស្រីអាចធ្វើបានដែលណាបង !

-តែការអាថ៌កំបាំងមនុស្សស្រីមិនបាច់ដឹងទេ ព្រោះ ...

-បងគ្មានគំនិតមើលងាយមនុស្សស្រីទេ បងនិយាយការពិតណា !

-បានហើយ ៗ ! បងមិនប្រាប់ខ្ញុំទេក៏ហីទៅ !

-កុំខឹងអី ! បងសូមទោសចុះ មិនអាចប្រាប់អូនបានទេ បងលាហើយណា ! អូនគេងអោយស្ងប់ចុះ ថ្ងៃស្អែកបងនឹងវិលមក

វិញនាំដំណឹងល្អអោយអូនផង !

-បានហើយ ៗ ! ដំណឹងល្អរបស់បងឯង គ្មានអ្វីក្រៅពី ចាប់គេចងនោះទេ !

-យ៉ាងម៉េច ! អូនកាន់ជើងពួកទុច្ចរិតឬ ?

-ទេ ! អូនឥតកាន់ជើងទេ ! តែដំណឹងល្អរបស់បងគឺសុទ្ធតែរឿងអីចឹង !

-ចុះ ! បងបានដំណឹងតែអីចឹង មានតែប្រាប់អីចឹងទៅ នោះមកពីបងឥតកុហក ! បងលាហើយ !

គីរីវុធ ថើបសក់សង្សារយ៉ាងយូរ :

-ជំរាបម៉ាក់អ៊ំផងណា !

-ចា៎ះ !

-សក់អូនក្រអូបណាស់ ! នាងសក់ក្រអូប !

-ខ្ពើមណាស់ ! កុំសូវវោហាបញ្ឆោរអូនពេក អូនមិនជោរដូចចេកខ្ចីទេ !

គីរីវុធ ញញឹម ហើយបោះជំហានចេញទៅក្រោម ជំនោរនៃរាត្រីកាល ។ ស្បៀមហាន្ធកាលបានលេបយករូបនាយបាត់ទៅ ។

~៥~

ផ្ទៃមេឃងងឹតឈ្លុបស្ទើរចាក់ភ្នែកមិនយល់ យូរៗផ្លេកបន្ទោរវាសឆ្វាច់ៗ កាត់លំហអាកាសទើបអាចមើលឃើញធម្មជាតិស្ងាត់ជ្រងំ ។

សំលេងចង្រិត ទីទុយ មៀម យំប្រណាំងគ្នាទ្រហឹងអឹងអាប់។

សំលេងឡានបន្លឺឡើង ហើយរត់កាត់តាមផ្លូវចាក់កៅស៊ូក្នុងបរិវេណឧទ្យានអង្គរ រមណីដ្ឋានដ៏ប្រណិតរបស់ជនជាតិខ្មែរ ។

តួប្រាសាទភិមានអាកាស ខ្ពស់ត្រដែតបង្ហាញស្រមោលខ្មៅស្ដង់ដូចតួអសុរាក្នុងរឿងព្រេងនៃប្រទេសនានាក្នុងសកលលោក។

មិនយូរប៉ុន្មានផ្ទៃមេឃប្រែជាស្រទ្បះ ចាប់ផ្ដើមមានពន្លឺព្រឿងៗឡើងវិញជាសញ្ញាថាជិតភ្លឺហើយ ខ្យល់ជំនោរបក់រហើយនាំទាំងធាតុត្រជាក់មកផង តែធម្មជាតិនៅស្ងាត់ជ្រងំនៅឡើយយូរៗម្ដងទើបឮសំលេងខ្លែងស្រាកបង្ហូកគួរព្រឺក្បាល ។

តួប្រាសាទនៅកណ្ដាលទ្រូងព្រៃស្រោងស្ងាត់ជ្រងំគួរព្រឺខ្នង។

រំពេជនោះ ស្នូររថយន្តមួយបានបន្លឺឡើង ហើយបន្តិចក្រោយមក រថយន្តរ៉ុលវ៉ាហ្គែនមួយបានមកឈប់ពីមុខតូប្រាសាទ

សភាពបរិយាកាសនៅងងឹតឈ្លប់ យើងមិនអាចដឹងថាឡាននោះពណ៌អីទេ ហើយក៏មិនអាចមើលលេខឃើញដែរ ។

ស្នូរសំលេងបុរសម្នាក់បញ្ជា :

-នាងឡើងទៅលើប្រាសាទនោះ ហើយនឹងបានជួបមនុស្សម្នាក់ ។ នាងមិនបាច់និយាយអីទេ ទៅដល់សូមនាងកេះដែកភ្លើងចំនួនបីដងបង្ហាញគេដោយកុំអោយឆេះអោយសោះ អោយមានតែផ្កាភ្លើងបានហើយ ! ពេលនោះគេនឹងប្រគល់វ៉ាលីមួយអោយនាង សូមនាងទទួលយកមកភ្លាម ខ្ញុំចាំនៅទីនេះ ... ។

-ចាស់ !

ស្នូរចំលើយរបស់នារីព្រមជាមួយនឹងទ្វារឡានរបើក ហើយស្រមោលតូចស្ដើងមួយរសាត់ចេញពីរថយន្ត ។

ពេលដែលស្រមោលតូចស្ដើងនោះរសាត់យ៉ាងលឿនទៅកាន់ប្រាសាទ ស្រមោលមនុស្សម្នាក់ទៀតបានលួនចេញពីកម្ពោជព្រៃហើយសំដៅទៅកាន់រថយន្តតូចនោះយ៉ាងរហ័ស ។

ទិដ្ឋភាពនៅពេលនោះមិនខុសពីផ្លូវខ្មោចឡើយ សូម្បីតែ

សំលេងខ្យល់បក់ក៏គ្មានផង ។

ស្រមោលអាថិកំបាំងលូនយ៉ាងរហ័ស ហើយបានមកឈប់ពីក្រោយរថយន្ត ។

ទំនងជាអ្នកបើកបរដែលនៅក្នុងឡានឥតដឹងខ្លួនទេ បានជាគ្មានប្រតិកម្មអីសោះ ។

ស្នូរ " ប៉ូកពុំ " លាន់ឡើង គឺសំលេងគេគោះតួរថយន្ត

-អ្នកណាហ្នឹង !

សំលេងអ្នកបើកបរសួរដោយភ្ញាក់ ហើយវាច្រានទ្វារឡានស្ទុះចេញមកដោយភ្ជង់កាំភ្លើងទៅមុខផង ។

-អ្នកណា ! ...

នាយស្រែកបានតែប៉ុណ្ណោះក៏ត្រូវគាំងស្មេញដោយមានដៃមួយរឹងដូចដង្កាប់ចាប់បំពង់កវាជាប់ ។ វាបែរបំរះហើយទធាក់ផងងដៃរបស់វាច្បាមមកក្រោយរកចាប់អ្នកដែលរឹតបំពង់កវា ។

កាំភ្លើងនៅនឹងដៃវា ប្រុងផ្ទុះទៅហើយ តែជនដែលគៀបបំពង់កវានោះបានកញ្ឆក់យកកាំភ្លើងនោះភ្លាម ។

ការប្រវាយគ្នាយ៉ាងស្ងៀមស្ងាត់ប្រព្រឹត្តទៅមួយស្របក់ជនដែលនៅចាំក្នុងរថយន្តត្រូវសន្លប់ដោយសារចាញ់កំលាំងជន

មកដល់ក្រោយ ។

ឃើញខ្លួនមានជោគជ័យហើយ ជនមកដល់ក្រោយបើកទ្វាររថយន្តតិចៗ ហើយចាប់ក្របួចកអាវ អ្នកបើកបររុញបញ្ចូលទៅមុខ ទើបខ្លួនគេរំកិលខ្លួនចូលទៅអង្គុយកន្លែងអ្នកបើកបរធ្វើព្រងើយ ។

លុះរួចរាល់ហើយ ជននោះស្រាយខ្សែដែលគេ ដាក់ជាប់នឹងខ្លួនចងអ្នកបើកបរជាប់ ហើយយកកូនកន្សែងដៃចុកមាត់វា ។ នេះជាមធ្យោបាយកុំអោយវាស្រែកនៅពេលវាដឹងខ្លួន ។

ខ្យល់បក់ហ៊ូៗ ជាសញ្ញានៃពេលជិតភ្លឺហើយ ជននោះនៅអង្គុយជ្រងុកចាំនារីវិលត្រឡប់មកវិញដោយអន្ទះសា ។

យូរៗគេលើកនាឡិកាដៃមើលពន្លឺហ្វូសស្វ័របង្ហាញយ៉ាងច្បាស់ ម៉ោងបួនម្ភៃនាទី ។

-នាងទៅទទួលរបស់គេយូរសំបើមម្ល៉េះ ? នាងជួបគ្រោះថ្នាក់ទេដឹង ?

កំពុងតែគិតទន្ទឹងមើលផ្លូវ នាយឃើញផ្កាភ្លើងផ្ទុះឡើងផែសៗ បីដងជាសញ្ញា ហើយបន្តិចក្រោយមកស្រមោលស្តើងមួយក៏រសាត់តាមកាំជណ្តើរប្រាសាទចុះមកក្រោមយ៉ាងលឿន ។

ស្នូរវថយន្តបញ្ឈប់តិចៗ ចាំជាស្រេច ។

ស្រមោលតូចស្តើងរសាត់យ៉ាងលឿនដោយមានយួរ វ៉ាលីសយ៉ាងធ្ងន់មួយផង ។

ដំណើររាងយឺតៗ ហាក់ដូចជាប្រឹងសំបើមណាស់ ។

ទីបំផុតស្រមោលនោះបានមកជិតឡាន :

-អារី !

-អ្នកណាហ្នឹង ? បងឬ ?

-ហ្នឹងហើយបង !

-ចុះអាបើកឡាន !

-វានៅក្បែរយើង ! ទើបឡានលឿនទើបមេឃភ្លឺឥឡូវ ហើយ។

ផ្ទៃមេឃភ្លឺកាន់តែច្បាស់ ហើយអារីហុចវ៉ាលីសអោយទៅ គីរុធ ហើយបើកទ្វារឡាន ។ ... តែ ...

-ប៉ុង ! ... ស្នូរគ្រាប់កាំភ្លើង !

-អូយ !

តួរាងកាយតូចស្តើងរបស់អារី ដួលទ្រប់លើឡានជាមួយ សំលេងដង្ហើយយ៉ាងខ្លាំង :

-អារ៊ី ! យ៉ាងម៉េចហ្នឹងអូន ?

-ប៉ុង ! ប៉ុង ! សំលេងគ្រាប់កាំភ្លើងលាន់ឡើងជាបន្តទៀត ! គ្រាប់កាំភ្លើងហើរមកទង្គិចតួររថយន្តលាន់ផាំងៗ ...។

គ្មានពេលគិតពិចារណាសួរហេតុផល គីរីវុធធាក់ទ្វារឡានម្ខាងហើយអោបវ៉ាលីសប្រមៀលខ្លួនចុះពីឡានក្រាបជាបន្ទាន់ ។

-ប៉ុង ! ៗ ! ស្នូរកាំភ្លើងបាញ់មកទៀតឥតអាក់ ។ តែពេលនេះគីរីវុធ មានស្ថានភាពការពារខ្លួនស្រួលបួល នាយរលាស់អាវុធសំឡាញ់ចិត្តចេញក្រៅហើយបាញ់តបវិញភ្លាម ...។

-ប៉ុង ! ៗ ! ៗ !

ស្នូរកាំភ្លើងឆ្លើយឆ្លងគ្នាជាមួយនឹងពណ៌ក្រហមនាពេលព្រឹកបានលេចឡើងនាជើងមេឃខាងកើត ។

ពួកវាបាញ់មកខ្លាំងពេក មិនអាចអោយនាយនៅជិតឡានបាន ។

ឆ្លៀតពេលដែលបាញ់ចេញទៅ នាយដកយកទូរស័ព្ទឥតខ្សែសំរាប់ចារកម្មមកប្រើ ហើយហៅស្នងការភ្លាម :

-អាឡូ ! ក០០៥ ត្រូវការជំនួយនៅប្រាសាទភិមានអាកាសអស់!

នាយនៅតែបាញ់តបវិញ តែកំលាំងកាំភ្លើងរបស់នាយ

ចាញ់ពួកជនទុច្ចរិតទេ ដោយពួកវាមានគ្នាច្រើនជាងនាយ ។

ចាំបាច់ត្រូវតែដកឃ្លាមួយរយៈ តែនាយមិនអាចដើបរត់បានឡើយ ព្រោះជាប់វ៉ាលីសដ៏ធ្ងន់ ម្ល៉ោះហើយការតាមជាចាំបាច់ គ្រាប់របស់នាយក៏មិនអាចអោយនាយបាញ់ពួកវាដោយសេរីបានដែរ ព្រោះវាមានមាត់ ម្ល៉ោះហើយបើនាយប្រើវាអស់ នាយនឹងត្រូវបរាជ័យមួយរំពេច ។

កំពុងតែគិតស្រមោលមួយលូនយ៉ាងរហ័សតំរង់ឡាន ... វាច្បាស់ជាទៅដោះលែងគ្នាវាហើយ !

-គីរីវុធ តំរង់ត្រៃកាំភ្លើង ...

តែដូចជាគ្មានលទ្ធភាពល្មមបាញ់វាអោយត្រូវណាស់ !

...ចុងក្រោយបំផុតវាដើបបើកទ្វារឡានហើយអូសជើងអាជាប់ចំណងចេញមក ...

ពីចំងាយ គីរីវុធមើលមុខវាមិនច្បាស់សោះបានន័យថាមិនក្រសោបពួកវាបានទេ !

អានោះរួចពីចំណង គ្រាប់កាំភ្លើងនៅតែបាញ់មករកនាយដដែល ...។

អធិការ ក០០៥ បង្ខំចិត្តដេកក្រាបការពារវ៉ាលីសឥតហ៊ាន

កំរើកខ្លួន ។

គ្រាន់តែរំដោះគ្នាបានភ្លាម ពួកវាចាប់ផ្ដើមបាញ់ដកឃ្លាភ្លាមមួយរំពេច ។

គីរីវុធ រង់ចាំជំនួយយ៉ាងអន្ទះអន្ទែង ...។

ហេតុម្ដេចក៏យូរម្ល៉េះ ...។

អត់មិនបាន នាយបាញ់តបវិញ ... តែមួយៗ ...

ស្នូររថយន្តហ៊ីប្របន្លឺកាន់តែជិត :

-កនយើងរត់ ! ...

ពួកវាដកឃ្លារត់ចូលព្រៃហើយ គីរីវុធ ក្ដៅក្រហាយក្រៃលែងនាយចង់ដេញតាមណាស់ តែទាល់ត្រង់វាលីសទេរូបមិនអនុញ្ញាតនាយឡើយ ។

នៅពេលដែលទ្បានហ៊ីប្រជំនួយមកដល់ ពួកវាបានគេចខ្លួនចូលព្រៃអស់ ។

ផ្ទៃមេឃចាប់ផ្ដើមភ្លឺច្បាស់មែនទែនហើយ ! គីរីវុធ ក្រោកឈរបោសធូលីដែលប្រទ្បាក់ស្រមក ។

អ្នកដែលនាយយកចិត្តទុកដាក់ជាងគេគឺ អារ៉ា ! តើនាងទទួលវាសនាបែបណាទៅហើយ ?

នាយបោះជំហានតំរង់តួឡាន ភ្នាក់ងារមានសមត្ថកិច្ច គោរពនាយ :

-សូមគោរព លោកអធិការ តើមានកិច្ចការអ្វីត្រូវធ្វើទៀត !

គីរីវុធ គោរពតបវិញ :

-លោកនាំយកឡាននេះទៅកាន់ស្នងការដ្ឋាន ហើយឆាប់រកមធ្យោបាយស្រាវជ្រាវរកម្ចាស់របស់វាអោយឃើញ ! នៅសល់ប៉ុន្មាននាក់ចាំទៅជាមួយខ្ញុំ !

-ទទួលបញ្ជា !

ភ្នាក់ងារទទួលបញ្ជា បញ្ឆេះឡានវ៉ុលវ៉ាហ្គែនដែលគ្មានលេខហើយរោទិ៍ម៉ាស៊ីនបោះពួយចេញបាត់ទៅ !

ខ្យល់ស្លឹកឈើបក់ប្រាវៗ ពន្លឺព្រះអាទិត្យបានចាំងចេញពីចំណិតព្រះទិនករ ទើបនឹងលេចបានពាក់កណ្ដាលពីជើងមេឃ បង្កជាទិដ្ឋភាពដ៏ស្រស់ត្រកាល ។ គីរីវុធ ឱនក្បាលលុតជង្គង់ចុះ ក្បែររូបកាយស្ដូកស្ដឹងរបស់នារីម្នាក់ គ្មាននរណាក្រៅពីនាងមេអំបៅមាសអារ៉ុនឡើយ ។

នាយចាប់ដៃនាងស្ទាបជីពចរ ឃើញខ្សោយណាស់ទៅហើយ ! បបូរមាត់របស់នាងឡើងស្វាយស្លក ឈាមកកប្រឡាក់

អាវរូតខ្ទង់ម្ដុំបោះដៃផុត ។

-អារុំ ! អារុំ ! " នាយជ្រូនហៅនាងតិចៗ " ។

ក្រៅពីដង្ហើមផ្ដឹកៗ នាយគ្មានបានទទួលចំលើយពីនាងឡើយ ។

ភ្នាក់ងារមានសមត្ថកិច្ច ដែលមកជួយនាយឈរស្ងៀមស្ងើរមិនហ៊ានដកដង្ហើម ។

គីរីវុធ អធិការក្រោមលេខសំគាល់ ក០០៥ ត្រកងប្រាណនារីអភ័ព្វឡើងហើយបោះជំហានសំដៅទៅកាន់រថយន្ត ដោយងាកមកបញ្ជាថា :

-សូមលោកយកវ៉ាលីសនោះដាក់ឡានផង នោះជាទេវរូបហើយ ...។

នាយងាកមកវិញនៅពេលដែល បបូរមាត់អារុំហើបញ័រៗហាក់ចង់និយាយ តែឈាមមួយដុំខ្ពុរចេញមកនាយត្រេកអរណាស់:

-អារុំ ! អារុំ ! អូនដឹងខ្លួនហើយឬ ?

នារីរងគ្រោះត្រលប់ភ្នែកបញ្ឈរដោយអាការៈហេវហត់ហើយសំលេងខ្សាវៗ :

-បង ! បងឬ ? ... ឯ... ណា... របស់... មាន... តំលៃ...

បងយក... បាន... ហើយឬ ?

-បងយកបានហើយ ! អូនឈឺចាប់ណាស់មែនទេ អារី ?

-ទេ !... អូន... សប្បាយ... ចិត្ត.... ណាស់... តស់... បង... យើង... នាំគ្នា...ទៅរស់...នៅ... ឯស្រុក... សៀមតែ... ពីរនាក់ ... ណាបង...។

-ត្រូវហើយ ! បងនឹងជូនអូនទៅ ! អូនកុំខំនិយាយពេក !...

-ទេ ! អូនត្រូវ... តែ... និ... យាយ... ព្រោះមួយជីវិត... នេះ... អូន... ដែល... ទទួល...ការថ្នាក់... ថ្នម... ពីគេ... ដូចរូប ... បងទេ...! អូន... ស្រឡាញ់.... បង... អូនចង់រស់... ក្បែរ... បង... ទៅ... បង... យើង... ឆាប់ចាក... ចេញពី... ទីនេះ... ហើយយក... របស់នោះ... ទៅផង...យើង... រស់នៅ... ជាមួយគ្នា... ណា... បង...

ជាមួយនឹងពាក្យបង នាងខ្ពុរឈាមថែមទៀតប្រឹងត្រដរ ខ្យល់ដកចង្ការមាន់ ហើយបាក់កទៅម្ខាងលើរង្វង់ដៃរបស់គីរីវុធ ដែលមិនទាន់ដាក់នាងចុះនៅឡើយ ។

នាងលាចាកលោកទៅហើយ ដោយសង្ឃឹមថានាងនឹង អាចរស់នៅដោយសុខសាន្តលើទ្រព្យដែលជាវត្ថុមានតំលៃដែល

នាងប្តូរជីវិតដណ្តើមមកបាន ។

-អារ៉ុ ! អារ៉ុ ! អូនស្លាប់ហើយ ! ...

គីរីវុធ ស្រែកខ្លាំងៗ ថ្វីត្បិតតែនាយគ្មានមនោសញ្ចេតនាស្នេហ៍ត្រង់នឹងនាងក៏ដោយក៏នៅចំពោះស្នេហាភក្តីរបស់នាងចំពោះនាយពេលនេះធ្វើអោយនាយរញ្ជួយចិត្តដោយអាណិតអាសូរក្រៃលែង ។

នាយបិតភ្នែកអោយនាង ហើយដាក់នាងចុះលើដីយកសំពត់គ្របអោយនាង ។

ខ្យល់បក់ហ៊ូៗ ហាក់ដូចជាសំរែកដង្ហោយហៅរបស់យមភូបាលនាំដួងវិញ្ញាណរបស់នារីកំសត់ទៅកាន់ឋាននាយឆ្ងាយឥតទីកំណត់ ។

គីរីវុធ ឈរស្ងឹងស្ងាធ ជូនដំណើរវិញ្ញាណក្ខន្ធនាងទៅកាន់សុគតិភព ។

-អារ៉ុ ! អូនស្លាប់ហើយ ស្លាប់ដោយបានជួយបំពេញបេសកម្មយ៉ាងធំធេងដល់បង ជាតិមិនភ្លេចពលីកម្មថ្លៃថ្លារបស់អូនទេ ! សូមវិញ្ញាណក្ខន្ធអូនទៅកាន់សុគតិភពកុំបីអាក់ខានឡើយ ។

បន្ទាប់មកនាយងាកទៅកាន់ភ្នាក់ងារមានសមត្ថកិច្ច :

-លោក ! មើលជួយបញ្ចុះសពរបស់នាងនៅទីនេះហើយ !

-បាទ ! ទទួលបញ្ជា !

មិនយូរប៉ុន្មានផ្នូរមួយក៏បានកើតឡើងក្រោមម្លប់ស្រឡៅដ៏ត្រឈឹងត្រឈៃ ។ គីរីវុធ យកចុងកាំបិតស្មៀតឆ្លាក់លើដើមស្រឡៅថា :

-ផ្នូរនាងអារ៉ី ! នារីកំព្រា !

កិច្ចការហើយស្រេច អធិការ ក០០៥ បានឡើងជិះលើរថយន្ត ចាកចេញពីប្រាសាទភិមានអាកាសក្រោមសំលេងថ្ងូចថ្ងូររបស់វាតាដែលមានវិស័យដូចសំលេងយំសោកអាលោះអាល័យរបស់សពនាងអារ៉ីឡើយ ។

រថយន្តបោះពួយទៅមុខយ៉ាងលឿន គីរីវុធ ស្ទាបវ៉ាលីសដែលដាក់ទេវរូប នាយនឹកថាបេសកម្មរបស់នាយបានចប់មួយដំណាក់ហើយ ។ នៅមួយដំណាក់ទៀត គឺការចាប់ចងជនដែលបានចូលរួមក្នុងអំពើឧក្រិដ្ឋធ្វើឃាតលើរូបអ៊ំយន់ ! អ៊ំចាន់ និងអារ៉ី

រថយន្តបានឈប់ពីមុខស្នងការដ្ឋានពេលម៉ោងជិតប្រាំបីទៅហើយ ។ លោកមេបញ្ជាការស្ទុះចេញមកទទួល :

-សួស្តីលោកអធិការ ! ដំណើរលោកបានជោគជ័យឬ ?

គីរវុធ ចាប់ដៃលោកមេបញ្ជាការ ដៃម្ខាងទៀតយូរវ៉ាលីស : ទេវរូបដណ្តើមបានហើយ ! តែគួរអោយអាណិតអារ៉ិ ដែលជួយយើងត្រូវស្លាប់ !

-លោកឥតចាប់ពួកជនទុច្ចរិតបានម្នាក់ទេឬ ?

-គួរអៀនខ្មាសណាស់ ! ដោយមេឃងងឹតពេកពួកវារត់គេចខ្លួនអស់ រកចាប់មិនបានទេ ម៉្យាងទៀតក្រុមជំនួយទៅមិនទាន់ពេលផង !

លោកមេបញ្ជាការទះស្មានាយល្ងង់លោម :

-មិនអីទេ ! សំខាន់ គឺយើងខ្លាចទេវរូបឆ្លងដែនទៅកាន់ប្រទេសក្រៅ ! ត្រង់មនុស្សយើងអាចក្រសោបចាប់នៅពេលណាក៏បានដែរ !

-តើឡាន រ៉ុលវ៉ាហ្គែន ជារបស់អ្នកណាដែរ ?

-រឿងនេះពិបាកសន្និដ្ឋានណាស់ ! ព្រោះពីម្សិលមិញម៉ោងប្រាំល្ងាច លោក អ៊ិន ស៊ិន់ បានមកប្តឹងថា ចោរបានលួចឡានរ៉ុលវ៉ាហ្គែនរបស់លោក ដូច្នេះយើងមិនទាន់ហ៊ានសន្និដ្ឋានថាម្ចាស់រថយន្តគឺលោក អ៊ិន ស៊ិន់ បានចូលរួមក្នុងរឿងនេះ ឬក៏យ៉ាងណាទេ ?

-តែលោក ស៊ន់ ត្រូវតែជាប់ក្នុងការអង្កេត និងតាមដាន !

-រឿងនេះខ្ញុំបានចាត់ចែងអស់ហើយ !

-ឥឡូវយើងត្រូវធ្វើកំណត់ហេតុ និងថតរូបទេវរូបទុករាយការណ៍ទៅថ្នាក់លើ ។

អ្នកទាំងពីរបោះជំហានចូលក្នុងការិយាល័យ ។ គីវរុធចុចគន្លឹះវ៉ាលីសហើយលាចេញ ... ខ្សែភ្នែករបស់លោកមេបញ្ជាការនិងបុគ្គលិកទាំងអស់ផ្តោតលើរូប ...។

វត្ថុមួយរុំក្រដាសយ៉ាងក្រាស់ ... ច្បាស់ជាទេវរូបហើយ

គីវរុធ លើកបីរូបនោះ នាយធ្វើភ្នែកស្លឹសម្លឹងលោកមេបញ្ជាការ :

-មានរឿងអីឬ លោកអធិការ បានជាធ្វើភ្នែកស្លឹអីចឹង ?

-បាទ ! ដូចជាចំលែកណាស់ របស់នេះដូចជាដុំរាងបួនជ្រុងទ្រវែង !

-លោកស្រាយក្រដាសចេញទៅ !

គីវរុធ ហែកក្រដាសខ្វាកៗ យ៉ាងរហ័ស ... ទីបំផុត...

-អ្ហា ! ដុំថ្មទេតើ ?

ទាំងអស់គ្នាលាន់មាត់ស្រឡាំងកាំង ! មែន ! របស់ដែល

គេរាល់គ្នាសន្និដ្ឋានថាជាទេវរូបនោះជាការយល់ច្រឡំ ព្រោះនេះជាដុំថ្មសាមញ្ញដែលគេធ្វើរាងដូចរូបមនុស្សអង្គុយអីចឹង ។

លោកមេបញ្ជាការអស់បើគិត គាត់សើចហាសៗ...

-យី ! លោកអធិការ ! ម៉េចក៏យកដុំថ្មរុំក្រដាសអីចឹង ?

គីរីវុធ ស្ទើរបោកក្បាលបំបែកនឹងជញ្ជាំង :

-យីះ ! ពួកអាចង្រៃទាំងនេះវាលេងសៀ្សតដាក់អញផង ! ស្ដាយណាស់ ! មិនគួរភាន់ស្មៀតចាញ់បោកពួកអាដែងនេះសោះ

គីរីវុធ បោកដុំថ្មនោះទៅនឹងដីដោយហ្មួហ្មង :

-នឹកអាណិតអារ៉ុ ! នាងស្មានថារបស់មានតំលៃហើយ បានជាប្រថុយជីវិតដល់ថ្នាក់ស្លាប់យ៉ាងនេះ !

-លោកអធិការ " លោកមេបញ្ជាការនិយាយ " ក្នុងពេលដែលយើងយកដុំថ្មនឹងមក ពួកវាប្រហែលជាបណ្ដោះទេវរូបត្បូងខ្មៅទៅទៀតហើយមើលទៅ ?

-ប្រាកដជាអីចឹងហើយ ! តែតើយើងធ្វើម្ដេចទៅ បើបណ្ដាញពួកវាយើងរកមិនទាន់ឃើញនៅឡើយ ? ឬក៏ត្រូវប្រមូលពួកសង្ស័យទាំងប៉ុន្មានមកសួរចំលើយ ? លោកមេបញ្ជាការ ចុះពួកអាបីនាក់ដែលចាប់បានពីថ្ងៃមុន និងអាម្នាក់ដែលចាប់ពីល្ងាចមិញ

វាមានឆ្លើយថាដូចម្ដេចទេ ?

-គ្មានសោះ ! អាបីនាក់ថ្ងៃមុននោះវាសារភាពថា វាជាពួកយួកួងមែន តែឥតបានទាក់ទងនឹងរឿងឃាតកម្ម និងការរត់ពន្ធទេវរូបយកទៅក្រៅទេ ។ ចំណែកអាដែលចាប់យប់មិញ វាបានឆ្លើយថារឿងរ៉ាវទាំងអស់វាឥតបានទទួលផ្ទាល់ពីគេទេ គឺថាវាបំរើពួកនេះមែន តែវាឥតស្គាល់អ្នកដើមគំនិតជាអ្នកណាឡើយ ?

-ចំលែកណាស់ ! តាមសំដីពួកអាវ៉ុ ក៏បានប្រាប់ខ្ញុំដូច្នេះដែរ គឺថាពួកវាឆ្លើយឆ្លងគ្នាតាមរយៈសំបុត្រប៉ុណ្ណោះ ! គិតទៅពួកវាមានផែនការបណ្ដាក់គ្នាល្អណាស់ ហើយពោពេញដោយអាថ៌កំបាំងទៀតផង !

-រួចតើលោកអធិការឯងមានវិធានការអីតទៅទៀតទេ ?

-ត្រូវតែមាន ! ខ្ញុំមិនបណ្ដោយអោយពួកវាលេងស្មៀតដើរលើក្បាលខ្ញុំទេ ! ហ៊ឺះ អាឡេវ ! មិនអាចវ័ធលើអាជ័យបានទេ! លោកមេបញ្ជាការខ្ញុំលាសិនហើយ !

-សូមលោកអញ្ជើញអោយបានជោគជ័យ !

-មិនអីទេ ! ខ្ញុំមិនបណ្ដោយអោយទេវរូបឆ្លងដែនបានជាដាច់ខាត ។

គីរីវុធ បោះជំហានចេញមកដល់ខាងក្រៅ នាយនឹក ឃើញរឿងអ្វីមួយ ក៏ងាកទៅលោកមេបញ្ជាការ ៖

-លោកមេបញ្ជាការ ! សូមលោកបញ្ជាអោយភ្នាក់ងាររបស់ យើងធ្វើការឆែកឆេរតាមរថយន្តដឹកទំនិញ និងរថយន្តដឹកជញ្ជូន អ្នកដំណើរអោយមែនទែន ពិសេសចំពោះរថយន្តដែលធ្វើដំណើរ ចេញពីខេត្តយើងទៅកាន់ខេត្តផ្សេង។

-សូមលោកកុំភ័យ ! ខ្ញុំបានចាត់ចែងអស់ហើយ !

គីរីវុធ ឡើងម៉ូតូបញ្ឆេះចេញទៅ ! តើនាយត្រូវធ្វើដំណើរ ទៅកាន់ទីណា ?

គ្មានគោលដៅ នាយត្រូវទៅសុំងំយកកំលាំងនៅផ្ទះនារីតី មួយរយៈ ពួកជនទុច្ចរិតច្បាស់ជាតាមដានសកម្មភាពរបស់នាយ ព្រោះក្នុងប៉ុន្មានថ្ងៃនេះពួកវាចាប់ផ្តើមស្គាល់នាយមែនទែនហើយ ដូច្នេះការប្រយុទ្ធក៏អាចមានច្រើនដែរ នាយត្រូវប្រយ័ត្នជាងមុន ទើបបាន !

-បងវុធអញ្ជើញមកវិញហើយ !

នារីតីទះដៃដោយត្រេកអរ រត់ចេញមកទទួលនាយ

-បងអ្នា ! លោកប៉ាត្រឡប់មកវិញហើយ !

-លោកអ៊ំអញ្ជើញមកវិញហើយឬ ? ឥឡូវគាត់ទៅណា ?

-ចាស់នៅខាងក្នុង !

-បងទៅជួបគាត់បន្តិច !

គីរីវុធ ចូលទៅ បុរសចំណាស់ម្នាក់ក្បាលឆកកំពុងអានកាសែត ។ ឮសូរសំរិបជើងក៏ងើបមើលនាយដែលសំដែងការគួរសម :

-ជំរាបសួរលោកអ៊ុំ !

-អឺ ! វុធទេ ! ក្មួយឯងមកសៀមរាបយូរហើយ ?

-បាទ ! មកដល់បួនប្រាំថ្ងៃហើយលោកអ៊ំ !

-ឯងមកលេង ឬក៏មកធ្វើការ ?

-បាទ ! មកធ្វើការលោកអ៊ុំ !

-រួចយ៉ាងម៉េចដែរការងារនោះ ?

-បាទ ! នៅងងឹតសូន្យសុងនៅឡើយ !

-ហ៊ឺ ! ការងាររបស់ឯងពិបាក ហើយគ្រោះថ្នាក់ណាស់ !

-តែវាក៏ថ្លៃថ្លា និងមានឧត្តមគតិណាស់ដែរ !

-អើ ! តាមការយល់ឃើញរបស់ឯងទេ ! រូបភាពណាទើបឯងវិលត្រឡប់ទៅវិញ !

-បាទ ហើយកិច្ចការ ខ្ញុំនឹងទៅវិញភ្លាម !

-រួចយ៉ាងម៉េចទៅ ? លោកប្អូន និងម្តាយឯងសុខសប្បាយទេ

-បាទ ! ប៉ាម៉ាក់សុខទុក្ខធម្មតាទេ !

-ឯងមិននាំគាត់មកលេងបានម្តង !

-បាទ ! ចាំថ្ងៃក្រោយ ! គាត់ចង់មកលេងដែរ តែការងារឯភ្នំពេញមមាញឹកពេក ! ពេលខ្ញុំទទួលបញ្ជាអោយមកកាន់សៀមរាបគាត់ចង់មកដែរ តែខ្ញុំឃាត់គាត់ព្រោះដំណើររបស់ខ្ញុំលើកនេះស្មុគ្រស្មាញ និងគ្រោះថ្នាក់ណាស់ គ្មានពេលនាំគាត់ដើរលេងទេ !

-ឯងតែអីចឹង ! " ជនចំណាស់បន្ទោស " តាមពិតមកពីឯងខ្លាចគាត់រំខានការខិលខូចរបស់ឯង លោកប្អូនចេញពីស្រុកកំនើតយូរហើយ គួរណាស់នាំគាត់មកលេងម្តង ទើបត្រូវ !

គីរីវុធ សើច :

-លោកអ៊ំថាអីចឹងក៏បាន ! ចុះបើខ្ញុំរវល់ដល់ម្លឹងៗ !

-ឯងយកគាត់មកទុកនៅទីនេះបានហើយ រួចហើយឯងទៅធ្វើការឯណាក៏ទៅចុះ ! មានពិកបាកឯងនាំគាត់អី !

-លោកប៉ាអ្ហា ! " នារីតីលូកមាត់ " បងវុធធ្វើការពេញមួយយប់ គាត់ហត់នឿយណាស់ ! ល្មមអោយគាត់ទៅសំរាកបន្តិចទៅ

-អី ! អញមានឃាត់វាឯណា ! យូរៗ មកម្តងនៅនិយាយលេងនឹងអ៊ំបន្តិចបានទេ ឬមួយក៏ ... យី នារតី ! កូនឯងចេះការពារបងណាស់មែនទេ ! តែវុធ ! តើលោកប្អូននិយាយថាម៉េចដែរ រឿងរបស់ឯងនិងនារតីនោះ !

នារតី អៀនឡើងមុខក្រហម នាងងាកមុខចេញចាំស្តាប់សំដីរបស់បងជីដូនមួយរបស់នាងដែលឆ្លើយថា :

-បាទ លោកប៉ាមានប្រសាសន៍ថានឹងប្រុងគិតគូរឆាប់ៗ នេះហើយ តែមកពីខ្ញុំមានភារកិច្ចមមាញឹកជាប់គ្នាពេករកដកឃ្លាមិនរួចសោះ កុំអីគាត់អញ្ជើញមកចាត់ចែងយូរហើយ !

-រឿងនេះអ៊ំចាំមើលតែផ្លូវគាត់ហ្នឹងណា !

-បាទ ! បើតាមយោបល់ក្មួយ ចាំអោយអូននារតីប្រលងជាប់អងហើយសិនទៅលោកអ៊ំ !

-មិនសំខាន់ទេ ! "គាត់គ្រវីក្បាល" រឿងប្រលងនោះ ព្រោះទោះជាវាប្រលងជាប់ក៏មិនដឹងទៅរកការធ្វើនោះទេ ! កូនស្រីចេះកិច្ចការផ្ទះបានហើយ !

នារតី ឃើញឪពុកនិយាយច្រើនពេកនាងតៀនជាលើកទីពីរ :

-បងវុធ ! ទៅផ្លាស់ខោអាវទៅបង ! កែងដៃកើតអីចាជាំសំបើមម្ល៉េះ ?

គីរីវុធ សើច :

-នេះជាការងាររបស់បងណា ! ពីយប់មិញឆាកស៊ីសាច់ហុតឈាមគ្នាមួយដាបញ្ជើសដែរ !

គីរីវុធ ក្រោកពីកៅអីទៅផ្លាស់ខោអាវហើយងូតទឹកជំរះកាយ ទើបស្រស់ស្រូប ។

កម្លោះក្រមុំអង្គុយញញឹមទល់មុខគ្នា ហាក់ដូចជាស្រឡាញ់គ្នាក្រៃលែង ។ នារតី បេះត្រីដាក់ចានបបរសង្សារបណ្តើរសួរបណ្តើរ :

-បងវុធ ! ក្រែងបងថាព្រឹកហ្នឹងបងមានរឿងល្អមួយប្រាប់អូនឬ ?

-ហ្នឹងហើយ ! បងនិយាយអ៊ីចឹងមែន តែឥឡូវរឿងហ្នឹងក្លាយជារឿងមិនល្អទៅហើយ ! ហើយជារឿងចុកឈាមទៀតផង !

-ម៉េចអ៊ីចឹង ?

នារតី សួរដោយឆ្ងល់ ។ គីរីវុធ នឹកឃើញរឿងពីយប់មិញនាយសើចយឺកៗ :

-ហ៊ី ! មិនគួរនិយាយប្រាប់អូនសោះ ! បងខ្មាស់ណាស់ តាំងពីដើមមកបងមិនដែលដើរពីក្រោមពួកខិលខូចឡើយ ទើបតែយប់មិញនេះ ចាញ់បោកវាមួយចាន វាឆ្វាញ់ដៃ ហើយផ្ទេមមាត់ក្រៃលែង ។

គិរីវុធ ដួសបបរបញ្ចុកចូលមាត់សួរទៀត :

-ឱ ! នែ ! នារតី ! អូនដឹងទេ ហេតុអ្វីក៏អសនី បងនាងរតនាមិនមកចូលរួមក្នុងពិធីបុណ្យកំណើតរបស់អូន !

នារតី គ្រវីក្បាល :

-អូនឥតដឹងទេ ! រតនាប្រាប់ថាគាត់ឥតទៅផ្ទះជាមិនបានមក បងសួរមានការអី ?

-បងចង់ទៅលេងផ្ទះនារតី ... ។

-ទៅធ្វើអី ?

-អូនឯងប្រច័ណ្ឌឬ ?

-នេះជាសិទ្ធិរបស់អូន !

-អូនឯងកុំចង្អៀតចង្អល់ពេក ! បងទៅលេងនាងជាការស្គាល់គ្នាទេតើ ! ជូនបងទៅបន្តិចណាមាសថ្លៃ !

-ហ៊ឺស ! កុំបានមាត់កពេក ! " នារតីមួលស្លឹកត្រចៀកសង្សារ

គីរីវុធ ស្រែក " យ៉ូស " ធ្វើមុខស្អុយ !

នារតី សើចក្អាកក្អាយដោយរីករាយ ។

# ~៦~

ផ្ទះរបស់រចនាជាភូមិគ្រឹះមួយយ៉ាងស្កុកស្កម្ភសង់ជាប់នឹងមាត់ស្ទឹងសៀមរាបបែរមុខមករកថ្នល់ជាតិក្បែរវត្តលង្កា ។ ជុំវិញភូមិគ្រឹះមានដើមស្វាយ និងម៉ាក់ព្រេងម៉ាក់ប្រាងចោលម្លប់ត្រឈឹងត្រឈៃ ។

ម៉ូតូមួយបញ្ឆោដោយគីរីវុធ បញ្ឈិះនារតីពីក្រោយមកឈប់ពីមុខទ្វាររបងគ្រឹះ ។ សំលេងឆ្កែព្រូសពីក្នុង :

-អីយ៉ា ! " គីរីវុធ លាន់មាត់ " បងនៅគ្រាន់បើ ឆ្កែនៅព្រូសនៅឡើយ ។

នារតី សើចញឹមៗ :

-ឆ្កែព្រូសព្រោះខ្លាចមនុស្សមកលួចបេះដូងម្ចាស់វាមិនគិតនៅអួតខ្លួនថាគ្រាន់បើទៀត ។

គីរីវុធ សើចញឹមៗ នាយចតម៉ូតូហើយដើរទៅចុចកណ្ដឹងនារីម្នាក់ដើរចេញមកពិតជារចនាទាំងសាច់ទាំងឈាម ។

នាងមានទឹកមុខធ្ងល់បន្តិច តែលុះស្គាល់ជាគីរីវុធ ក៏រត់រឹងមកបើកទ្វារ :

-យី ! លោកទេ ? ខ្ញុំស្មានតែអ្នកណា ! វាសនារបស់ផ្ទះខ្ញុំ ហើយដែលបានលោកអញ្ជើញមកលេងដូច្នេះ ! សូមអញ្ជើញ ! អ្នកបង! អញ្ជើញចូល !

រចនា ដឹកដៃនារតី :

-អញ្ជើញលោកចូលលេងខាងក្នុង ! ”រួចរាងងាកមកនិយាយលេងរឹងនារតី ” អ្នកបងរៀបចំពិធីបុណ្យចំរើនអាយុរបស់អ្នកបងបានអធិកអធមណាស់ ហើយសប្បាយផង !

នារតី សើចដោយពេញចិត្ត :

-អរគុណចំពោះពាក្យសរសើររបស់រចនា !

នារតី ដើរនាំមុខភ្ញៀវចូលក្នុងភូមិគ្រឹះហើយទៅកាន់បន្ទប់ទទួលភ្ញៀវ ។ បុរសចំណាស់ពីរនាក់កំពុងជជែកគ្នា ម្នាក់មុខសុទ្ធរចនាទំនងជាឪពុករបស់នាងហើយ នាងណែនាំអោយស្គាល់

-លោក ! នេះជាឪពុកខ្ញុំ !

-ជំរាបសួរលោកពូ ! ” នាយសំពះសួរ ”

-ថ្វាយព្រះក្សួយ !

រចនា ចង្អុលទៅម្ខាងទៀត :

-នេះជាឪពុកមារបស់ខ្ញុំ ! គាត់នៅភ្នំពេញទើបតែអញ្ជើញមក

លេងផ្ទះខ្ញុំពីម្សិល !

ទាំងគីរីវុធ ទាំងនារតី លើកដៃសំពះ :

-ជំរាបសួរលោកពូ !

-ថ្វាយព្រះក្មួយ !

-មារបស់រចនាសំពះតបវិញហើយសំលឹងមើលគីរីវុធពោលថា:

-តាមសំដីលោកក្មួយឯងជាអ្នកភ្នំពេញដែរ ?

-បាទ ! ខ្ញុំជាអ្នកភ្នំពេញដែរលោកពូ !

-អូ ! ត្រូវមែន ! លោកក្មួយឯងអញ្ជើញមកលេងសៀមរាបយូរហើយឬ ?

-បាទ បួនប្រាំថ្ងៃហើយ !

ឪពុករចនាមើលមុខគីរីវុធដោយកែវភ្នែកមុតថ្លា :

-អង្គុយមកក្មួយ ! រចនាកូនឯងទៅលើកទឹកក្រូចមក ក្មួយប្រុសឬដែលបានជួយសង្គ្រោះរចនាអោយរួចពីគ្រោះថ្នាក់នោះ ?

គីរីវុធ មិនទាន់ឆ្លើយ ព្រោះឪពុកមារបស់រចនា បានក្រោកឈរពោលថា :

-លោកបងជជែកលេងចុះ ! ខ្ញុំចេញទៅក្រៅមួយភ្លែត !

-អើ ! ឆាប់មកហូបបាយវិញណា !

មាននាងចេញបាត់ទៅទើបគីរីវុធ ពោលជំរាបថា :

-គឺក្មួយនេះហើយជាអ្នកជួយនាង !

-ពូត្រេកអរណាស់ ! បើកុំតែបានក្មួយឯងម៉្លេះកិត្តិយសពូ និងគ្រួសារពូមិនដឹងជាធ្លាក់ដល់កំរិតណាទេ ! ពូសូមថ្លែងអំណរគុណចំពោះក្មួយជាពន្លឹក ហើយបើមិនយល់ទាស់ទេ ក្មួយនៅញុំាបាយជាមួយពូមួយពេលណា !

-បាទ ! សូមលោកពូកុំនិយាយពីរឿងគុណស្រ័យអីការជួយសង្គ្រោះគ្នាជារឿងធម្មតាទេ !

-រឿងនេះមិនមែនធម្មតាទេ ! បើកុំតែក្មួយឯងប្រថុយស្លាប់រស់ជាមួយពួកអាយូក្លូងទាំងនោះ ម៉្លេះពូ ...មិនដឹងសើចឬយំទេ !

ឈប់បន្តិចគាត់និយាយបន្ត :

-ឬរចនាប្រាប់ពូថា ក្មួយឯងជាភ្នាក់ងារគិញសំងាត់ផងឬ ?

គីរីវុធ ភ្ញាក់បន្តិច នាយមិនចង់អោយអ្នកណាដឹងថានាយជាគិញសោះតែហួសពេលហើយ ។ នាយតបមួយៗដោយឈ្ងោកក្បាលផញ្ញឹងគិត :

-បាទ ! ការងារបន្ទាប់បន្សំទេ !

-យី ! បន្ទាប់បន្សំ ! ការងារនេះថ្លៃថ្លាណាស់ ! ពូក៏ចូលចិត្តដែរ កិច្ចការហ្នឹង ! រួចក្មួយឯងមកសៀមរាបហ្នឹងមានបេសកកម្មអីដែរ?

-បាទ ! ទេ ! លោកពូ ! ខ្ញុំមកលេងជាមួយប្អូន គ្មានការងារអី ទេ !

ឪពុករចនាហាក់ដូចជាដឹងថា សួរជ្រុលមាត់ជ្រុលក ក៏ប្រញាប់កែប្រយោគ :

-សូមទោសលោកក្មួយ ! ការងាររបស់លោកក្មួយជារឿងអាថ៌កំបាំង ! មិនគួរពូសួរឯងសោះ !

-មិនអីលោកពូ !

ពេលនោះរចនាលើកភេសជ្ជៈមួយថាសចេញមកទទួលភ្ញៀវ ។

-ញាំទៅក្មួយ ! ក្មួយស្រី ! អឹមអៀនអី សុទ្ធតែអ្នកស្រុកគ្នាឯងតើ !

គីរីវុធ ទទួលកែវទឹកក្រូចលើកក្រេបបណ្ដើរគិតបណ្ដើរ :

-ចុះអសនី ! បងរបស់រចនាទៅណាបាត់ជាមិនឃើញនៅផ្ទះ

ទទួលក្រឡេកភ្នែកលើជញ្ជាំង នាយឃើញរូបថតមនុស្សប្រុសម្នាក់យ៉ាងសង្ហាញូរនឹងជញ្ជាំងនាយក៏សួរ :

-អត់ទោសអ្នកនាងរចនា ! នេះជារូបបងរបស់អ្នកនាងឬ ?

រចនា ងាកមើលរូបថតញញឹមក្នុងទឹកមុខធម្មតា

-ចាះ ! ត្រូវហើយ គាត់ជាបងរបស់ខ្ញុំដែលជំរាបលោកពីថ្ងៃមុន! គាត់មិនសូវនៅផ្ទះទេ ម្ដែ៊ៗ ដើរបាត់ៗ ជួនបាត់ពីរបីថ្ងៃក៏មាន។ ព្រឹកមិញនេះមកដល់ជួនពេលហៀបភ្លឺ បានមួយភ្លែតក៏ចុះទៅវិញបាត់ ...

-គាត់ប្រហែលជារវល់ក្នុងការរកស៊ីណាស់មែនទេ ?

-ហ៊ឺ ! ឮសំដីរបស់គិរីវុធ ឪពុករចនាដកដង្ហើមធំទើបនិយាយ "គ្មានរកស៊ីអីវាទេ ! អាកូនប្រុសខ្ញុំមួយនេះគ្មានកំណើតទេ មួយថ្ងៃៗវាដើរលេងបង្ហិនបំផ្លាញសព្វបែបយ៉ាង ទោះជាខ្ញុំជេរប្រដៅវាយ៉ាងណាគ្មានបានការអីដែរ ! នេះមកពីវាគ្មានម្ដាយតាំងពីតូច !

-ឱ ! អីចឹង អ្នកនាងរចនាគ្មានម្ដាយទេឬ ?

រចនា ងក់ក្បាល :

-ចាះ ត្រូវហើយ ! ម៉ាក់ទទួលអនិច្ចកម្មតាំងពីខ្ញុំនៅតូចៗ ម្ល៉េះ

កំពុងជជែកគ្នា ស្រាប់តែវត្ថុអ្វីមួយនៅក្នុងហោប៉ៅអាវរបស់គិរីវុធ លាន់ទីតៗ ...

គិរីវុធ ភ្ញាក់ព្រើតលាន់មាត់ :

-អ្ហា ! ខ្ញុំមានការចាំបាច់ ! សូមលាលោកពូ និងអ្នកនាងសិន ហើយ ចាំថ្ងៃក្រោយជួបគ្នាទៀត !

-អើ ! បើក្មួយមានធុរៈហើយ ពូក៏មិនហ៊ានឃាត់ដែរ ថ្ងៃណាទំនេរសឹមមកលេង ញ៉ាំបាយនឹងពូម្តងណាក្មួយ !

-បាទ ! " នាយងាកទៅរចនា " អ្នកនាងរចនាខ្ញុំលាសិនហើយណា !

រចនាធ្វើភ្នែកព្រិច១ រស្មីមួយចំលែកបានជិតលើរង្វង់គ្រាប់ភ្នែក បបូរមាត់នាងញ័រ១ ហាក់ចង់និយាយរឿងអ្វីមួយដែលលាក់អាថ៌កំបាំងទុកក្នុងចិត្តរបស់នាង ។

មិនអោយនាងមានអារម្មណ៍ចំលែកម៉េចកើត បើមួយជីវិតនេះ ក្រៅពីជនពាលបីនាក់ដែលបានចាប់នាង ចង់រំលោភនោះ មានតែគិរីវុធនេះឯងដែលបានឃើញរូបកាយរបស់នាងឥតមានសល់ចន្លោះ ដែលសូម្បីតែឪពុករបស់នាងក៏នាងមិនដែលបង្ហាញផង ដូច្នេះតើមានអ្វីទៀតសំរាប់រូបនាង ។

គិរីវុធ យល់អារម្មណ៍នាងច្បាស់ណាស់ តែនារតីឥតដឹង ថា រចនាបានបូជារូបកាយរបស់នាងក្រោមប្រស្រីភ្នែករបស់គិរីវុធទៅហើយនោះទេ នាងដឹងតែម្យ៉ាងគឺថា នាងសង្ស័យថារចនាល្ងួច

ស្រលាញ់គីរីវុធ របស់នាងតែប៉ុណ្ណោះ ។

ចំណែកគីរីវុធដឹងហួសពីដឹងទៅហើយថា រចនា បានផ្តិតរូបភាពទុកក្នុងប្រអប់បេះដូចនាងទៅហើយ តើអោយនាយពុនខាងណា ចោលខាងណា ឬក៏ត្រូវរែក ! បើនារតីកាន់កាប់យ៉ាងផ្តាច់មុខចំពោះរូបនាយ :

យូរណាស់ទើបនាងពោលដោយញាប់ញ័រ :

-ចាស់ ! លោក ! សូមលោកឧស្សាហ៍មកលេងជាមួយខ្ញុំផងណា !

-មិនអីទេ ! ចាំកាលណាបេសកកម្មរបស់ខ្ញុំចប់ ខ្ញុំពិតជាមកលេងជាមួយអ្នកនាងមិនខាន !

-ការងារនៅវែងឆ្ងាយណាស់ ! មិនអាចកំណត់បានទេ !

គីរីវុធបែរខ្លួនចោះជំហានបណ្តើរនារតីចេញក្រៅដោយមានរចនា និងឪពុកជូនដំណើរដល់មាត់ទ្វាររបង :

-លោក ! កុំភ្លេចមកលេងនឹងខ្ញុំទៀតណា !

នេះជាសំដីចុងក្រោយរបស់រចនា នាងពោលដោយទឹកមុខស្រពោន ។

ឪពុកនាងយល់ចិត្តកូនស្រីណាស់ គាត់នឹកអាណិតកូន តែ

គាត់មិនអាចទិញទឹកចិត្តគីរីវុធអោយកូនស្រីគាត់ឡើយ ម៉្យាងទៀតគាត់ឥតទាន់ដឹងទឹកចិត្តរបស់គីរីវុធចំពោះកូនស្រីគាត់ដែរ ។

-ឧស្សាហ៍មកលេងនឹងពូណាក្មួយ !

-បាទ ! ខ្ញុំលាហើយ !

គីរីវុធ បែរទៅកាន់នារតីប្រាប់ថា :

-អូននារតី ! បងមានការមិនបានជូនអូនដល់ផ្ទះទេ សូមអូនទៅខ្លួនឯងចុះណា !

នារតីមានការងងក់បន្តិច តែមិនអាចជជែកតវ៉ាបានឡើយព្រោះនេះជាភារកិច្ចចាំបាច់បំផុតរបស់សង្សារ នាងហៅរ៉ឺម៉កឡើងជិះទៅ ។

គីរីវុធបញ្ឆេះម៉ូតូ ហើយចេញដល់ច្រកស្ងាត់មួយទើបនាយលូកយកវត្ថុពិសេសពីហោប៉ៅ ហើយចុចគន្លឹះសញ្ញា :

-ក០០៥ សូមរង់ចាំទទួលពត៌មាន !

សំលេងទីត១ និងភ្លើងសញ្ញាបង្ហាញជាមួយនឹងសំលេងប្រាប់ថា :

-ក០០៥ សូមចេញដំណើរតាមផ្លូវជាតិលេខប្រាំមួយទៅកើតជាប្រញាប់ ព្រោះមានរថយន្តលេខ ភព១៣៥៤៧៧ បើកចេញពី

សៀមរាបយ៉ាងចំលែកបំផុត ការឆែតឆេរនៅជាយក្រុងពុំទាន់បានទទួលលទ្ធផលនៅឡើយទេ តែគេសន្និដ្ឋានថាវានឹងទៅទទួលទេវរូបពីកន្លែងផ្សេង ! ខ្ញុំនឹងបញ្ជូនភ្នាក់ងារជំនួយទៅតាមក្រោយ

ភ្លើងសញ្ញារលត់ គីរីវុធ កាន់ដៃចង្កូតម៉ូតូ ហើយមួលវ៉ាបង្កើនល្បឿនដូចខ្យល់កំបុតត្បូង ។

អ្នកដំណើរហក់គេចព្រាត ហើយដកកមើលជនចំលែកដែលបើកបរដូចប្រាថ្នាទៅកាន់ឋានអវចីយ៍ ។

តែគីរីវុធ ឥតខ្វល់ខ្វាយនឹងការយកចិត្តទុកដាក់របស់គេឡើយ ។ ចារកិច្ចមិនអនុញ្ញាតអោយយឺតយ៉ាវបានឡើយ ការយឺតយូរតែមួយនាទីអាចបណ្ដាលអោយខូចការទាំងមូលបាន ហើយក៏អាចបញ្ជូនជីវិតនាយទៅកាន់ឋានគ្មានវិលត្រឡប់ដែរ ។

ចេញផុតទីក្រុង ម៉ូតូហោះលើផ្លូវជាតិទៅមុខយ៉ាងលឿន ដើមឈើធំៗ ប្រកបដោយកិរិយាវិលថយក្រោយឥតអាក់ ។ បង្គោលគីឡូត៍ក៏ចេះតែវ៉ាត់មកច្រើនឡើងៗ ។

មួយភ្លែតប៉ុណ្ណោះ នាយបានឆ្លងកាត់ចំងាយផ្លូវជាងម្ភៃគីឡូម៉ែត្រស្រេច ហើយមកដល់តំបន់ព្រៃធំអមសងខាងផ្លូវ ។

កូនឡានតូចមួយរត់ពីមុខប្រកបដោយល្បឿនដូចគ្នានឹង

ម៉ូតូដែរ ។ ចំងាយផ្លូវប្រហែលប្រាំរយម៉ែត្រ នាយនឹងទៅទាន់រថយន្តនោះមិនខាន ។

គឺពិតជាឡានហ្នឹងហើយ លេខ១៣៥៤៧៧ តើឡានេះពិតជាទៅទទួលទេវរូបឬយ៉ាងណាដែរ ?

ការឃាត់ឡានមិនទាន់ដល់ពេលនៅឡើយទេ វាទើបចេញពីក្រុង ច្បាស់ជាវាពុំទាន់ទទួលទេវរូបនៅឡើយទេ ! នាយត្រូវទៅចាំនៅទីប្រជុំជនដំដែក និងប្រាប់អ្នកកាន់កាប់នៅទីនោះអោយចាំស្ទាក់ឆែកឆេរ ។

គិតស្រេចម៉ូតូរបស់នាយរត់បង្ហួសឡានយ៉ាងលឿន ។ ... ពេលទន្ទឹមគ្នានាយមើលក្នុងឡាន ... បុរសម្នាក់អង្គុយពីក្រោយជាមនុស្សដែលនាយឥតស្គាល់ឡើយ ។ រីឯអ្នកបើកបរក៏ឥតស្គាល់ទៀត តើពីរនាក់នេះអាចជាអ្នកប្រព្រឹត្តអំពើទុច្ចរិតឬ ?

ម៉ូតូនាយបង្ហួសទៅមុខប្រុងស្រូតទៅចាំងទីប្រជុំជនដំ ដែកតែ... ឡាននោះឈប់ងក់... មនុស្សម្នាក់ចេញពីផ្ទះមួយក្បែរនោះហើយឡើងឡាន ឡានក៏ត្រឡប់ក្បាលបើកត្រឡប់ទៅវិញ ។

ក០០៥ ភ្ញាក់ព្រើតបញ្ឈប់ម៉ូតូ ជាបន្ទាន់ហើយក៏ត្រលប់ក្រោយ នាយមើលផ្ទះចំណាំអោយច្បាស់បង្គោលគីឡូម៉ែត្រលេខ

២២ សៀមរាប ស្ថិតនៅចិញ្ចើមថ្នល់ទន្ទឹមនឹងផ្ទះនោះ ។

អស់ការ... នាយបន្តដំណើរ...

ហាក់ដូចជាគ្មានបានទទួលលទ្ធផលសោះ នាយបណ្ដោយអោយឡាននោះទៅឆ្ងាយបន្តិចក៏ឈប់ម៉ូតូ ហើយរាយការណ៍តាមរយៈវត្ថុពិសេសភ្លាម ។

ភ្លើងសញ្ញា នាយនិយាយ ...

_ក០០៥ រាយការណ៍ ឡានលេខ ១៣៥៤៧៧ បត់ក្បាលទៅកាន់ក្រុងវិញហើយ សូមអោយភ្នាក់ងារតាមអោយជាប់ អស់ការខ្ញុំទៅតាមក្រោយ ... អស់ !

នាយបិតសំលេងហើយបន្តដំណើរក្រោមការរិះគិតមួយរយជំពូក ។

បើឡាននេះគ្មានបង្ហាញលក្ខណៈគួរអោយសង្ស័យ ហេតុអ្វីក៏ភ្នាក់ងារស៊ើបអង្កេតរាយការណ៍អោយតាមដាន ?

ឬក៏នេះជាការបំភាន់របស់ពួកទុច្ចរិតទៀត ? តើឃាតករលើរូបអ៊ីយ៉ាន ! បានលូកដៃជាបន្តទៅទៀតក្នុងការជំរត់យកទេវរូបទៅលក់ឯបរទេសឬក៏វាលក់បន្តអោយឈ្មួញទុច្ចរិតណាមួយ ?

តើមានការប្លែកកើតឡើងឯភូមិត្រពាំងសេះ ឬទេ ? នាយ

នឹកឃើញជនចំលែក នាយឆោម និងម្នាក់ទៀតដែលនាយជួបនៅព្រៃអង្គរ តើពួកនេះមានលួកទ្បក្នុងរឿងនាំយកទេវរូបទៅក្រៅទេ? នឹកដល់បញ្ហានេះ គីរីវុធ ហាក់ដូចជាចង់ធ្វើដំណើរទៅកាន់ភូមិត្រពាំងសេះ ដើម្បីជួបនឹងយ៉ានី តើយ៉ានីមានបានទទួលពត៌មានអ្វីប្លែកឬទេក្នុងរឿងឃាតកម្មលើរូបឪពុករបស់នាង ។

គីរីវុធ មិនសូវចេះស្ទួញសាញទ្បើយ កាលបើគិតឃើញដូច្នេះហើយ នាយបង្កើនល្បឿនម៉ូតូ រត់កាត់តាមស្ពានថ្មឆ្លងស្ទឹងសៀមរាប ហើយបត់តាមផ្លូវទៅជើងតំរង់បរិវេណឧទ្យានអង្គរ ។

មិនយូរប៉ុន្មាននាយក៏បានមកដល់ភូមិត្រពាំងសេះដូចបំណង ។ ម៉ោងជិតមួយ ថ្ងៃរសៀលកទៅហើយ នាយឥតខ្វល់នឹងការស្រេកឃ្លានរបស់ក្រពះទ្បើយ ។

បត់តាមផ្លូវដីតូចមួយដែលនាយធ្លាប់មកម្តងហើយ ហើយឈប់ពីមុខខ្ទមម្តាយធំរបស់នាយ គឺផ្ទះអ៊ំសែម ។

សំលេងម៉ូតូទាញការប្រុងប្រយ័ត្នរបស់នារីម្នាក់អោយរត់ចេញមកអើតមើល គឺយ៉ានី

-អុះ ! បងវុធទេ ! បងទើបងញើញមកពីណា ?

គីរីវុធ ញញឹម នាយចតម៉ូតូងើបមើលទៅប្អូនស្រីក្នុងក្តី

ភូតកុហក :

-យ៉ានី ! ” នាយហៅបានត្រឹមណោះក៏ឈប់ស្ងៀម ព្រោះទឹកមុខរបស់យ៉ានីខុសប្លែកសព្វជង គឺទឹកមុខពោរពេញដោយទុក្ខព្រួយទាំងតំណក់ទឹកភ្នែកដាមៗ លើថ្ពាល់ផង ”។

នាយមានក្ដីងឿងឆ្ងល់ :

-មានរឿងអីឬបានជាអូនយំ ? អ៊ំអញ្ជើញទៅណា ?

យ៉ានីឥតឆ្លើយចំពោះសំនួរដំបូងរបស់នាយទេ នាងឆ្លើយចំពោះសំនួរចុងក្រោយ :

-ម៉ែអញ្ជើញទៅចំការហើយ !

គីរីវុធ ចោះជំហានឡើងលើផ្ទះ :

-យ៉ានី ! ម៉េចបានជាអូនយំ ?

នាយសួរផ្ទួនដូច្នេះ ហាក់បង្ខំអោយចិត្តយ៉ានីកំរើកឡើងសារជាថ្មី តំណក់ទឹកភ្នែកក៏ស្រក់ព្រួមកទៀត គីរីវុធ សួរបន្ត :

-យ៉ានី ! អូនឥតព្សសំនួរបងទេ ? ឬក៏អូនលែងទុកចិត្តបងហើយ? បងសួរជាមានរឿងអីបានជាយំដូច្នេះ ប្រាប់មកមើល ក្រែងលោបងមានលទ្ធភាពជួយដោះស្រាយអូនឯងបាន ?

-ឥតសង្ស័យទេបង ! បងពិតជាគ្មានលទ្ធភាពអាចជួយអូនបាន

ទេ ! នេះជាបញ្ហាជីវិតណាបង !

គីរីវុធ ភ្ញាក់ព្រើត នាយដូចជាព្រឺខ្លួនដែរ :

-បញ្ហាជីវិត ? តែបញ្ហានេះទាក់ទងដល់រូបនាយឬទេ ?

នាងសួរដោយឆ្ងល់ :

-អូនថាមានបញ្ហាជីវិត ! តើជីវិតនេះយ៉ាងម៉េចដែរ ?

យ៉ានី ខឹងក្រខ្យល់កាន់តែខ្លាំង :

-អូនជំរាបបងតាមត្រង់ចុះ អូននឹងបងឆោមបានស្រលាញ់គ្នាយូរហើយ តែឥតទាន់រៀបការព្រោះយើងទាំងពីរនាក់ក្រខ្លាំងពេកម្ល៉ោះហើយកាលពីម្សិលមិញនេះ បងឆោមបានមកបបួលអូនជម្រត់គ្នាចេញពីភូមិនេះ ដើម្បីទៅកសាងអនាគតនៅស្រុកផ្សេងអូនបានប្រកែកដែរ ព្រោះយើងគ្មានលុយមួយសេនអីចឹង តើទៅស្រុកគេធ្វើម្តេចចិញ្ចឹមពោះរស់ ។ បងឆោមបានធានាថាអោយតែអូនព្រមទៅ គាត់អាចចិញ្ចឹមរស់ព្រោះគាត់ទទួលធ្វើការអោយគេមួយបានប្រាក់ច្រើនណាស់ អោយតែអូនព្រមទៅតាមចុះ ។ ឥឡូវនេះគាត់ទៅទទួលយកប្រាក់ពីគេហើយ ពេលទទួលប្រាក់បានហើយ គាត់ឥតត្រលប់មកវិញទេ គាត់បង្ហួសទៅរហូតហើយអូនបានអង្វរគាត់អោយត្រលប់មកស្រុកវិញដែរ តែគាត់បដិសេធ

ដោយប្រាប់ថា មិនអាចវិលមកវិញបានទេ បើអូនមិនព្រមទៅតាមគាត់ទេនោះ យើងទាំងពីរនឹងត្រូវចែកផ្លូវគ្នាដើរតែត្រឹមនេះឯង !

គីរវុធ ភ្ញាក់ព្រើត នាយត្រូវតែចេះចាប់អារម្មណ៍សង្ស័យអោយបានគ្រប់ករណី ។ តើនាយឆោមទទួលធ្វើអីអោយគេ ស៊ីឈ្នួលពង្រត់យកទេវរូបឬ ? ឬក៏អាចយកទេវរូបទៅលក់ប្តូរយកលុយ ? ចាំបាច់ត្រូវតែតាមនាយឆោមសិន ! នាយសួរយ៉ានី :

-ឆោមប្រាប់ថាគេទៅធ្វើការនៅឯណាដែរអូន ?

-ចាស់ ! គាត់ថាបើអូនព្រមតាមគាត់ គឺត្រូវអូនទៅចាំគាត់នៅភូមិបន្ទាយស្រី ក្បែរប្រាសាទបន្ទាយស្រី ព្រោះគាត់ត្រូវធ្វើការអោយគេនៅទីនោះ !

-បន្ទាយស្រី ?

-ចា៎ះ ត្រូវហើយ ! ម៉េចក៏បងចាប់អារម្មណ៍ខ្លាំងម្ល៉េះ ?

-នេះជាបញ្ហាដែលទាក់ទងនឹងឃាតកម្មលើរូបលោកអ៊ំ ឪពុកអូនណា យ៉ានី !

-ថាម៉េច ! បងឆោមសំលាប់ពុក ?

-មិនទាន់ប្រាកដទេ ស្ថិតនៅក្នុងការតាមដាននៅឡើយទេ ! បងមានការប្រញាប់បន្តិច បងលាហើយណា !

ពេលចប់ស្ទើរមិនទាន់ គីរីវុធចុះពីផ្ទះយ៉ានីយ៉ាងរហ័ស នាយទាញម៉ូតូងាកប្រាប់នាងថា :

-រឿងដែលអូននិយាយនឹងបងពេលនេះ កុំប្រាប់អ្នកណាទៀតឮទេ ?

-ចាំះ !

យ៉ានី ទទួលមែន តែចិត្តរបស់នាងកំពុងនឹកឆ្ងល់នឹងអាការៈចំលែករបស់បងប្រុស តែនាងមិនហ៊ានសួរ បានត្រឹមតែសំលឹងមើលម្ញ៉ះៗ ពីលើផ្ទះ ។

សភាពការណ៍អាចចាត់ទុកថា ដល់ដំណាក់កាលត្រូវបង្ខំហើយ បញ្ហាទេវរូបមិនអាចបណ្តោយតទៅទៀតបានទេ ព្រោះជនទុច្ចរិតអាចបណ្តោះវាយកទៅបរទេសបានយ៉ាងងាយ ។

រឿងហេតុដែលយ៉ានីនិយាយប្រាប់នាយអំពីនាយចោមអាចអោយនាយសន្និដ្ឋានថា វាអាចចូលក្នុងរឿងនេះដែរ ! បើពិតជាដូច្នេះមែន បន្តិចទៀតច្បាស់ជាមានការស៊ីសាច់ហុតឈាមគ្នាមិនខាន !

ម៉ូតូរុលទៅមុខ នាយលូកដៃស្ទាបកាំភ្លើងខ្លីដែលលាក់ខ្លួននឹងចង្កេះរបស់នាយ វាជាមិត្តសំលាញ់ស្មោះត្រង់របស់នាយក្នុង

ពេលមានអាសន្ន ។

តែបើខ្មាំងរៀបបណ្ដាញរបស់វាច្រើនការពារអំពើទុច្ចរិតរបស់វានាយច្បាស់ជាជួបការលំបាក ដូច្នេះចាំបាច់ត្រូវការជំនួយ

ទោះពិតឬពុំពិត ចារកិច្ចមិនអនុញ្ញាតអោយនាយធ្វេសប្រហែសបានឡើយ ...។

នាយទាញទូរស័ព្ទវិទ្យាសាស្ត្រចេញមក ឯម៉ូតូចេះតែបោលទៅមុខដដែល :

ពន្លឺ និងសញ្ញាភ្លើងបញ្ចេញភ្លាម គឺវរុធហៅ :

-ក០០៥ សុំរកជំនួយ ! ចំណុចជួប... ព្រៃស្រោងបន្ទំមុខប្រាសាទបន្ទាយស្រី... អាវុធ... អស់ !

សញ្ញាភ្លើងរលត់ នាយទុកក្នុងហោប៉ៅវិញ ហើយបង្កើនល្បឿនម៉ូតូ ដូចខ្យល់ព្យុះកំបុតត្បូង ...។

កន្លះម៉ោងប៉ុណ្ណោះ នាយបានរត់លើផ្លូវក្រាលថ្មក្រហមក្នុងព្រៃស្រោងដ៏ធំ បន្តិចទៀតនឹងដល់ប្រាសាទបន្ទាយស្រីជាមិនខាន ។

ការតាំងចិត្តផុសផុល នាយនឹងជួបការប្រយុទ្ធមួយចំពោះមុខ តែរំពេជនោះ !

-ប៉ុង ! សូរកាំភ្លើងមួយផ្ទុះយ៉ាងស្រាលពីចំងាយនាយផ្ទៀងត្រចៀកស្តាប់ ...។

ស្ងាត់ ... ឮតែសំលេងម៉ូតូ !

គិរីវុធ ឆ្ងល់ ! មានរឿងអីកើតឡើងឬ ?

-ប៉ុង ! ៗ ! សូរគ្រាប់កាំភ្លើងផ្ទុះឡើងទៀតហើយស្រាលដូចមុន !

ច្បាស់ជាមានការប្រយុទ្ធគ្នាឯនាយ ! រឿងអ្វី ? មានការប្រទ្រុសប្រទ្រាសគ្នារវាងគ្នារវាងពួកទុច្ចរិតឬ ?

គិរីវុធ មួលបន្ថែមល្បឿនម៉ូតូ មួយព្រិចភ្នែកប៉ុណ្ណោះ នាយបានមកដល់មុខផ្លូវចូលទៅកាន់ប្រាសាទបន្ទាយស្រី ។

ទេសភាពជុំវិញនាយស្រស់បំព្រងដោយរុក្ខជាតិបៃតងខ្យល់បក់ប្រាវៗ...។

រំពេចនោះសូរសំលេងមួយដូចជាសំលេងម៉ូតូ...

នាយត្រូវតាមទៀតឬយ៉ាងណា ?

សំលេងម៉ូតូកាន់តែឆ្ងាយ...

ត្រូវតែតាម... តែរឿងហេតុនឹងទៅជាយ៉ាងណា ? ច្បាស់ជាមានទាក់ទងក្នុងរឿងអីមួយមិនខាន ។

គីរីវុធ ធាក់បញ្ឆេះម៉ូតូប្រុងតាម ហើយបន្តទូរស័ព្ទពិសេស

-ក០០៥ ប្រាសាទបន្ទាយស្រីមិនបានសំរេចទេ ត្រូវបន្តទៅមុខទៀត អស់ !...

គីរីវុធ បង្វិលក្បាលប្រុងព្រលែងអោយវារត់ទៅមុខ តែ... ក្នុងព្រៃក្បែរថ្មល់ ឡានមួយបញ្ឈប់ចោលនៅទីនោះ...។

-អ្ហាក ! ឡានអញតាមពីព្រឹកទេតើ !

មែន ! លេខឡាន ១៣៥៤៧៧ ទាំងសាច់ទាំងឈាម ! អស្ចារ្យ ! ពួកនេះប្រសប់លេងឆាកកំប្លែងណាស់ ។

-យ៉ះ ! ពួកអានេះលេងល្បិចស្អាតណាស់តើ !

គីរីវុធ បញ្ឈប់ម៉ូតូ នាយរត់ដូចហោះតំរង់ទៅកាន់ឡាន នោះ ព្រោះមានសំលេងចំលែកហាក់ដូចជាសំលេងថ្ងូរ !

តួឡានគេបោះបង់ចោលឥតស្តាយស្រណោះ ! ហេតុដូម្តេចក៏គេគ្រវាត់ឡានចោលអីចឹង ? អ្នកនោះមានអាថ៌កំបាំងអី

-អូយ ! ៗ ! " សំលេងថ្ងូរ"

មិនមែនសំលេងខ្មោចលងទេ ប្រាកដជាសំលេងមនុស្ស ថ្ងូរ គីរីវុធហាក់ដូចកង្កែបទៅកាន់ប្រភពសួរសំលេង ។

បុរសម្នាក់ដេកផ្កាប់មុខក្នុងថ្លុកឈាម...

គីរវុធ ឱនលើកត្រកង ប្រែខ្លួនអោយផ្ងារមកវិញ

-អ្ហា ! ឆោមទេតើ ! " នាយលាន់មាត់ដោយថ្ងូរ " ឆោម ! ឆោម !...។

ឮពាក្យអង្រូន់ហៅ ជនរងគ្រោះជិតផុតដង្ហើមទៅហើយ បើកភ្នែកឡើងស្លក់ !...

-អ្នក... ណា !...

-ឆោម ! មានរឿងអីប្រាប់មក ! ឆោម !

នាយឆោមត្រលប់ភ្នែកបញ្ឈរស្លី ខ្ពុរឈាមពីមាត់មួប១ :

-អាហែង ! អា... ហែង... ក្បត់... វាល... ស្រែណូយ ! ភូមិមួយនៅចុងខេត្តសៀមរាបខាងជើង

ពេលបានប៉ុណ្ណោះ នាយឆោមខ្ពុរឈាម ហើយដាច់ខ្យល់ស្លាប់ភ្លាមមួយរំពេជ ដោយឥតទាន់បានបញ្ជាក់ការពិតដល់គីរវុធឡើយ ។

នាយដាក់សពជនទុច្ចរិតលើដី ហើយបោះជំហានចេញក្រៅព្រោះស្នូរឡានបានមកដល់ដែរ ។

គីរវុធ លើដៃរា ព្រោះជាឡានជំនួយរបស់ក្រុមមានសមត្ថកិច្ច ។

ឡានឈប់ ជនម្នាក់ក្នុងសំលៀកបំពាក់ជាអ្នកប្រតិបត្តិការសឹកចុះមក ហើយគោរព !

-សូមគោរពលោកអធិការ !

គីរីវុធ គោរពតប :

បន្តដំណើរទៅកាន់ភូមិស្រែណូយទៀត ! ពួកវាបានបណ្ដោះគ្នាទៅកាន់ទីនោះហើយ !

ពោលចប់គីរីវុធ ហក់ឡើងម៉ូតូហើយបញ្ឆេះតទៅទៀត

ពីបន្ទាយស្រីទៅភូមិស្រែណូយមានចំងាយជាងសាមសិបគីឡូម៉ែត្រ ស្ថានភាពផ្លូវពិបាកធ្វើដំណើរណាស់ ទាល់តែល្ងាចព្រះអាទិត្យជិតលិចទើបដល់ភូមិនោះ តែហាក់ដូចជាគ្មានឃើញអ្វីគួរអោយសង្ស័យសោះ ! គីរីវុធ បើកម៉ូតូឆ្វៃលជុំវិញផ្លូវភូមិដើម្បីមើលស្ថានភាពភូមិសាស្ត្រ និងរង់ចាំកងជំនួយដែលមកតាមក្រោយ។

នាយបានចូលសាកសួរពត៌មានពីអ្នកភូមិម្នាក់ :

-អត់ទោសលោកអ៊ំ ! មានឃើញមនុស្សចំលែកមកតាមហ្នឹងទេ !

-មនុស្សចំលែក ? " អ៊ំចាស់សួរដោយឆ្ងល់ " មនុស្សចំលែក

ដូចម្តេចទៅ ? ដូចជាឥតឃើញទេ !

ពេលនោះមានក្មេងឃ្វាលគោម្នាក់ដើរដេញគោ ចូលភូមិជួបនឹងគីរីវុធ វាប្រាប់ថា :

-នុះ ! នៅជាយព្រៃខាងណោះ មានម៉ូតូពីរដូចម៉ូតូពូងឯងដែរកំពុងបើកទៅទិសខាងកើតហើយ ពួកវាបានសួរខ្ញុំរកផ្លូវវាងទៅដល់ភ្នំគូលែន ពួកនោះមានឱបបាវមួយផង !

គីរីវុធ ភ្ញាក់ផង អរផង !

-ពិតជាពួកវាហើយ ! អាអូនពួកវាមានគ្នាប៉ុន្មាននាក់ ?

-បាទ ! បួននាក់ !

គីរីវុធ អង្អែលក្បាលក្មេង :

-បងអរគុណហើយអាអូន ! អូនឯងអាចជូនបងបន្តិចបានទេ

-មិនបាច់ទេ ! បងឯងទៅតាមផ្លូវនេះអោយលឿន នឹងតាមទាន់ពួកនោះហើយ !

-ល្អណាស់ ! បងលាហើយ !

គីរីវុធ ត្រូវរង់ចាំពួកកងជំនួយដើម្បីហ៊ុំព័ទ្ធពួកវា ។ មិនយូរប៉ុន្មានស្នូររថយន្តក៏បានមកដល់ ។

-អ្នកទាំងអស់គ្នា យើងត្រូវតាមវាបន្តទៅទៀត ! ផ្លូវតូចណាស់

មិនអាចអោយឡានទៅមុខទៀតបានទេ ! សូមបងប្អូនឡើងតាមព្រៃនេះទៅ ” គីរីវុធ ចង្អុលទៅទិសព្រៃដែលក្មេងប្រាប់ កុំឈប់អោយសោះ ហើយអោយលឿនបំផុតដើម្បីជួយខ្ញុំ ឯខ្ញុំនឹងទៅតាមម៉ូតូដើម្បីស្កាត់ដំណើរពួកវា ។

គីរីវុធ បន្តដំណើរទៅទៀតឥតបង្អង់ឡើយ ...

នេះជាស្ថានការណ៍តក់កហល់ហើយ ... មិនអាចបណ្តែតបណ្តោយតទៅទៀតបានទេ ខ្មាំងច្បាស់ជាបញ្ជូនទេវរូបឆ្លងដែនហើយ !

ឯកងជំនួយក៏បានពង្រាយគ្នាធ្វើដំណើរទៅតាមក្រោយ ដែរ

ពេលនោះផ្ទៃមេឃចាប់ផ្តើមងងឹតហើយ តែភ្លើងម៉ូតូរបស់គីរីវុធ ចាំងភ្លឺរន្ទាលបើកកាត់ផ្លូវព្រៃយ៉ាងសែនលំបាក ជួនកាលប៉ះនឹងអង្កត់ឈើ និងដុំដីដំបូក តែទិសដៅត្រូវតែទៅមុខដាច់ខាត ។

ពួកវាបានចេញពីទៅមុនយូរក្រែងហើយ ព្រោះតាមផ្លូវស្រទន់ៗមានឃើញស្នាមប្រឡាក់កង់ម៉ូតូក្រឡៅ ។

តាមការធ្វើដំណើរពិបាកយ៉ាងនេះ ល្បឿនម៉ូតូមិនលឿនជាងល្បឿនគេដើរប៉ុន្មានទេ ដូច្នេះហើយបានជាគីរីវុធ ទទួលអារម្មណ៍ថាខ្លួនរំកិលទៅមុខយឺតក្រៃលែង ។

ការប្រដេញនេះ ខិតទៅមុខឥតថយឡើយរហូតដល់ភ្លឺ

ស្រាងៗ ទើបគីរីវុធ មកដល់វាលស្មៅខ្ពស់មួយនាយបែរមើលទៅ ជើងភ្នំឃើញព្រៃឈើខៀវស្រងាត់បែកអ័ព្ទក្រាស់ឃ្មឹក ។

នាយឱនមើលតាមស្មៅឃើញទក់ៗ ស្នាមរត់តំរង់ទៅរក ភ្នំ ... នាយតាមជាប់ពីក្រោយ តើវាទៅដល់ណា ? ។ ពិសេស បំផុតនាយបារម្ភតែម៉្យាង គឺខ្លាចពួកវាបញ្ជូនទេវរូបឆ្លងដែនផុត ជាការពិបាក ។

មកដល់ជិតចំរាក់ភ្នំដែលមានថ្មចោទសន្ធឹមដូចបាក់ពីលើ

នៅឯឆ្ងាយ នាយឃើញមនុស្សប្បូននាក់កំពុងប្រតោងមែក ឈើរត់ទៅមុខយ៉ាងលឿន ។

គីរីវុធ ងាករកម៉ូតូជុំវិញទីនោះតែឥតឃើញសោះ ! ... ពួក វាបណ្តោះយកទៅទុកឯណាហើយ !

-ចាំបាច់ត្រូវចាប់ខ្លួនអាបួននាក់នេះអោយបានទើបនាយ សង្ឃឹមថាស្រាវជ្រាវរកឃើញ ! តែវារត់ទៅឆ្ងាយគួរសមដែរ !

គីរីវុធ នឹកក្នុងចិត្ត ចំពេលដែលអត់ផ្លូវទៅមុខទៀត នាយ បង្ខំទំលាក់ម៉ូតូចោល ហើយរត់តាមពួកវា !

ពួកទុច្ចរិតប្រហែលជាដឹងថា មានមុនស្សតាមបានជាពួក វាខំរត់យ៉ាងលឿនណាស់ដែរ ។

ពេលវត់ទៅប្រកិតគ្នាបន្តិចហើយ ស្រាប់តែពួកអាបួននាក់គេចខ្លួនតាមប្រគាបថ្មអស់ ហើយវាបាញ់មកក្រោយភ្លាមឥតបង្អង់ ៖

-ប៉ុង ! ៗ !

គីរីវុធ ភ្ញាក់ព្រើត មិនស្មានថាពួកវាបាញ់មកក្រោយយ៉ាងនេះសោះ នាយក្រាបភ្លឹបហើយវលាស់កាំភ្លើងចេញជាបន្ទាន់ ...

-ប៉ុង ! ៗ ! ។ នាយបាញ់សងវិញភ្លាមឥតប្រណីដៃ ព្រោះនាយដឹងច្បាស់ថា កងជំនួយនឹងមកដល់ក្នុងពេលឆាប់ៗនេះហើយ ។

-ប៉ុង ! ពួកវាបាញ់មកដូចលាជផ្ទុះ

-ពួកអាបួននាក់នេះច្បាស់ជាមានគ្រាប់ច្រើនមើលទៅ បានជាហ៊ានបាញ់របៀបនេះ ។

គីរីវុធ គិតក្នុងចិត្ត ។ នាយក្រាបមិនហ៊ានងើបក្បាលអោយខ្ពស់ទេ បើអ្នកណាហ៊ានហើយតែបន្តិចគ្រាប់នឹងចូលទំលុះស៊ីខួរមិនខាន ។

ឯគីរីវុធ ក៏ដូច្នេះដែរ នាយចាំតែមើលពួកវាដែរ អោយតែអាឯងលេចក្បាលចេញបន្តិចអញបាញ់បេះអាឯងភ្លាមមួយរំពេចតែពួកវាចេះណាស់ដែរ វាមិនមែនភ្លើឯណា !

កំពុងតែគិត នាយពូសួរសិរីបខាងក្រោយខ្នង លុះងាកទៅក៏ឃើញពួកជំនួយមកដល់មែន ឃើញតែក្បាលលឹបលៗ ប្របេះៗគុម្ពស្មៅ ។

គិរីវុធ លូនតំរង់ទៅរកដោយស្រែកប្រាប់ថា :

-ខ្ញុំគឺ ក០០៥ ! គ្នាឯងទេ !

បន្ទាប់មកនាយទៅជួបនឹងប្រធានកងស៊ើបការណ៍ពោលតិចៗ :

-ពួកវាដៅសំងំនឹងប្រគាបថ្មខាងមុខនោះ ! ត្រូវប្រយ័ត្នអោយមែនទែន ! ពួកយើងបំបែកគ្នាឡើងទៅគ្រប់ទិសដើម្បីចាប់ពួកវាអោយបានទាំងរស់ណា ! យល់ទេ ! ឯខ្ញុំ ! ខ្ញុំបាញ់វាជាបន្តទៅទៀតកុំអោយវាដឹងខ្លួនថាពួកយើងហ៊ុំព័ទ្ធវា !

-បាទ ! យល់ !

តមកពួកគេបានបំបែកគ្នាហើយវាងទៅតាមទិសផ្សេងៗ

គិរីវុធ បែរក្បាលទៅវិញ នាយចាប់ផ្ដើមបាញ់បញ្ឆោត :

-ប៉ុង ! ៗ ! គ្រាប់ហើរទៅទង្គិចថ្មបណ្ដាលអោយបែកខ្ចាយ ! តែឥតទាន់ធ្វើអោយពួកវាត្រូវរបួសឡើយ ។

-ប៉ុង ! ៗ ! ពួកវាក៏បានផ្លាស់កន្លែងបាញ់សងមកវិញញាប់

ណាស់ដែរ ។

-លើកដៃ ! ហើយនៅអោយស្ងៀម !

សំរែកខ្លាំង ៗ ហាក់ដូចជាចង់អោយគីរីវុធឮសំរែកនេះ

នាយអរភើត ! ហៀបនឹងស្ទុះចោលចូលទៅហើយ តែ ...

-ប៉ុង !

-អូយ !

គីរីវុធ ក្រាបភ្លឹប ព្រោះនាយឥតដឹងសំលេងគ្រាប់ពីខាង

ណាទេ តែនាយឮសូរសំលេងគំរាម :

-កុំងើបអោយសោះ ! អាណាងើបតដៃ អញបាញ់ចោលទាំង

អស់ !

នាយធូរទ្រូងបន្តិច ព្រោះសំដីរបស់ពួកកងជំនួយកំញើញ

ពួកវា ។ មិនអស់ចិត្តនាយស្រែកពីចំងាយ :

-ចាប់បានអស់ហើយនៅ ?

-ចាប់ហើយលោកអធិការ !

ច្បាស់ហើយទើបនាយរត់ទៅភ្លាម ។ នៅលើផ្ទៃថ្មរលីង

ធំមួយ ពួកទុច្ចរិតបួននាក់ជាប់ចំណងក្រញង់ៗ ធ្វើមុខដូចស្វាជាប់

អន្ទាក់អីចឹង ។

គឺវុធ សំលឹងមុខពួកវា នាយភ្ញាក់ក្រញ៉ាង ព្រោះអាបីនាក់នោះគ្មានអ្នកណាក្រៅពីពួកអាបីនាក់ដែលលបវាយនាយកាលនៅខ្ទង់ទំនប់បារាយណ៍ទឹកថ្លានោះឡើយ ។ រីឯអាម្នាក់ទៀតត្រូវបាញ់អោយរបួសជើងឆ្វេង អង្គុយញាក់ទទ្រើតដូចកូនកណ្ដុរធ្លាក់ទឹក អានេះហើយដែលនាយឃើញវាជាមួយនាយឆោមកាលនៅក្នុងព្រៃអង្គរក្បែររូបបដិមាព្រះអង្គធំ ។ គ្រាន់តែឃើញភ្លាមនាយអាចសន្និដ្ឋានថា វាជានរណាស្រេចទៅហើយ ។

មុខនឹងជួបជាមួយពួកវា នាយដកយកទូរស័ព្ទពិសេសចេញមក ។

ស្នូរសំលេង និងភ្លើងសញ្ញា នាយរាយការណ៍ភ្លាម :

-ក០០៥ ជ្រុងខាងជើងភ្នំគូលែន ! សូមឧត្តមាគចក្រមួយមកយកអ្នកទោស ! អស់ ! ...

នាយដាក់វាចូលក្នុងហោប៉ៅវិញ ហើយដើរតំរង់អាចាក់ជើង នាយចាប់សក់វាភ្លើយឡើង :

-ហេតុអីបានជាឯងសំលាប់អាឆោម ?

តាមពិតនេះជាការសង្ស័យរបស់នាយទេ ! បើវាជាអ្នកសំលាប់អាឆោមមែន ច្បាស់ជាវាមិនហ៊ានឆ្លើយទេ គឺវាសារភាព

ដូច្នេះនាយត្រូវធ្វើ។

លុះឃើញវានៅស្ងៀមទើបនាយសួរទៀត :

-ប្រាប់អោយច្បាស់ហើយត្រង់ ក្រែងលោអាចបន្ធូរបន្ថយបាន

អញស្គាល់ឯងច្បាស់ណាស់ ព្រោះមុននឹងស្លាប់ អាឆោមបាន

ប្រាប់អញអស់ហើយ តែអាឯងត្រូវសារភាពទៀត ! ទីមួយអាឯង

សំលាប់អាឆោមដើម្បីដណ្តើមយកលុយពីវាទាំងអស់មែនទេ ?

វានៅស្ងៀម គីរីវុធ រឹតសក់វាកាន់តែខ្លាំង ហើយទះមួយ

ដៃកណ្តាលមុខវា :

-ផាច់ ! អានោះវិលខ្វាល់ហើយដួលលើដី វាភ័យញាក់ទទ្រើត

-កុំ ! ... កុំធ្វើ ... បាទខ្ញុំ ! ...

-អើឆ្លើយទៅ ! ឯងធ្វើអីខ្លះ ! ឯងសំលាប់អ៊ុំយន់ អ៊ុំចាន់មែន

ទេ ?

-បាទ ! ទេ ! មិន ...មែនទេ ! ... អ៊ុំយន់ត្រូវអ៊ុំចាន់សំលាប់...

ដើម្បីប្លន់យកទេវរូបត្បូងខ្មៅពីគាត់ ក្រោយ ... មកទើបអាឆោម

បបួលខ្ញុំសំលាប់អ៊ុំចាន់បំបាត់ដាន ដើម្បីយកទេវរូបត្បូងខ្មៅបន្ត

ទៀត! ...

គីរីវុធ ភ្ញាក់ព្រើត អាពីរនាក់ដែលនាយជួបកាលពីយល់

នៅភូមិត្រពាំងសេះ គឺអាហែង និងអាចោមគិតគ្នាសំលាប់តាចាន់ទេតើ ! នាយសួរវាបន្ត :

-បន្ទាប់មកអាឯងយកទេវរូបនោះទៅលាក់ទុកហើយយកទៅលក់មែនទេ ?

-បាទ !

-ឯងលក់អោយអ្នកណា ?

-លោក អសនី !

-អសនី ? គីរីវុធ ឧទានដោយភ្ញាក់ ព្រោះនាយស្មានមិនដល់ថា បងប្រុសរបស់រចនារកស៊ីក្បត់ជាតិយ៉ាងនេះសោះ ។

-រួចហើយយ៉ាងម៉េចទៀត ?

-បាទ ! ក្រោយពីនិយាយលក់អោយលោកអសនីរួចហើយខ្ញុំពីរនាក់អាចោមត្រូវនាំយកទេវរូបនោះទៅប្រគល់អោយពួកគេបីនាក់នេះដែលជាដៃជើងរបស់ថៅកែបារមនោរម្យ រួចហើយទើបខ្ញុំទៅទទួលប្រាក់ពីលោកអសនីឯសៀមរាបវិញ ។

គីរីវុធ ងាកទៅរកអាស្មួន អារស់ និងគូកនរបស់វាម្តង :

-មើលអា ! អ្នកណាជាអ្នកប្រឌិតរឿងបោកប្រាសនៅប្រាសាទវិមានអាកាស !

ស្ងាត់ច្រៀប គ្មានអ្នកណាឡើយ ។ នាយក្របូចកអាវអាសួនសំឡុត :

-គឺអាឯងមែនទេ ជាអ្នកសំលាប់អារ៉ិ :

អាសួនមុខខ្មៅដូចធ្យូង :

-ស្រីផិតផុនអារ៉ិ អ្នកណាក៏អាចសំលាប់វាបានដែរ !

-ផាច់ !

គីរីវុធ ដាក់វាមួយដៃ វាទ្រេតទៅម្ខាងហើយខ្ជាក់ឈាមចេញមក :

-និយាយជាមួយអញអោយស្រួលបន្តិចណា !

ត្រូវមួយដៃអានោះបែបស្លុតបន្តិច តែនាយបែរទៅខាងអារស់ម្តង :

-អញជឿថា អាឯងមិនចង់ឈឺខ្លួនទេ មែនទេ !

ត្រូវមួយដៃអានោះបែបស្លុតបន្តិច តែនាយបែរទៅខាងអារស់ម្តង :

-អញជឿថា អាឯងមិនចង់ឈឺខ្លួនទេ មែនទេ !

-មើលអ្នកណាជាអ្នកលេងឆាកកំប្លែងបោកប្រាសអញឯប្រាសាទវិមានអាកាស ? ហើយអ្នកណាជាអ្នកបាញ់សំលាប់អារ៉ិ !

-បាទ ! គឺចៅកែនៅភ្នំពេញនិងចៅកែបារមនោរម្យជាអ្នកគិតរឿងនេះ ព្រោះគេដឹងថាពួកគិញសំងាត់កំពុងតាមដានពួកគេ ដូច្នេះគេត្រូវតែបោកប្រាសលោក ដើម្បីបណ្តោះទេវរូបជាបន្តទៅទៀត គេបានទិញឡានវ៉ុលវ៉ាហ្គែនពីលោក អ៊ិន ស៊ិត់ ដើម្បីបង្វែឡានលោកហើយគឺអាសួសនេះហើយជាអ្នកសំលាប់អាវ៉ិ ! សូមលោកកុំធ្វើបាបខ្ញុំ !

អារស់និយាយទាំងមាត់ញ័របប៉ុប ។

គីរីវុធ ឈរច្រត់ចង្កេះ :

-យប់មិញពួកឯងប្រគល់ទេវរូបអោយទៅអ្នកណា ?

-បាទ ១ ! " អារស់និយាយតតាក់តតុប " ទេវរូបគេបានទទួលបន្តពីពួកខ្ញុំ តាំងពីល្វាចមិ្សលមិញម្ល៉េះ នៅឯងភូមិស្រែណូយ !...

គីរីវុធ ផ្ទារដៃ ចាញ់បោកពួកវាមួយចានទៀតម្ល៉េះទេវរូបបញ្ជូនទៅឆ្ងាយបាត់ ។

-ពួកឯងប្រគល់អោយអ្នកណា ?

-បាទ ! ដៃជើងចៅកែមកពីភ្នំពេញបីនាក់ម្នាក់ជាអ្នកបើក ឡាន ១៣៥៤៧៧ ដែលគេទុកចោលឯបន្ទាយស្រី ហើយយកវាបន្តដំណើរដោយម៉ូតូមកចាំពួកខ្ញុំស្រែណូយ ។ ពេលទទួលពីពួកខ្ញុំ

ហើយគេបានតាមផ្លូវជើងត្រលប់ទៅកាន់ក្រុងសៀមរាបវិញដើម្បីបន្តយកទេវរូបទៅភ្នំពេញ ...

-តើថៅកែនៅភ្នំពេញជាអ្នកណា ?

-បាទ ! បាទ ! ... ខ្ញុំឥតស្គាល់ទេ !

-ល្អ ! ប៉ុណ្ណោះទុកជាបានការ !

គីរីរុធ រុញអង់តែនប្រដាប់ស្រូបសំលេងដែលនាយបញ្ចេញមកស្រូបយកចំលើយពួកវាទុក ។ នាយនឹកសរសើរដល់ផែនការរបស់ពួកវាណាស់ ពិសេសគឺថៅកែបាវតែមួយ ។ ឥឡូវហាក់ដូចជាវ៉ែកអាថ៌កំបាំងចេញអស់ហើយ នៅតែតាមរកទេវរូបមកវិញ និងចាប់ពួកជនទុច្ចរិតតែប៉ុណ្ណោះ ក្នុងនោះនាយនឹកឃើញរចនា ដែលត្រូវជាប្អូនរបស់អសនី ! តើនាងមានអារម្មណ៍យ៉ាងណា នៅពេលដែលនាយចាប់រូបបងរបស់នាង ។

ដើម្បីកុំអោយពួកវារត់គេចខ្លួនទាន់ នាយប្រញាប់ប្រើទូរស័ព្ទឥតខ្សែអោយដំណឹងទៅមេបញ្ជាការភ្លាម :

-ក០០៥ សូមឃាត់ខ្លួន អសនី កូនលោក រួស រាយ និងថៅកែបាវមនោរម្យជាបន្ទាន់ ហើយចាត់ចែងឆែកឆេរអោយបានខ្លាំងក្លាបំផុតចំពោះជនសង្ស័យ ព្រោះទេវរូបបានបកទៅសៀមរាបវិញ

ហើយ ! អស់ !

សំលេងមួយលាន់ឡើយ ទាំងអស់គ្នាងាកទៅរកឧត្ដម្ភាគ ចក្រមួយជ្រែកអាកាសតំរង់មក :

-អោយសញ្ញាភ្លាម ថាយើងនៅទីនេះ !

គីរវុធ ឧទានប្រាប់ ។ ខាងជំនួយចងកន្សែង និងកូនឈើ ហើយលើកគ្រវី ។

បក្សីវិទ្យាសាស្ត្របោះពួយតំរង់មករក ហើយបន្ទាបខ្លួនពី ចំងាយ ។ គីរវុធ បញ្ជា :

-ឆាប់នាំពួកវាឡើងភ្លាមទៅ ! ទុកម្នាក់ជួយយកម៉ូតូរបស់ខ្ញុំ ទៅវិញផង !

-លោកអធិការ !

-មានការអីឬ ?

-ម៉ូតូរុញបញ្ចូលឧត្ដម្ភាគចក្រក៏បានដែរ ! យើងនាំគ្នាលើកទៅ

-អីចឹងក៏បានដែរ ! ចាត់ការភ្លាម

មួយភ្លែតប៉ុណ្ណោះ ការងារធ្វើហើយស្រេចបក្សីយន្តបង្ហើប ខ្លួនបន្តិចម្ដងៗពីផ្ទៃដី កំលាំងកង្ហាររបស់វាបំប៉ើងធូលីហុយសំពោង មួយភ្លែតប៉ុណ្ណោះ តួរបស់វាកប់បាត់នឹងផ្ទាំងពពក ហើយតំរង់ទៅ

កាន់ក្រុងសៀមរាប ។

គេក៏បានមកដល់គោលដៅ ហង្សយន្ត បន្ទាបខ្លួនពីមុខស្នងការ ។

នេះមិនមែនជារឿងធម្មតា ព្រោះកំរគេយកឧត្តម្ភាគចក្រមកប្រើណាស់ ។ ហេតុនេះ វត្ថុមានរបស់អាកន្ទុំរុយធ្វើអោយជនានុជនផ្អើលឆោឡោរត់មើលប្រសាច ។

## -៧-

-លោកមេបញ្ញាការ ” គិរីវុធ និយាយទៅកាន់លោកមេបញ្ញាការនៅពេលដែលនាយបានចូលទៅកាន់ការិយាល័យស្រួលបួលហើយ ” តើពួកថៅកែបារ និងអសនីបានឃាត់ខ្លួនហើយនៅ ?

-កិច្ចការរួចរាល់អស់ហើយ ! លោកអធិការឯងត្រូវការជួបនឹងគេឬ ?

-បាទ ! ព្រោះទីកន្លែងរបស់ទេវរូបបច្ចុប្បន្នមានតែគេទេទើបដឹង ពិសេសគឺថៅកែបារ ព្រោះគាត់ជាអ្នកបញ្ជូនទេវរូបទៅថៅកែឯភ្នំពេញទៀត !

-បើអីចឹង សូមលោកអញ្ជើញ !

គិរីវុធ និងលោកមេបញ្ញាការបោះជំហានទៅកាន់បន្ទប់មួយផ្សេងទៀត ហើយចាក់សោរចូលទៅ ។ បុរសពីរនាក់អង្គុយលើកៅអី យើងអាចស្គាល់ច្បាស់មួយជាថៅកែបារ និងមួយទៀតគឺអសនី ជាបងរបស់រចនា ។ អ្នកទាំងពីរមានទឹកមុខស្មើហាក់ដូចជាគ្មានរឿងរ៉ាវអីកើតឡើងចំពោះគេទេ !

គិរីវុធ ដើរទៅជិតថៅកែបា :

-សួស្ដីលោកថៅកែ ! លោកប្រហែលជាតូចចិត្តចំពោះការបរាជ័យនៃ ផែនការលោកណាស់មែនទេ !

-ហ៊ឹះ ! " ថៅកែបានិយាយ " ខ្ញុំឆ្ងល់ណាស់លោកអធិការហេតុម្ដេចក៏លោកចាប់មនុស្សទាំងទទឹងទទែងអីចឹង ?

-បាទ ! " គីរីវុធហួតបារីអុជជក់ " លោកត្រូវតែឆ្ងល់អីចឹងហើយ ព្រោះខ្ញុំបានឃាត់ខ្លួនលោកដោយឥតទំនងមែនទេ ? ខ្ញុំជឿថាបន្តិចទៀតលោកនឹងអស់ឆ្ងល់ជាមិនខាន !

ពោលចប់គីរីវុធដកយកប្រដាប់ស្រូបសំលេងដាក់លើតុហើយចុចគន្លឹះ ... ស្នូរសំលេងជជែកគ្នារវាងនាយ និងអាហែងនិងអាសួស អារស់ បានលាន់ឡើង ។ ថៅកែបារបែកញើសមុខអសនីឡើងស្លាំង អ្នកទាំងពីរជាមនុស្សអស់លក្ខណ៍ហើយ

ស្នូរសំលេងចប់ គីរីវុធ បិទគន្លឹះហើយច្រកក្នុងហោប៉ៅវិញៈ

-យ៉ាងម៉េច ! លោកលែងឆ្ងលល់ហើយមែនទេ ! ខ្ញុំសង្ឃឹមថាលោកពិតជាយល់ស្ថានការណ៍ ហើយនឹងឆ្លើយរឿងពិតប្រាប់ខ្ញុំជាមិនខាន !

-រឿងអីទៅ ?

-រឿងដែលថៅកែឯង និងថៅកែភ្នំពេញរៀបជើងព្រួលបណ្តោះទេវរូបនោះណា ?

-ទេវរូបនោះ គេយកទៅដល់ស្រុកសៀមហើយ !

ថៅកែនិនាយយកំបុតថ្លុយ ។

-មិនមែនទេ ! ទេវរូបនោះនៅក្នុងខេត្តយើងនៅឡើយ ហើយរៀបនឹងបណ្តោះយកជាបន្តទៅទៀតហើយ ! សូមលោកនិយាយអោយច្បាស់ទៅ ! ខ្ញុំជឿថាលោកឥតចង់ស្គាល់រសជាតិទារុណកម្មទេមែនទេ ? តែបើលោកបង្អំ ! ខ្ញុំនឹងជូនលោកខ្លះជាមិនខាន !

ថៅកែបារព្ធសូរទារុណកម្ម គាត់ប្រែទឹកមុខបន្តិចដែរ បែកញើសនៅលើថ្ងាសប៉ុនគ្រាប់ពោត ។

-យ៉ាងម៉េច ! លោកនិយាយទៅ ! " គីរីវុធ ផ្ទួនពាក្យ " ទីមួយទេវរូបនៅឯណា ? គេប្តូរគ្នានៅទីណា ? អ្នកណាជាអ្នកទិញបន្តពីលោក ?

-ដៃជើងរបស់ខ្ញុំបីនាក់បានអោយបន្តទៅគេហើយ ! ត្រង់គេយកទៅណាទៀតខ្ញុំឥតដឹងទេ !

-កុហក " គីរីវុធ គំហក " លោកប្រហែលជាចង់បានថ្នាំខ្លាំងហើយ ល្អណាស់ ខ្ញុំនឹងបំពេញជូនលោកឯង !

ថៅកែបាញ់រមាត់ប៉ប៉ុច :

-បាទ ! បាទ ! ... ទេវរូបបញ្ជូនបកមកសៀមរាបវិញហើយ មែន ... ហើយពេលម៉ោងដប់ពីរថ្ងៃនេះ គេនឹងដឹកមកតាមទូក នេសាទទៅប្រគល់បន្តអោយគេម្នាក់ទៀតនៅកណ្តាលទន្លេ !

-ទូកលេខប៉ុន្មាន ?

ថៅកែគ្រវីក្បាល :

-ខ្ញុំឥតស្គាល់ទេ ! ឯថៅកែឯភ្នំពេញក៏ឥតស្គាល់ដែរ !

-ល្អណាស់ ! ទុកដូចជាបានការ !

គីរីវុធ និងលោកមេបញ្ជាការចេញក្រៅ ។ លោកមេបញ្ជាការទះស្មានាយថ្មមៗ :

-គួរអោយសរសើរលោកអធិការណាស់ ! លោកស្រាវជ្រាវបានចង្កោមរបស់ពួកវាល្អណាស់ !

គីរីវុធ ញញឹម :

-នេះក៏ដោយសារមានជំនួយពីលោកដែរ ! យើងត្រូវធ្វើការជាបន្តទៀត ! ការឆែកឆេរ និងការរាំងស្កាត់ទូកនេសាទត្រូវជៀសវាងដាច់ខាត !

-ម៉េចអីចឹង ? " លោកមេបញ្ជាការសួដោយឆ្ងល់"

-ដើម្បីកុំអោយពួកវាដឹងខ្លួន ! ដែលអាចធ្វើអោយពួកវាប្តូរផែនការ នាំអោយយើងមានការលំបាក !

-យោបល់នេះប្រសើរណាស់ ! តើយើងត្រូវធ្វើដូចម្តេច ?

-នាវាប្រដេញរបស់យើងត្រូវប្រចាំការលើផ្ទៃទន្លេអោយបានច្រើន ពិសេសឧត្តម្លាគចក្រមួយត្រូវប្រចាំការ ការពារពេលណាមានការប្រយុទ្ធគ្នា លោកយល់ទេ !

-យល់ !

គីរីវុធ លើកនាឡិកាមើល ... ម៉ោងដប់មួយ

-យើងចេញទៅប្រតិបត្តិការភ្លាម ពេលវេលាដល់ហើយ តាមផែនការដែលបានគ្រោងទុក ! កុំភ្លេចប្រដាប់មុជទឹក ! ខែនេះទឹកជ្រៅណាស់ !

គីរីវុធ ហោះចេញទៅភ្លាម នាយទចង់ក៏មកដល់ទ្វាររបងនារីម្នាក់ឈរចាំជាស្រេច គឺនាងរចនា :

-បង ! បងវុធ !

គីរីវុធ ភ្ញាក់ព្រើត ស្មានមិនដល់ថារចនាពោលពាក្យស្និទ្ធស្នាលដល់ម្លឹងសោះ នាយឈប់ងក់ :

-អ្នកនាងមានការអីឬ ?

-ចាស់ ! អូនមករកបង ! តើបងប្រុសរបស់អូនមានរឿងអីទៅបង ?

-ហ៊ុ ! "គីរីវុធ ដកជង្គើម" បងរបស់អ្នកនាងជាជនទុច្ចរិតក្នុងការនាំយកទេវរូបត្បូងខ្មៅទៅលក់ឯបរទេសណា !

-ពុទ្ធោ ! នេះជាការពិតឬ ?

-សាក្សី និងវត្ថុភស្តុតាងមានគ្រប់គ្រាន់ហើយ មិនអាចប្រកែកបានទេ !

-បងវុធ ! "នាងធ្វើភ្នែកព្រិចៗ គួរអោយខ្នាញ់" សូមបងយោគយល់ដល់រូបអូន អនុគ្រោះអោយគាត់ទៅបានទេ ?

-មិនកើតទេអ្នកនាងរចនា ! នេះជាច្បាប់រដ្ឋណា ! មិនមែនស្រេចលើខ្ញុំទេ ! សូមអ្នកនាងមេត្តាអភ័យទោស ខ្ញុំមានការប្រញាប់ណាស់ ! សូមលាសិនហើយ !

ពោលចប់គីរីវុធ រត់ឡើងទន្សានដែលបើកសឹមៗ ចេញមកហើយបោះពួយលឿនស្លេវឆ្ពោះទៅទិសខាងត្បូង ។

ផ្ទៃទឹកទន្លេនារដូវវស្សាមានវិសាលភាពមិនខុសពីកូនសមុទ្រតូចមួយឡើយ ។ កាលណាគេឈរលើមាត់ច្រាំងត្រង់ភ្នំក្រោមមើលទៅមុខ គេឃើញតែផ្ទៃទឹកធំល្វឹងល្វើយប៉ុណ្ណោះ ។

នៅលើផ្ទៃទឹកល្ហល្ហាចជាប់ជើងមេឃ ទូកនេសាទតូចៗ កំពុងអណ្តែតប៉ែលប៉ោលលើរលកដែលប្រដេញគ្នាជាប់រដឹកឥតដាច់ ។

នៅពីលើ បក្សាបក្សីដែលមានចំពុះវែងៗ កំពុងហើរឆាបហ្វូងមច្ឆារធ្វើជាចំណី និងសត្វខ្លះបានទម្លាប់ខ្លួនហែលទឹកប្រដេញគ្នាធ្វើព្រងើយ ។

កូនកាណូតមួយរោទិ៍ម៉ាស៊ីនខ្ទ័រ បង្វិលស្លាបចក្រកាយទឹកបែកសសំព្រុះរត់លើផ្ទៃទឹកទៅមុខយ៉ាងលឿនហាក់ដូចជាមានការប្រញាប់ណាស់ ។

ពួកទុង រនាល ក្រសារ ដែលកំពុងហែលទឹកចេញចាប់ត្រីផ្អើលគិលហើយទទះស្លាបហើរគេចចេញយ៉ាងលឿន ។

នៅពីមុខកូនអូបរមួយចាំជាស្រេច ពួកនេះប្រាកដជាមានការអាថ៌កំបាំងអ្វីម្យ៉ាង ។

នៅពេលដែលកាណូតបានចូលអែបនឹងអូបរនោះហើយ ពួកនៅលើកាណូតបានលើកហិបឈើមួយហុចអោយអ្នកនៅលើអូបរហើយ ពួកគេបានឆ្លងទៅកាន់អូបរនោះទើបបើកកាត់ទទឹងទន្លេសំដៅច្រាំងខាងលិច ។ រីឯកាណូតក៏បើកប្រដេញតាមពី

ក្រោយដែរ ។

គ្រាន់តែអូបរចេញផុតពីទីជួបគ្នាអំបាញ់មិញបន្តិច អូបរចំនួនបួនបានបើកកាត់ទឹកបែកពពុះសំពោងចេញពីមាត់ច្រាំងជាបន្ទាន់តំរង់ទៅរកអូបរ និងកាណូតដែលឃើញស្រមោលព្រឹមៗឯនាយ ។

នៅលើអាកាសឯណោះ អាកន្ទុំរុយមួយកំពុងបង្វិលកង្ហារចក្រលាន់សំលេងខ្ទ័រឆាបពីលើ មិនខុសពីមានឥន្ទ្រីសំកាំងស្លាបចាំចាប់កូនត្រីឡើយ ។

ក្បួនវិទ្យាសាស្ត្រកំពុងប្រដេញគ្នាបែកទឹកខ្វាយ ហើយមិនយូរទេ គេនឹងតាមទាន់គ្នាមិនខាន ព្រោះក្រុមប្រដេញមានល្បឿនលឿនជាងពួកខាងមុខ ។

កន្លះម៉ោងក្រោយមក ការប្រដេញកាន់តែខិតជិតគ្នាមែនទែន !

ក្នុងអូបរប្រដេញមុខគេ យើងឃើញគីរីវុធ ឈរជំទែងលើកកែវឆ្លុះ ឆ្លុះមើលទៅអូបរខាងមុខ ។ នាយប្រាប់ថា :

-ពួកវាកំពុងបោលតំរង់ទៅរកជាយព្រៃហើយ ! មិនយូរទេ នឹងមានការប្រយុទ្ធគ្នាហើយ ! ប្រុងប្រៀបអោយមែនទែន ! ពិសេស

គឺរបាំងការពារត្រូវប្រយ័ត្ន ពួកវាច្បាស់ជាបាញ់សងមកយើងវិញមិនខាន ។

គីរីវុធ និយាយមិនទាន់ចប់ស្រួលបួលផង ស្នូរគ្រាប់កាំភ្លើងផ្ទុះឡើងភ្លាម :

-ប៉ុង !

គីរីវុធ ក្រាបភ្លឹប គ្រាប់ហើរពីលើក្បាលនាយពួសូរវឹត !

-បាញ់សងទៅពួកវាវិញ !

ផុតបញ្ជារបស់គីរីវុធ ពួកយើងបាញ់ប្រាវ :

-ប៉ុង ! ប៉ុង !

ស្នូរគ្រាប់អាវុធហើរលើផ្ទៃទឹកឆាវៗ ...

-អូយ ! ស្នូរសំរែកកប់ពពក ! អ្នកបើកបរកាណូតត្រូវពួកយើងបាញ់ត្រូវ ធ្លាក់ទឹកប្រូង ... កាណូតគ្មានអ្នកកាន់ចង្កូត ហើយវិលគ្មានគោលដៅមួយរំពេចៗ។ អាម្នាក់ដែលនៅលើកាណូត ឃើញសភាពការណ៍មិនស្រួល លោតទឹកប្រូង !

ពួកយើងប្រុងលោតតាម តែគីរីវុធ ឃាត់ :

-មិនបាច់តាមវាទេ ! វាគ្មានស្អីសំខាន់ប៉ុន្មានជាងពួកអានៅលើអូបរងណោះទេ ! ចាំពេលណាវាហែលហត់ហើយវាលើកដៃអោយ

យើងជួយស្រង់វាជាមិនខាន !

ជាបន្តបន្ទាប់គ្នានោះ អូបរចំនួនបួនបានវាយជារង្វង់ស្វែងក្របីហុំព័ទ្ធជលយានរបស់ពួកទុច្ចរិត ។

គួរអោយសរសើរដល់ទឹកចិត្តក្លាហានរបស់ពួកវាណាស់ ! វាឃើញសភាពការណ៍ទាល់ច្រកមែនទែនហើយ ក៏បាញ់មកលើពួកយើងដើម្បីរត់យកព្រះអាយុ ។ តែដោយមានរបាំងការពារគ្រប់គ្រាន់ ពួកយើងឥតទទួលគ្រោះថ្នាក់អ្វីឡើយ ហើយកាន់តែបង្រួញរង្វង់ហុំព័ទ្ធតូចទៅ ៗ ។

-ប្រយ័ត្ន !

គីរីវុធ ស្រែកភ្លាត់សំលេង ព្រោះពួកវាគប់គ្រាប់បែកមួយគ្រាប់មកលើពួកយើង !

ភ្លាមនោះរហ័សទាន់ចិត្ត អ្នកកាន់ចង្កូតបានកាច់យ៉ាងរហ័សបង្វិលក្បាលអូបរទៅម្ខាងជាមួយនឹងស្នូរ "ធ្លឹល" ផ្ទុះឡើងបែកទឹកសសំពោងទៅលើយ៉ាងខ្ពស់ !

ជាមួយគ្នានោះពួកវាបាត់ស្មានភាពលំនឹងដែរ :

-បាញ់សំរុកអោយមែនទែន !

ផុតបញ្ញារបស់គីរីវុធ គ្រាប់កាំភ្លើងហើរចេញពីត្រែកាំភ្លើង

ពួកយើង ដូចទឹកភ្លៀងទៅលើពួកវា ។

អូបរពួកយើងនៅតែបញ្ឆោះកៀងវានៅកណ្តាលជាប់ មិនអោយពួកវាគេចបានឡើយ តែយើងនៅមិនទាន់ហ៊ានទៅជិតវានៅឡើយទេ ដោយខ្លាចពួកវានៅសល់គ្រាប់បែកគប់មកទៀត ។

ពេលជាមួយនោះ អាកន្ទុំរុយឯលើអាកាសក៏បានឆាបចុះមកយ៉ាងទាបណាស់ដែរ ពួកជនទុច្ចរិតស្លន់ស្លោមែនទែន ពួកវានាំគ្នាលោតចុះទឹកអស់គ្មានសល់ ហើយអូបររបស់វា ដោយឃ្លេងឃ្លោងខ្លាំង លោកក៏ត្រូវក្រឡាប់លិចបាត់ក្នុងទឹក ។

-ពួកយើងមុជតាម !

ផុតបញ្ជារបស់គីរីវុធ ទាំងអស់គ្នាពាក់ប្រដាប់មុជទឹកភ្លាម ទាំងគីរីវុធទាំងកងស៊ើបការបានលោតចូលក្នុងទឹកឥតបង្អង់ ។ ឯអូបរនៅតែបើកធ្វេលលើផ្ទៃទឹកដដែល ចាំស្រង់អ្នកងើប ។

ពពុះទឹកអណ្តែតឡើងលើភល។ មួយស្របក់ក្រោយមកមិនបានកន្លះម៉ោងផង ពួកទុច្ចរិតមួយនាក់ត្រូវពួកយើងចាប់បានហើយរុញឡើងជលយាន រួចបញ្ចូលខ្នោះលេខប្រាំបីអោយវាជាបន្ទាន់ នៅតែគីរីវុធម្នាក់ប៉ុណ្ណោះមិនទាន់ងើប ព្រោះនាយកំពុងតាមយកទេវរូបដែលកប់បាត់ក្នុងភក់បាតទន្លេ ។

កន្លះម៉ោងក្រោយមក គីរីវុធងើបពីទឹកដោយមានប្រដាប់ដកដង្ហើមជាប់នឹងច្រមុះ ។ អ្នូបរបើកទៅជិត គ្នាយើងស្រែកសួរ

-ឃើញទេវរូបទេលោកអធិការ ?

-ឃើញហើយ តែលើកមិនរួចទេ ! ហុសខ្សែមកខ្ញុំមុជទៅចងឯក្រោម ពេលណាឃើញខ្សែញាក់ចាប់លើកភ្លាមណា !

ខ្សែមួយចង្វាយត្រូវទំលាក់ជាបន្ទាន់ ហើយគីរីវុធក៏មុជចុះទៅបាតទន្លេសារជាថ្មី ។

មួយរយៈពេលដ៏ខ្លី ហិបឈើដាក់ទេវរូបត្រូវបានលើកឡើងអ្នូបរជាមួយនឹងក្តីរីករាយជាពន្លឹកករបស់ពួកយើង ។

គីរីវុធ ដោះប្រដាប់មុជទឹកចេញ នាយធ្វើសញ្ញាអោយអាកាសយានបន្ទាបខ្លួនចុះជាបន្ទាន់ :

-ជួយលើកហិបទេវរូបដាក់ទៅក្នុងយន្តហោះ និងពួកអាចោរលួចប៉ុន្មាននាក់នេះផង ឯគ្នាយើងក្រៅពីអ្នកបើកបរក៏ត្រូវឡើងលើយន្តហោះដែរ !

ផុតបញ្ហាទាំងអស់គ្នាបោះពួយឡើងលើហង្សវិទ្យាសាស្ត្រឥតបង្អង់ បន្ទាប់មកអាកន្ទុំរុយក៏បែរក្បាលបោះពួយទៅកាន់ក្រុងសៀមរាបក្រោមផ្ទៃមេឃដ៏ស្រឡះនាវស្សារដូវ ។

នៅក្នុងការិយាល័យស៊ើបអង្កេត ចំពោះមុខលោកមេបញ្ជាការ និងគីរីវុធ អធិការខាងស៊ើបអង្កេតក្រោមលេខសញ្ញា ក០០៥ គេកំពុងគាស់ហិបដែលទើបដណ្តើមបានពីជនទុច្ចរិតថ្មីៗ នេះ ។

គ្រាន់តែគំរបរបើកចេញភ្លាម គេចោលភ្នែកមើលវត្ថុដ៏មានតំលៃ ដែលគេខិតខំតាមដានជាយូរមកហើយ ។

គីរីវុធ លូកដៃលើកទេវរូបដែលស្រោបក្រដាសទន់ក្រាស់ឃ្មឹក :

-អស្ចារ្យ ! ទេវរូបនេះធ្ងន់ណាស់តើ សមតាមពាក្យលោកនាយកអភិរក្សប្រាសាទបូរាណប្រាប់មែន ទំងន់ប៉ែតសិបគីឡូក្រាមឥតខុស ។

ក្រោយពីស្រាយក្រដាសខ្ចប់ចេញអស់ហើយ តួទេវរូបអង្គុយពេនពណ៌ខ្មៅក្រិប ពិតជាសាងអំពីត្បូងមរកតដ៏ល្អប្រណិត ហើយខាងស្តាំមានស្នាមបែកបន្តិច គឺជាស្នាមដែលអ៊ឹយន់កាប់ប៉ះកាលគាត់គាស់គល់ឯចំការ ហើយដោយសារស្នាមបែកនេះហើយដែលអាចអោយគីរីវុធដឹងថា ឃាតកម្មលើរូបអ៊ឹយន់ គឺដោយសារតែទេវរូបត្បូងខ្មៅនេះឯង ។

នៅលើចិញ្ចើមរបស់ទេវរូប ពេជ្រមួយគ្រាប់ប៉ុនមេជើង

ចេញពន្ទីព្រាត :

-អស្ចារ្យណាស់ ! ដីខ្មែរកាលណោះពិតជាសុវណ្ណភូមិមែន បានជាមានត្បូងពេជ្រល្អដល់ម្លឹងក្នុងការសាងទេវរូបនេះ ។

គិរីវុធ លាន់មាត់ហើយងាកទៅលោកមេបញ្ជាការ :

-តើលោកគិតយ៉ាងម៉េចអំពីទេវរូបនេះ ! ត្រូវបញ្ជូនទៅភ្នំពេញសិន ឬក៏ប្រគល់អោយខាងក្រសួងអភិរក្សអង្គរថែរក្សា ?

-ត្រូវបញ្ជូនទៅភ្នំពេញ ។ នៅពេលដែលលោកអញ្ជើញទៅរាយការណ៍ឯភ្នំពេញ សូមលោកយកវាទៅផងចុះ ពិសេសសគួរផ្តល់រង្វាល់ដល់គ្រួសារសពអ៊ំយន់ដែលបានជីកបានទេវរូបនេះ ។ តាមពិតបើគ្មានឃាតកម្មលើរូបគាត់ទេនោះ គាត់ច្បាស់ជាយកទេវរូបនេះប្រគល់ឱ្យរដ្ឋមិនខាន មិនអីចឹងឬ ?

-ត្រូវហើយ !

ពេលនោះភ្នាក់ងារម្នាក់ចូលមកគោរព :

-លោកអធិការ ! មាននារីម្នាក់មករកលោក !

-នាំនាងចូលមក !

មួយស្របក់នារីម្នាក់ចូលមក :

-យ៉ាំនីទេ ? " គិរីវុធ ឧទានដោយភ្ញាក់ " ប្រសើរណាស់បង

កំពុងចង់ជួបអូនដែរ ។ អង្គុយមកអូន !

យ៉ានី នៅស្ងៀមស្ងាត់សំលឹងមើលទេវរូបដែលតំកល់លើតុ។ គីរីវុធ ចង្អុលប្រាប់ :

-អូនយ៉ានី ! ហេតុអ្វីបានជាលោកអ៊ុំគេសំលាប់អូនដឹងទេ ?

យ៉ានី នៅស្ងៀម គីរីវុធ បន្ត :

-គឺលោកអ៊ុំជីកបានទេវរូបនេះ ពេលនោះអ៊ុំចាន់ឃើញ ដោយចិត្តលោភលន់ពេក អ៊ុំចាន់បានឃុបឃិតជាមួយនឹងអាឆោមសង្សារអូនឯង ។ ក្រោយមកទៀតនៅពេលដែលបងមកដល់ផ្ទះអូន អាឆោម និងអាហែងបានរួមគ្នាសំលាប់អ៊ុំយន់ទៀតដើម្បីបំបិទមាត់គាត់កុំអោយលេចឮតទៅទៀត ...។

-អ្ហា ! អីចឹងបងឆោមជាឃាតក ! ពុទ្ធោ !

យ៉ានីឧទាន មុខនាងទ្បើងស្លាំង :

-បងធ្វើម៉េចដឹង ?

-ចាំស្ដាប់បងនិយាយអោយអស់សិន ! កាលពីម្សិលមិញនេះអាហែង និងអាឆោមបានយកទេវរូបទៅប្ដូរយកប្រាក់ តែអាហែងដោយលោភចង់បានម្នាក់ឯងក៏សំលាប់អាឆោមបន្តទៀត ! ឯអាហែងបងចាប់បានហើយ !

-បងឆោមស្លាប់ទៅហើយ ? " យ៉ានីស្រែកភ្ញាត់សំលេង"

-ត្រូវហើយ ! នេះគឺឈាមស្រែកហៅណាអូន ! យ៉ានីតាម បងនេះមិនមែនក្អួយរបស់អ៊ំទេ ! ការដែលបងធ្វើនេះ គឺដើម្បីស៊ើបរកមុខឃាតកតែប៉ុណ្ណោះ ប៉ុន្តែចាប់ពីពេលនេះទៅ អូនទុកដាក់បងជាបងរបស់អូនម្នាក់ទៅចុះ ។ ឥឡូវនេះក្រសួងបានផ្តល់រង្វាន់ជាសគុណចំពោះអូនជួសអ៊ំដែល ជីកបានទេវរូបនេះហេតុនេះ សូមអូនមកទទួលពីលោកមេបញ្ជាការផងណា ! ឯបងសូមលាអូនហើយ ព្រោះបងត្រូវធ្វើដំណើរទៅកាន់ក្រុងភ្នំពេញក្នុងពេលឆាប់ៗនោះហើយ !

យ៉ានី គ្មានពាក្យនឹងថ្លែងចេញមកទេ មានតែទឹកភ្នែកប៉ុណ្ណោះ ដែលហូររហាមកាត់ផែនថ្ពាល់របស់នាង ។ ជាតិនេះ នាងអភ័ព្វណាស់ ឪពុកត្រូវសង្សារលបលួចសំលាប់ ហើយសង្សារក៏ស្លាប់ទៅទៀត ! តើនាងសង្ឃឹមលើនរណា ? ស្រមោលរបស់គីរីវុធដិតជាប់ក្នុងបេះដូងរបស់នាង តែស្រមោលនេះចាំក្នុងចិត្តរបស់នាងជានិច្ច ព្រោះគីរីវុធ មិនមែនជាបងប្រុសរបស់នាងទេ ហើយនាងក៏គ្មានសង្ឃឹមថានឹងបានជួបនឹងគីរីវុធទៀតដែរ ។

នាងក្រោកឡើង ហើយសំពះលាលោកមេបញ្ជាការ និង

គីរវុធ ៖

-ខ្ញុំជំរាបលាហើយ !

ទឹកភ្នែកស្រីស្រក់តក់ៗ នាងឥតហ៊ានងើបមុខសំលឹងគីរវុធឡើយ ហើយបែរខ្លួនយឺតៗប្រុងបោះជំហានចេញ តែ ៖

-ឈប់សិននាង ! " លោកមេបញ្ជាការ " សូមនាងទទួលយកប្រាក់ប្រាំពាន់រៀលសិនទៅ ទំរាំមានសេចក្តីសំរេចចិត្តរបស់ក្រសួងតាមក្រោយ ខ្ញុំនឹងថែមជូននាងទៀត !

លោកមេបញ្ជាការប្រគល់ប្រាក់អោយយ៉ានីដែលទទួលដោយម្រាមដៃញ័រទទ្រើក ព្រោះប្រាក់នេះមានចំនួនច្រើនក្រៃលែងសំរាប់រូបនាង ។ រួចហើយនាងលាចេញទៅក្រោមខ្សែភ្នែកអាណិតមេត្តារបស់គីរវុធ

យ៉ានី ចេញផុតទៅ គីរវុធ និងលោកមេបញ្ជាការនាំគ្នាទៅកាន់បន្ទប់ឃុំជនទុច្ចរិត ចាក់សោរបើកទ្វារចូល ។ គីរវុធ ឥតភ្ញាក់ផ្អើលលទេ ព្រោះជនបីនាក់ដែលចាប់បានពីទន្លេគឺអ្នកដែលនាយបានឃើញក្នុងឡាន ១៣៥៤៧៧ នាយសួរភ្លាម ៖

-ត្រូវឆ្លើយអោយខ្លីបំផុត បើមិនចង់ឈឺខ្លួនទេ ! តើចៅកែដែលទិញទេវរូបនៅភ្នំពេញឈ្មោះអី ?

វាសំលឹងមុខគ្នាទៅវិញទៅមក អាម្នាក់ស្គមជាងគេទំនងជាភ័យខ្លាំង ញ័រមាត់ :

-សូមលោកកុំធ្វើបាបខ្ញុំ ! ខ្ញុំធ្វើតាមគេទេ !

-យើងដឹងហើយ " គីរីវុធ " តែយើងចង់ដឹងថាថៅកែនៅភ្នំពេញឈ្មោះអី ?

-បាទ ! គឺលោក រស់សំណព្វ ! គាត់ជាអ្នករកស៊ីរត់ពន្ធវត្ថុបូរាណទៅលក់ឯបរទេស !

គីរីវុធ ស្ទុះចេញក្រៅ នាយអោយដំណឹងទៅភ្នំពេញជាបន្ទាន់ដើម្បីចាប់ខ្លួនលោក រស់ សំណព្វ ភ្លាមដើម្បីកុំអោយជនទុច្ចរិតបណ្ដោះខ្លួនទៅទៀត ។

ទេវរូបត្បូងខ្មៅបានរកឃើញហើយ ឯបណ្ដាញជនទុច្ចរិតក៏ក្រសោបបានអស់ហើយ ។ គីរីវុធ ទៅដល់ផ្ទះនារតីដោយហេវហត់ព្រោះអត់ងងុយ និងគ្មានអាហារមួយថ្ងៃមកហើយ ។

នារតីរត់មកទទួលសង្សារ :

-បងវុធ ! បងទៅណាយប់មិញ !

គីរីវុធ លើកបីសង្សារថើបថ្ពាសនាងយ៉ាងយូរ :

-ព្រលឹងអើយ ! បងមកសៀមរាបនេះ គឺដើម្បីតាមរកឃាតក

សំលាប់អ្នកជិកបានទេវរូបត្បូងខ្មៅណា ! ឥឡូវនេះរកឃើញហើយ!

នារតី ឱបកសង្សារ :

-បេសកកម្មរបស់បងចប់ហើយមែនទេ ?

-ត្រូវហើយ !

-ដូច្នេះ ! តើថ្ងៃណាទើបបងនាំលោកពូមកគិតគូររឿងយើង

-ចាំបងមកពីភ្នំពេញសិន ! អូនជំរាបលោកអ៊ំផងណា ! បងទៅភ្នំពេញថ្ងៃនេះហើយ !

-អត់ទេ ! កុំអាលទៅអីបង នៅលេងមួយថ្ងៃពីរសិនទៅ !

-ទេ ! បេសកកម្មចប់មែន តែមិនទាន់ទៅរាយការណ៍ឯក្រសួងទេណា !

គីរីវុធ ដាក់សង្សារចុះ ហើយថើបនាងយ៉ាងយូរ :

-បងលាហើយណាព្រលឹងបង !

សំលេងម៉ូតូរោទិ៍យ៉ាងខ្លាំង គីរីវុធ ទាញវ៉ែនតាគ្រប់លើ ភ្នែក លើកដៃបក់លាសង្សារ ហើយយានក៏រត់តិចៗចេញទៅដោយទឹកមុខក្រៀមស្រពោន ។

នៅចំពោះមុខលោកនាយកក្រសួងស៊ើបអង្កេត គីរីវុធ អង្គុយបីតចារិបង្អុយផ្សែងចាំស្តាប់បទបញ្ជាថ្មី :

-លោកអធិការ អច្ឆរិយា នេះរូបថតថៅកែ រស់ សណព្វ !

គីវរុធ ឬ អច្ឆរិយា ទទួលរូបថតមកមើល នាយភ្ញាក់ខ្លាំងមែនទែន ព្រោះលោក រស់ សណព្វ គ្មានអ្នកណាក្រៅពីឪពុកមារបស់រចនាដែលនាយជួបនៅផ្ទះនាងឯសៀមរាបនោះឡើយ ។ លោកនាយកបន្ត :

-តាមចំលើយសារភាពរបស់គាត់ គាត់បានប្រាប់ថា ទេវរូបត្បូងខ្មៅនេះជារបស់ទីពីរដែលគាត់ទិញពីសៀមរាបបំរុងនឹងបញ្ជូនទៅស្រុកថៃ !

-ចុះរបស់ទីមួយជាស្អីទៅ ?

-របស់ទីមួយគឺឈ្មោះ រស់ សំណព្វ នេះបានលក់ទៅស្រុកថៃផុតទៅហើយ នោះគឺរូបហង្សមាសទំងន់ដប់គីឡូក្រាម ។ ពួកទុច្ចរិតថៃហ៊ានទិញដល់ទៅហាសិបគីឡូក្រាមមាសសុទ្ធ ។ ហង្សមាសនេះជីកបាននៅលើកំពូលភ្នំសន្ទុក ក្បែរប្រាសាទនៅទីនោះ ។ ហេតុនេះបេសកកម្មរបស់លោកលើកក្រោយនេះ គឺត្រូវទៅនាំយករូបហង្សមាសពីស្រុកថៃមកវិញ ។ សំណុំលិខិត និងការងារ ផ្សេងៗក្រសួងបានរៀបចំអស់ហើយ សូមលោករៀបចំខ្លួនទៅណា ហើយត្រូវចេញដំណើរនៅថ្ងៃស្អែកនេះ ដើម្បីកុំអោយហង្សនេះបាត់បង់។

សូមលោកទៅរៀបចំខ្លួនចុះ ។ លោកត្រូវចាំថា នៅក្នុងប្រទេស លោកមានឈ្មោះថា គីរវុធ តែនៅលើឆាកអន្តរជាតិ លោកមាន ឈ្មោះថាអច្ឆរិយា ក០០៥ ចាំអោយច្បាស់ ។

គីរវុធ គោរពលាហើយចេញក្រៅ នារីម្នាក់ឈរចាំនាយ ជាស្រេច :

-បងវុធ !

-យី ! រចនា ! អូនមកភ្នំពេញយូរហើយ ?

-ចាស់ ! ពេលដឹងថាបងមកភ្នំពេញអូនក៏តាមមកភ្លាម ! " នាងធ្វើភ្នែកព្រិចៗចង់យំ " បងវុធ ! អូនដឹងថាបងមានគូដណ្ដឹង ហើយ តែអូននៅតែស្រលាញ់បង ព្រោះបងបានឃើញរូបកាយ អូនអស់ទៅហើយ ! អូនមិនអាចទទួលបុរសណាផ្សេងបានទៀតទេ តែអូនគ្មានសង្ឃឹមថាបងនឹងផ្តល់ក្តីសង្ឃឹមអោយអូនវិញដែរ ព្រោះ របស់អូន ឪពុកមារបស់អូនសុទ្ធតែជាជនទុច្ចរិត ! តែទោះយ៉ាងនេះ ក្តី អូនគ្រាន់តែជំរាបបងថា អូនមិនអាចទទួលបុរសណាផ្សេងបាន ទៀតទេ !

គីរវុធភ្ញាក់មិនតិចទេចំពោះសំដីរបស់រចនា នាយនឹកឃើញ កាលនាងត្រូវពួកពាលប៉ងចាប់រំលោភ ហើយបាននាយជួយ

CATALOGUED IN ALCPH
No. 2199
Date ...

នាង មិនគួរនាងតាំងចិត្តដល់ម៉ឺងសោះ ។ តើអោយនាយដោះស្រាយដូចម្ដេចទៅ ?

នាយពោលតិចៗ :

-រឿងបងអ្នកនាងជាជនទុច្ចរិត គ្មានទាក់ទងដល់អ្នកនាងទេ ! ឯរឿងយើងទាំងពីរ ខ្ញុំពុំទាន់ឆ្លើយរួចដែរ ព្រោះខ្ញុំត្រូវទទួលបេសកកម្មទៅស្រុកថៃ ដើម្បីតាមយកហង្សមាសមកជូនមាតុភូមិវិញ ហេតុនេះចាំបងមកពីស្រុកថៃវិញសិន សឹមនិយាយគ្នាទៀត ! បងលាហើយ !

គីរីវុធ បោះជំហានចេញទៅ ដោយទុកអោយរចនាឈរត្រិះរិះពីបញ្ហាមួយម៉ឺនជំពូករង់ចាំថ្ងៃនាយត្រឡប់ពីតាមរកហង្សមាសមកវិញ ។

- ចប់ -

CATALOGED IN ALEPH
No : 29992
Date 12. 03. 2017